ល្ខោនយីកេរឿង

# ក្បួនជីវិត

និពន្ធដោយលោក ទី ជីហ្វត

ចងក្រងឡើងវិញដោយក្រុមគរុនិស្សិតអក្សរសាស្ត្រខ្មែរក្រុមទី ២០

ជំនាន់ទី ២០ នៃវិទ្យាស្ថានជាតិអប់រំ៖

កញ្ញា កៅ សុកជា

កញ្ញា ឆន់ ស៊ីថា

កញ្ញា នឿន ដារីន

លោក ផន វិបុល

ព.ស.២៥៥៩ គ.ស.២០១៥

# អារម្ភកថា

រឿង **ក្បូនជីវិត** គឺជាប្រភេទល្ខោនយីកេ ដែលនិយាយអំពីដំណើរជីវិតសាត់អណ្តែតរបស់តួអង្គនាងមាលា។ មិនត្រឹមតែប៉ុណ្ណោះ រឿងនេះក៏បានបង្កប់នូវតម្លៃអប់រំយ៉ាងជ្រាលជ្រៅដល់មនុស្សជំនាន់ក្រោយ តួយ៉ាងដូចជាការសម្រេចចិត្តជ្រើសរើសគូស្រករ ការជ្រើសរើសមុខជំនាញដ៏ពិតប្រាកដមួយសម្រាប់ជីវិតជាដើម។

រឿង **ក្បូនជីវិត** ជាស្នាដៃនិពន្ធដោយកវី **ឌី ឌីឃួត**។ ស្នាដៃនេះបន្ទាប់ពីបានសរសេររួចរាល់ អ្នកនិពន្ធក៏ប្រគល់ឱ្យវិទ្យុសំឡេងប្រជាជនកម្ពុជា (សព្វថ្ងៃវិទ្យុជាតិ) រៀបចំថតសម្តែងដើម្បីចាក់ផ្សាយតាមវិទ្យុ។ រឿងនេះត្រូវបានចាក់ផ្សាយតាមវិទ្យុសំឡេងប្រជាជនកម្ពុជានៅថ្ងៃទី២៨ ខែមិនា ឆ្នាំ១៩៨៧ គឺនៅក្រោយពេលដែលលោកស្លាប់អស់រយៈពេលជាច្រើនថ្ងៃ។

ដោយមើលឃើញ ពីតម្រូវការចាំបាច់សម្រាប់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៅតាមបណ្តាគ្រឹះស្ថានសិក្សាទាំងឡាយ ក៏ដូចជាពីអត្ថន័យ អត្ថរូប និងអត្ថរសដ៏ល្អរបស់រឿងនេះ ទើបក្រុមគរុនិស្សិតអក្សរសាស្ត្រខ្មែរមួយក្រុម ដែលមានសមាជិកបួននាក់នេះ សម្រេចចិត្តយកខ្សែអាត់សំឡេង បីដុំមានរយៈពេលប្រហែល បីម៉ោងមកចម្លងចេញជាអត្ថបទសំណេរ។ ដូច្នេះហើយ យើងខ្ញុំទាំងអស់គ្នាក៏សូមមេត្តាមិត្តអ្នកសិក្សាទាំងអស់អភ័យទោសរាល់ចំណុចខ្វះខាតដែលកើតមានដោយអចេតនាលើស្នាដៃនេះ។ បើទោះបីជាយើងខ្ញុំធ្វើការត្រួតពិនិត្យសារចុះសារឡើងហើយក៏ដោយ ក៏ប៉ុន្តែកំហុសឆ្គងអាចនឹងកើតមានចៀសមិនផុតទេ។ ម្យ៉ាងវិញទៀត ចំពោះការសរសេរឈ្មោះរបស់តួអង្គនីមួយៗនៅក្នុងសាច់រឿង យើងបានធ្វើការពិភាក្សាគ្នារួចក៏កំណត់ថាឈ្មោះនេះសរសេរបែបនេះ ឈ្មោះនោះសរសេរបែបនោះ ដោយពុំមានឯកសារណាយោងឡើយ។ ហេតុនេះយើងខ្ញុំទាំងអស់គ្នា រង់ចាំទទួលដោយរីករាយនូវមតិរិះគន់ស្ថាបនាកែលម្អគ្រប់បែបយ៉ាង ពីមជ្ឈដ្ឋានអ្នកសិក្សា ដើម្បីឲ្យស្នាដៃមួយនេះប្រកបដោយលក្ខណៈត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ និងមានតម្លៃជាសកល។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា ស្នាដៃមួយនេះ នឹងបានចូលរួមចំណែកក្នុងការលើកស្ទួយវិស័យអក្សរសាស្ត្រ អក្សរសិល្ប៍ជាតិឱ្យមានភាពរីកចម្រើនទៅមុខ។

**រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥**

**គរុនិស្សិតអក្សរសាស្ត្រខ្មែរ ក្រុមទី២០ ជំនាន់ទី២០**

# សេចក្ដីថ្លែងអំណរគុណ

ស្នាដៃនេះអាចសម្រេចជាលទ្ធផលនៅពេលនេះ គឺដោយសារការផ្ដល់ទាំងកម្លាំងកាយ ការលើកទឹកចិត្ត និងផ្ដល់ជាសម្ភារពីបណ្ដាមនុស្សជាទីគោរព និងស្រឡាញ់រាប់អានរបស់យើងខ្ញុំ។

យើងខ្ញុំទាំងអស់គ្នា សូមសម្ដែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកអ្នកដ៏ខ្ពង់ខ្ពស់ទាំងឡាយដែលមានដូចខាងក្រោម៖

- លោកឪពុកអ្នកម្ដាយរបស់យើងខ្ញុំទាំងអស់គ្នា ដែលតែងតែផ្ដល់ជាកម្លាំងចិត្ត និងថវិកាដល់កូនៗទាំងអស់គ្នា
- អ្នកស្រីសាស្ត្រាចារ្យ **សន ម៉ុម** ដែលបានជំរុញ និងតែងតែលើកទឹកចិត្តដល់យើងខ្ញុំទាំងអស់គ្នាក្នុងការចងក្រងស្នាដៃនេះ
- មិត្តៗគរុនិស្សិតអក្សរសាស្ត្រខ្មែរ ជំនាន់ទី២០ នៃវិទ្យាស្ថានជាតិអប់រំ ដែលបានផ្ដល់ជាកម្លាំងចិត្តដល់យើងខ្ញុំ។

# **ឧទ្ទិសកថា**

ជាបឋមយើងខ្ញុំទាំងអស់គ្នាសូមឧទ្ទិសស្នាដៃនេះជូនចំពោះ វិញ្ញាណក្ខន្ធរបស់អ្នកនិពន្ធ **ឌី ឌីហ្វូត** ដែលបានបន្សល់ទុកនូវស្នាដៃជាច្រើនដល់អ្នកសិក្សាជំនាន់ក្រោយបានសិក្សា និងស្វែងយល់ពីតម្លៃរបស់ស្នាដៃទាំងនោះថែមទៀតផង។ ជាក់ស្តែង គឺស្នាដៃដែលលោកអ្នកសិក្សាទាំងឡាយកំពុងកាន់ក្នុងដៃនាពេលនេះជាដើម។ សូមវិញ្ញាណក្ខន្ធរបស់លោក បានទៅកាន់សុគតិភព។

យើងខ្ញុំសូមឧទ្ទិសស្នាដៃមួយនេះ ជូនចំពោះវិញ្ញាណក្ខន្ធរបស់ **មហាបុរស រដ្ឋបុរស បណ្ឌិត កវី អ្នកនិពន្ធខ្មែរ បញ្ញាវ័ន្ត** ទាំងអស់ ដែលលោកបានរក្សាការពារ និងបន្សល់ទុកនូវមត៌កវប្បធម៌ដ៏ខ្ពង់ខ្ពស់ដល់កូនចៅជំនាន់ក្រោយ។

យើងខ្ញុំក៏សូមឧទ្ទិសស្នាដៃនេះ ជូនចំពោះជនរួមជាតិខ្មែរទាំងអស់ ដែលបានលះបង់ទាំងកម្លាំងកាយ ចិត្ត និងកម្លាំងប្រាជ្ញាធ្វើប្រយោជន៍ដល់ជាតិខ្មែរ។

# កម្រងជីវប្រវត្តិរូប
# សង្ខេបរបស់អ្នកចងក្រង

# ជីវប្រវត្តិរូបសង្ខេប



ឈ្មោះ ៖ **គៅ សុភជា** ភេទ ស្រី

ថ្ងៃខែឆ្នាំកំណើត ៖ ១៧ មេសា ១៩៩១

ទីលំនៅបច្ចុប្បន្ន ៖ ភូមិស្វាយក្បោ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

ស្ថានភាពគ្រួសារ ៖ នៅលីវ

កម្រិតវប្បធម៌ ៖ គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ + ១)

ប៉ុស្តិ៍បម្រើការងារ ៖ ខេត្តស្វាយរៀង

ឪពុកឈ្មោះ ៖ **គៅ ធីរៈ** មុខរបរ នគរបាល

ម្តាយឈ្មោះ ៖ **ទេព ស៊ីម** មុខរបរ អាជីវករ

ចំណាប់អារម្មណ៍ក្នុងការចងក្រងស្នាដៃ៖ តាមការពិតព្រោះស្រឡាញ់តម្លៃអប់រំនៅក្នុងរឿងនេះ ហេតុនេះហើយក៏ខ្ញុំសម្រេចចិត្តចងក្រងរឿងនេះឡើង។ វាជួបនូវការលំបាកខ្លះដូចជាពិបាកស្តាប់ខ្សែរអាត់សំឡេង ពិបាករៀបឆាកនិងឃុតឃ្លោន ចំណាយពេលច្រើនសម្រាប់ការស្តាប់និងកែសម្រួលឡើងវិញជាដើម។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែជំនះនូវភាពលំបាកទាំងនោះ ដើម្បីចូលរួមថែរក្សាអក្សរសិល្ប៍ជាតិឱ្យមានភាពសម្បូរបែបនូវឯកសារប្រើប្រាស់ដែរ។

**រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៥**

# ជីវប្រវត្តិរូបសង្ខេប



ឈ្មោះ ៖ **ឆន់ ស៊ីថា** ភេទ ស្រី

ថ្ងៃខែឆ្នាំកំណើត ៖ ១០ តុលា ១៩៨៨

ទីលំនៅបច្ចុប្បន្ន ៖ ភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប

ស្ថានភាពគ្រួសារ ៖ នៅលីវ

កម្រិតវប្បធម៌ ៖ គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ + ១)

ប៉ុស្តិ៍បម្រើការងារ ៖ ខេត្តសៀមរាប

ឪពុកឈ្មោះ ៖ **ឆោគ ឆូ** មុខរបរ កសិករ

ម្តាយឈ្មោះ ៖ **ម៉ឹខ ប្រែចខ** មុខរបរ កសិករ

ចំណាប់អារម្មណ៍ក្នុងការចងក្រងស្នាដៃ៖ ការចងក្រងស្នាដៃនេះឡើង ដោយសារការស្រឡាញ់ និងចង់លើកស្ទួយសម្បត្តិវប្បធម៌ខ្មែរឱ្យនៅគង់វង្ស។ ពិសេសមូលហេតុចម្បងដែលនាំឱ្យក្រុមយើងខ្ញុំបង្កើតនូវស្នាដៃដ៏តូចមួយនេះ ដោយសាររឿងនេះមិនមានជាឯកសារទេ គឺគ្រាន់តែជាខ្សែអាត់សំឡេងប៉ុណ្ណោះ។

**រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៥**

# ជីវប្រវត្តិរូបសង្ខេប



| | | | |
|---|---|---|---|
| ឈ្មោះ | ៖ | **នឿន ដាវីន** | ភេទ ស្រី |
| ថ្ងៃខែឆ្នាំកំណើត | ៖ | ២៥ មេសា ១៩៩២ | |
| ទីលំនៅបច្ចុប្បន្ន | ៖ | ភូមិអង់ឃ្លាំ ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ | |
| ស្ថានភាពគ្រួសារ | ៖ | នៅលីវ | |
| កម្រិតវប្បធម៌ | ៖ | គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ + ១) | |
| ប៉ុស្តិ៍បម្រើការងារ | ៖ | ខេត្តសៀមរាប | |
| ឪពុកឈ្មោះ | ៖ | **នឿន គឹមយឿន** | មុខរបរ គ្រូបង្រៀន |
| ម្តាយឈ្មោះ | ៖ | **ព្រិន សម្បត្តិ** | មុខរបរ មេផ្ទះ |

ចំណាប់អារម្មណ៍ក្នុងការចងក្រងស្នាដៃ៖ អក្សរសាស្ត្រខ្មែរមានសារៈសំខាន់ណាស់សម្រាប់សិស្ស និស្សិត និងប្រជាពលរដ្ឋ សិក្សាស្វែងយល់ដើម្បីដឹងពីឫសគល់នៃវប្បធម៌ អរិយធម៌ដ៏រុងរឿងរបស់ជាតិ។ ហេតុនេះហើយទើបយើងខិតខំចងក្រងស្នាដៃនេះឡើង ដើម្បីបន្សល់ជាស្នាដៃសម្រាប់ក្មេងៗជំនាន់ក្រោយបានដឹងទាំងអស់គ្នា។

**រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៥**

# ជីវប្រវត្តិរូបសង្ខេប



ឈ្មោះ ៖ **ផន វិបុល** ភេទ ប្រុស

ថ្ងៃខែឆ្នាំកំណើត ៖ ០៩ តុលា ១៩៨៥

ទីលំនៅបច្ចុប្បន្ន ៖ ភូមិក្តីស្លា ឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

ស្ថានភាពគ្រួសារ ៖ រៀបការ មានកូនប្រុស ១

កម្រិតវប្បធម៌ ៖ គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ + ១)

ប៉ុស្តិ៍បម្រើការងារ ៖ ខេត្តស្វាយរៀង

ឪពុកឈ្មោះ ៖ **ចិន ផល** មុខរបរ កសិករ

ម្តាយឈ្មោះ ៖ **ខួន សុគន់** មុខរបរ កសិករ

ចំណាប់អារម្មណ៍ក្នុងការចងក្រងស្នាដៃ៖ ក្នុងការរៀបរៀងឡើងវិញ ដើម្បីឱ្យស្នាដៃល្ខោនយីកេរបស់អ្នកនិពន្ធ ទី ជីហួត ឱ្យលេចចេញជារូបរាងអត្ថបទសំណេរ ដើម្បីងាយស្រួលក្នុងការអានរបស់អ្នកសិក្សាព្រោះថារឿងនេះមានតែខ្សែអាត់សំឡេង និងដើម្បីលើកកម្ពស់ខឿនអក្សរសាស្ត្រ អក្សរសិល្ប៍ជាតិឱ្យរីកចម្រើនរុងរឿងឡើង។

ម្យ៉ាងទៀតរូបកូនក៏សូមគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកអ្នកមានគុណទាំងទ្វេដែលបានពុះពារការលំបាកក្នុងការប្រកបការងារ ដើម្បីឱ្យរូបកូនបានសិក្សាស្វែងរកចំណេះរហូតបានដូចសព្វថ្ងៃនេះ។

**រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៥**

# ល្ខោនយីកេរឿង ក្បួនជីវិត

## និពន្ធដោយលោក ទី ជីហួត

## ឈុតទី ១

(ពោល) នេះនឹងថ្លាថ្លែងចែងចរចា នូវរឿងនិទានដ៏ខ្លោចផ្សា កុមារីកំព្រាមាតា ម្ដាយចុងឫស្យាចិត្តឃោរឃៅ។

## ឆាកទី ១

មាលា ៖ អាអូន!

ពិសី ៖ ចាំ!

មាលា ៖ ម៉ែឱ្យបងហូបតែបាយទទេ អត់មានម្ហូបសោះ!

ពិសី ៖ អ៊ីចឹង បងឯងយកម្ហូបតិចទៅណា?

ចន្ទី ៖ ពិសីកូន!

ពិសី ៖ ចាំ!

ចន្ទី ៖ ម៉េចក៏កូនឯងមកញ៉ាំបាយជាមួយនឹងវា អ្នាស់?

ពិសី ៖ អ្នកម៉ែ... ខ្ញុំ... នែ៎...!

ចន្ទី ៖ ហ៊ឹស! មីឃ្លា! ម៉េចក៏មីហងឯងមកដណ្ដើមត្រីពីកូនអញចឹងហ្អា?

មាលា ៖ អត់ទេ! អាអូនឱ្យខ្ញុំទេតើ! (ចន្ទីវាយ) ...អូយ...

ពិសី ៖ ម៉ែ! កុំវាយបងខ្លាំងពេក!

ចន្ទី ៖ មីចង្រៃដណ្ដើមរបស់ពីកូនអញផងហ្អេស៎?

មាលា ៖ (យំ) អូយ... ម៉ែឱ្យខ្ញុំហូបតែបាយទទេ...!

ចន្ទី ៖ អីក៏សម្បើមម្ល៉េះជាមួយនឹងអញណ៎ា!

មាលា ៖ ម៉ែឱ្យតែអាអូន ខ្ញុំឃ្លានពេក ខ្ញុំសុំម៉ែបានម្ដង!

ចន្ទី ៖ យស!

មាលា ៖ អូយ...!

ចន្ទី ៖ អីក៏សម្បើមម្ល៉េះ? ជាមួយនឹងអញណ៎ា!

មាលា ៖ អូយ...!

ចន្ទី ៖ អញប្រាប់ ថ្ងៃក្រោយអត់មានអ៊ីចឹងទៀតទេ! ស្លាប់ទៅកុំសម្លឹងមុខអញ! (ច្រៀង) ចំជាចិត្តធំ មីកូនកំព្រា (ពីរដង) កាត់ដូច ម្ដាយវា សត្រូវស្នេហា (បន្ទរ៖ កាត់ដូចម្ដាយវា សត្រូវស្នេហា) ព្រាត់ពីមុខ

អញឱ្យឆាប់ទៅវ៉ា (ពីរដង) ចេញពីគេហា ទៅស្លាប់ណាចុះ!

**មាលា** ៖ ម៉ែ...!

**ចន្ទី** ៖ ហ៊ឹស! មីគម្រក់! ទៅឱ្យផុតបាត់ពីមុខពីមាត់អញភ្លាមទៅ! ថាចេញពីផ្ទះឱ្យបាត់ទៅ! ទៅ!

**មាលា** ៖ អូយ!...ម៉ែឱ្យខ្ញុំទៅណា...?

**ចន្ទី** ៖ ព្រាត់ទៅស្លាប់ឯណាក៏ទៅៗ! ទៅ!

## ឈុតទី ២

(ពោល) ឈប់ស្លេះត្រឹមណេះមួយកន្លែង ថ្លែងពីបុរសជាបិតា ត្រឡប់មកផ្ទះដល់កាលណា សាកសួរដឹងការណ៍ខ្វល់ខ្វាយក្រៃ។

## ឆាកទី ២

**តេជ័យ** ៖ អូនហ្ន៎ា?

**ចន្ទី** ៖ អ៊ើ... ម្ចាស់ចិត្តអូនអ្ហើយ! បង... បងអញ្ជើញមកវិញហើយ! ហេតុអីក៏បាត់យូរម្ល៉េះបង?

**តេជ័យ** ៖ បងជាប់រវល់ក្នុងព្រះរាជធានីណាអូន! នែ៎! បម្រើការក្រសាលបរបាញ់របស់ព្រះរាជាណាអូន ទើបពុំបានមកផ្ទះ!

**ចន្ទី** ៖ អ៊ូ ! បងដង្ហែព្រះអង្គទៅប្រពាតព្រៃឬ? ដូច្នេះបងច្បាស់ជាបានសប្បាយ បានលាភសក្ការៈច្រើនណាស់ហើយមើលទៅណាបងហ្ន៎?

**តេជ័យ** ៖ ហ៊ឹស! គេសប្បាយនឹងលាភសក្ការៈទាំងផងទាំងពួងនោះ បានតែទៅលើដៃពួកឧត្តមមន្ត្រីទេ ជាពិសេសមន្ត្រីក្នុងវាំង! ចំណែកឯបងដែលជាមន្ត្រីតូចតាចវិញ បន្ទាប់ពីការហត់នឿយ! ណាស់ហើយសុំឱ្យតែរួចខ្លួនទៅចុះ! ជួនកាលពុំបានរួចខ្លួនផង ចេះតែខុសនេះទាស់នោះស្រួលមិនស្រួលធ្លាក់ពីតំណែងមួយរំពេច!

**ពិសី** ៖ ពុក... មកវិញហើយពុក?

**តេជ័យ** ៖ ហ៎ា ពិសីកូន! មកឱ្យពុកពរបន្តិចមើល! ឯណាមាលាបងរបស់ឯង?

**ចន្ទី** ៖ បង... បងហ្ន៎ា? បងផ្លាស់សម្លៀកបំពាក់ទៅបង!

**តេជ័យ** ៖ ត្រូវហើយអូន! អ្ហ៎ា ចុះកូនមាលាទៅណាទៅ?

| | | |
|---|---|---|
| **ចន្ទី** | ៖ | ហ៊ឺស! កូនស្រីទំយើរបស់បងឯង វាធ្វើឱ្យខ្ញុំគ្រាំគ្រាទ្រូង រហូតស្ទើរនឹងស្លាប់ចោលបងឯងជាមិនខានទេមើលទៅខ្ញុំនេះ! |
| **តេជ័យ** | ៖ | ហ៊្អា! រួចមាលាវាធ្វើទុក្ខអូនម្ដេចទៅហ៊្អា? |
| **ចន្ទី** | ៖ | អ៊ើស! ពិបាកណាស់លោកអើយអាចិញ្ចឹមកូនរបស់គេនេះ វាធ្វើម៉េចនឹងស្ដាប់បង្គាប់បើមិនមែនជាម្ដាយរបស់វាបង្កើតផងនោះ! |
| **តេជ័យ** | ៖ | មាលា! កំព្រាម្ដាយតាំងពីនៅតូច ដូច្នេះហើយបានជាបងពឹងលើអូនដែលជាម្ដាយក្រោយរបស់វាណា! |
| **ចន្ទី** | ៖ | ហ៊ឺស! ខ្ញុំគ្មានសមត្ថភាព នឹងគ្រប់គ្រងកូនដើមរបស់បងឯងទេ! បងឯងមើល... មើល វាដើរទៅណាបាត់ពីផ្ទះទៅហើយ? |
| **តេជ័យ** | ៖ | យី! មាលាទៅណា? |
| **ចន្ទី** | ៖ | ធ្វើម៉េចនឹងខ្ញុំដឹងបាន! |
| **តេជ័យ** | ៖ | រួចទៅពីអង្កាល់? |
| **ចន្ទី** | ៖ | បាត់តាំងតែពីថ្ងៃត្រង់ម្ល៉េះ! មកបង... បងផ្លាស់សម្លៀកបំពាក់សិនទៅបង? |
| **តេជ័យ** | ៖ | ទេ! បងត្រូវទៅរកកូនសិន! នែ៎! ពូបាវ! |
| **ពូបាវ** | ៖ | បាទទាន! |
| **តេជ័យ** | ៖ | ឆាប់នាំគ្នាជួយរកមាលា កូនស្រីរបស់ខ្ញុំផងមើល! |
| **ពូបាវ** | ៖ | បាទ! បាទ! |
| **តេជ័យ** | ៖ | រកឱ្យគ្រប់ទីកន្លែងទាំងអស់ណា? |
| **ពូបាវ** | ៖ | បាទ! |
| **តេជ័យ** | ៖ | ហ៊ឺស! កូនបាត់តាំងពីថ្ងៃត្រង់មកម្ល៉េះ ឥឡូវនេះជិតព្រលប់ទៅហើយ ហេតុអីបានជាអូនមិនចាត់មនុស្សឱ្យដើររក? តិចលោមានគ្រោះថ្នាក់អីទៅ មិនវឹវរទេអ្ហី! |
| **ចន្ទី** | ៖ | ហ៊ឺស! បងឯងនេះ ស្រឡាញ់កូនជាងស្រឡាញ់ប្រពន្ធទៅទៀត! ពិបាកចិត្តណាស់លោកអើយ ហេតុតែឯងជាម្ដាយចុងរបស់គេ! ធ្វើម៉េចក៏មិនត្រូវ! ធ្វើម៉េចក៏មិនត្រូវដែរ! (ច្រៀង) រាល់ថ្ងៃខ្វល់ខ្វាយតែបម្រើវា រក្សាគាំពារគ្មានទំនេរដៃ (ពីរដង) ប៉ុន្តែកូនហ្នឹងរឹងរូសពេកក្រៃ មីកូនចង្រៃនាំរឿងអាស្រូវ ធ្វើម៉េចក៏ខុសធ្វើម៉េចក៏ខុស |

ប្រាប់ខ្ញុំមកចុះតើធ្វើម្ដេចត្រូវ (ពីរដង) ឈឺចាប់ខ្លាំងណាស់ឱវ៉ាឆ្អួលក្ដៅ សាច់គេអ្នកក្រៅមិនដូចឈាមឯង!

**តេជ័យ** ៖ ចន្ទីអូន សូមអូនកុំខឹងសម្បាអី! បងដឹងហើយថា អូនស្រឡាញ់ចិញ្ចឹមបីបាច់មាលាដូចជាកូនបង្កើត ដូច្នេះបើកូនវាទាស់ខុសអី ចូរអូនជួយអប់រំកូនផង កុំប្រកាន់ក្មេងធ្វើអីណា!

**ចន្ទី** ៖ ហ៊ឺស! ខ្ញុំណែនាំអប់រំវាអីនឹងស្ដាប់ បើពុកវាកាន់ជើងម្ល៉េះនោះ!

**តេជ័យ** ៖ យ៉ាងម៉េចទៅ រកមាលាឃើញទេ?

**ពូបាវ** ៖ បាទ! រកសព្វខ្យល់អស់ហើយលោក! អត់ឃើញទេលោក!

**តេជ័យ** ៖ ហ៊ឺស!

**ពូបាវ** ៖ នែ៎! រកតាមសួន រកតាមកំពង់ទឹក ហើយសួរគេសួរឯងគ្មានចន្លោះទេលោក! ក៏ប៉ុន្តែអត់មានអ្នកណាឃើញស្រមោល... នែ៎... ក្មួយមាលាទេលោកម្ចាស់!

**តេជ័យ** ៖ ហ៊ឺ...! ជិតព្រលប់ទៅហើយ កូនរបស់ខ្ញុំទៅណាអ៊ីចេះ? អ៊ូ! នឹកឃើញហើយ! កូនមាលាច្បាស់ជាទៅផ្ទះលោកតារបស់វាហើយ! ពូ...!

**ពូបាវ** ៖ បាទ!

**តេជ័យ** ៖ ដឹកសេះមកឱ្យខ្ញុំ ឆាប់ឡើង!

**ពូបាវ** ៖ បាទ! បាទ!

**ចន្ទី** ៖ ហ៊ឺស! មិនបាច់ទៅរកអីទេបង! វាគង់ត្រឡប់មកវិញទេ!

**តេជ័យ** ៖ មិនកើតទេអូន!ក្មេងស្រីអាយុប្រាំបីឆ្នាំអ៊ីចឹង បើអូនធ្វេសប្រហែសវាអាចជួបនឹងគ្រោះថ្នាក់ដោយប្រការណាមួយមិនខាន! បងទៅហើយ...!

**ចន្ទី** ៖ ហ៊ឺស! បន់ឱ្យតែមីចង្រៃហ្នឹងវាស្លាប់ឱ្យស្រឡះទៅ កុំឱ្យនៅថ្ងៃក្រោយ ពិបាកចែកកេរមរតកជាមួយកូនរបស់អញទេ!

## ឈុតទី ៣

**(ពោល) កាលអើយកាលនោះណា មាលាទៅដល់ផ្ទះជីតា ក៏រត់ចូលពួនក្នុងគុម្ពផ្កា គេចពីបិតាដែលតាមរក។**

# ឆាកទី ៣

មាលា ៖ អឺ! ផ្ទះលោកតាលោកយាយសប្បាយណាស់! អឺ! គាត់ទៅណាអស់ហើយបានជាស្ងាត់អ៊ីចឹង?

(សម្លេងសេះបោល)

មាលា ៖ យី! ពុកខ្ញុំមកហើយ! គាត់ច្បាស់ជាមកតាមខ្ញុំហើយ ខ្ញុំចូលពួនគុម្ពផ្កាសិន!

(សម្លេងសេះបោល និងស្គរជោទ៏)

ទេពសិលា ៖ យី! នែ៎ អ្នកណាហ្នឹង? អ៊ូហូ! កូនតេជ័យទេហ្អី?

តេជ័យ ៖ ពុក! ម៉ែនៅទេ?

ទេពសិលា ៖ ម៉ែឯងនៅខាងក្រោយ!

តេជ័យ ៖ ពុកមានបានឃើញមាលាមកទេពុក?

ទេពសិលា ៖ អាណាគេ?

តេជ័យ ៖ មាលា!

ទេពសិលា ៖ អ៊្ហា! មិនឃើញទេវ៉ី! ចុះចៅមាលា វាមកជាមួយអ្នកណា?

តេជ័យ ៖ បាទ! មាលាបាត់ពីផ្ទះតាំងពីថ្ងៃត្រង់មកម្ល៉េះពុក!

ជីដូនមាលា ៖ យី! ស្លាប់ហើយ! ហេតុអីក៏ឯងធ្វេសប្រហែស មិនមើលកូនអ៊ីចឹងតេជ័យ?

តេជ័យ ៖ ម៉ែ! កូនទើបតែនឹងបានដឹងនៅពេលព្រលប់ មកពីធ្វើការនេះវិញទេ!

ជីដូនមាលា ៖ ចន្ទីចំជាផ្ដេសផ្ដាសមែន ចម្ងាយពីផ្ទះរបស់ឯងមកទីនេះ បើសិនជាមាលាវាដើរមកតាំងថ្ងៃត្រង់នេះ វាគង់តែដល់ទៅហើយ! ឥឡូវនេះគិតយ៉ាងម៉េចទៅហាស់? ឯងរកក្បែរផ្ទះហើយនៅកូន?

តេជ័យ ៖ រកអស់ចំណោះហើយម៉ែ!

ទេពសិលា ៖ យី! វាខឹងអីហ្អា?

ជីដូនមាលា ៖ វាខឹងអី?

តេជ័យ ៖ ខ្ញុំអត់ដឹងទេពុក មាលាចូលចិត្តពួនប្រលែងលេងនឹងកូនណាស់ កូនសង្ស័យតែវាពួននៅក្បែរៗ នេះទេ!

ជីដូនមាលា ៖ អ៊ើនែ៎! ប្រកូកហៅលមើលទៅកូន!

**តេជ័យ** ៖ (ស្រែក) មាលា អើមាលា! មាលា កូននៅឯណា ចេញមកកូន!

**ទេពសិលា** ៖ ហ៊ឺ! នាំឱ្យព្រួយបារម្ភមែន! ឯងឆាប់ត្រឡប់ទៅវិញទៅ! ស្វែងរកឱ្យមែនទែនណាប្រយ័ត្ន! នែ៎! នែ៎! ចៅរបស់អញ វាមានគ្រោះថ្នាក់ណ៎ា!

**តេជ័យ** ៖ ខ្ញុំទៅវិញហើយម៉ែ!

**ជីដូនមាលា** ៖ អើ... អើ... មិនស្រួលទេណ៎ា ខំរកកូនឱ្យឃើញឱ្យឆាប់ឡើងណាតេជ័យ!

**តេជ័យ** ៖ បាទ...!

**(សម្លេងសេះបោល)**

**ជីដូនមាលា** ៖ មាលាច្បាស់ជាខឹងនឹងចន្ទី វាយធ្វើបាបហើយតាវ៉ា!

**ទេពសិលា** ៖ ហ៊ឺ! ពិបាកណាស់ អារឿងម្ដាយចុង ហើយនឹងអាកូនដើម!

**ជីដូនមាលា** ៖ អើ៎! យប់ហើយណា ខ្ទាស់ទ្វាររបងទៅ ខ្ញុំទៅអុជចង្កៀងសិន!

**ទេពសិលា** ៖ ខ្ញុំមើលទៅ បាយមិនចូលទេយប់នេះ បើវាមានរឿងយ៉ាងនេះអ៊ីចឹង!

**មាលា** ៖ (សើច) លោកតា!

**ទេពសិលា** ៖ អើ... មាលា! ចៅឯងមកពួនសំងំតាំងពីអង្កាល់ហាស់? ស្លាប់ហើយ ចៅធ្វើឱ្យឪពុកភ័យណាស់ណា! យាយវ៉ា... នែ៎...នែ៎... មាលា... យាយវ៉ា!

**ជីដូនមាលា** ៖ ហ្ន៎ា! ចៅឯងមកពីអង្កាល់មាលា?

**មាលា** ៖ ចាស៎! ខ្ញុំមកដល់មុនពុកបន្តិចហ្នឹងណាលោកយាយ!

**ជីដូនមាលា** ៖ យី! បើអ៊ីចឹង! ហេតុអីបានជាឯងពួនមិនឱ្យពុកឃើញណាចៅ?

**មាលា** ៖ ហ៊ឺ... ព្រោះខ្ញុំខ្លាចពុកនាំខ្ញុំទៅផ្ទះវិញ!

**ជីដូនមាលា** ៖ ហ្ន៎ា ម៉េចអ៊ីចឹង?

**ទេពសិលា** ៖ ចុះហេតុអីបានចៅមិនចង់ទៅវិញចៅ?

**មាលា** ៖ ខ្ញុំអត់ទៅផ្ទះវិញទេលោកតា!

**ជីដូនមាលា** ៖ កូនតេជ័យ វាស្លន់ស្លោណាស់! នែ៎! តាវ៉ាឆាប់ទៅពឹងអាអន្ទិតជុំឱ្យជិះសេះ ទៅប្រាប់វាផង កុំឱ្យកូនវាភ័យយូរពេកណា!

**ទេពសិលា** ៖ អើ! យាយវ៉ាឯងឆាប់រៀបចំបាយទឹកឱ្យមាលាទៅ! នែ៎...! លោកអើយអាណិតចៅណាស់ មុខឱ្យខ្មៅអែចៅ!

**ជីដូនមាលា** ៖ ចាស៎ កុំព្រួយ! មកចៅ លុបមុខ លាងដៃនឹងអាលហូបបាយណាចៅ!

**មាលា** ៖ លោកយាយ! កុំឱ្យពុកនាំខ្ញុំទៅផ្ទះវិញអីលោកយាយ!

**ជីដូនមាលា** ៖ ហ៎ា! ចៅខឹងអីណាចៅ ប្រាប់យាយមកមើលណាចៅ! ចៅប្រាប់មក!

**មាលា** ៖ ខ្ញុំអត់ទៅផ្ទះវិញទេ លោកយាយជួយខ្ញុំផង កុំឱ្យពុកនាំខ្ញុំទៅផ្ទះវិញណាលោកយាយខ្ញុំអត់ទៅផ្ទះវិញទេ! (ច្រៀង) ម៉ែគាត់ស្អប់ខ្ញុំ វាយជុំរាល់ថ្ងៃ (ពីរដង) អាហារ អាហារចំណី ពុំឆ្ងាញ់ពិសា (បន្ទរះ អាហារ អាហារចំណី ពុំឆ្ងាញ់ពិសា) ពេលពុកមិននៅ ខ្ញុំឃ្លានម្ល៉េះរ៉ា (ពីរដង) ខ្ញុំសែន ខ្ញុំសែនខ្លោចផ្សា ស្រណោះខ្លួនពេក (បន្ទរះខ្ញុំសែន ខ្ញុំសែនខ្លោចផ្សា ស្រណោះខ្លួនពេក) ខ្ញុំហើយនឹងប្អូន ម៉ែគាត់បែងចែក (ពីរដង) ទោះបី ទោះបីដំណេក ក៏ពុំដូចគ្នា! (និយាយ) លោកយាយអើយជួយចៅផង ចៅអត់ទៅផ្ទះវិញទេ! លោកយាយអើយពេលហូបបាយ ម៉ែបេះសាច់ឱ្យតែអាអូន ហ៊ឺ... ឱ្យខ្ញុំហូបតែឆ្អឹងៗ!

**ជីដូនមាលា** ៖ កុំស្រក់ទឹកភ្នែកអី!

**មាលា** ៖ នំចំណីអីគាត់ឱ្យតែអាអូន គាត់ស្រឡាញ់តែអាអូន គាត់ស្អប់ខ្ញុំ!

**ជីដូនមាលា** ៖ ចៅអើយ! នេះមកពីចៅឯង វាគ្មានម៉ែនឹងគេណាចៅ!

**ទេពសិលា** ៖ ចុះហេតុអី បានជីដូន និងចៅ យំទល់មុខគ្នាអ៊ីចឹងហ្អា?

**ជីដូនមាលា** ៖ តាវាអើយ! ខ្ញុំអាណិតចៅខ្ញុំណាស់!

**ទេពសិលា** ៖ ហ៊ឹម...! យាយវាអើយ ខ្ញុំដឹងយូរហើយ ចន្ទីនេះវាកាចណាស់ ហើយចិត្តវាក៏មិនល្អ! ប៉ុន្តែឱ្យខ្ញុំធ្វើម៉េចហាស៎?

**តេជ័យ** ៖ ពុក...!

**ទេពសិលា** ៖ អ៎! តេជ័យ កូនមកហើយកូន!

**តេជ័យ** ៖ មាលា! ហ៊ឺស! ស្លាប់ហើយ ពុកខំដើររកកូនសឹងដាច់ខ្យល់ ហេតុអីក៏កូនពួននឹងពុកអ៊ីចឹង?

**មាលា** ៖ ពុក... កូន... កូន...អត់ទៅផ្ទះវិញទេ!

**ទេពសិលា** ៖ អើចៅ! បើថានេះ នៅដេកលេងជាមួយតាហ្នឹងសិនហើយក៏បានចាំស្អែកចាំនែ៎... នែ៎... តាជូនទៅណាចៅ?

| | | |
|---|---|---|
| **មាលា** | ៖ | ទេ... ហ៊ឺ... ខ្ញុំនៅជាមួយលោកតារហូតហើយ ខ្ញុំអត់ទៅផ្ទះវិញទេ! |
| **តេជ័យ** | ៖ | យី! ម៉េចក៏កូនមិនទៅផ្ទះអ៊ីចឹង? |
| **ជីដូនមាលា** | ៖ | នែ៎! នែ៎! ម៉េចក៏មិនប្រាប់ពុកឯងទៅចៅ? |
| **មាលា** | ៖ | (យំ) លោកយាយអើយ ចៅអត់ទៅផ្ទះវិញទេ! លោកយាយជួយចៅផង! |
| **ជីដូនមាលា** | ៖ | អើនែ៎! ឱ្យតែបានដឹងថា នាងនៅទីនេះទៅបានហើយណ៎ា! កូនឯងទៅផ្ទះវិញចុះ! ទុកចៅឱ្យវានៅជាមួយម៉ែពីរបីថ្ងៃសិនហើយ! |
| **មាលា** | ៖ | ទេ...! ខ្ញុំអត់នៅពីរបីថ្ងៃទេ! ខ្ញុំនៅជាមួយលោកយាយលោកតារហូតហើយ! បើលោកយាយមិនឱ្យខ្ញុំនៅខ្ញុំ...! |
| **ជីដូនមាលា** | ៖ | អើ... ឈប់យំទៅ! នែ៎! នែ៎! កូនហ្អា? កូនឯងគួរតែយល់ហើយរឿងនេះណាកូន! |
| **តេជ័យ** | ៖ | ខ្ញុំពិបាកចិត្តណាស់ម៉ែ! ខ្ញុំសុំផ្ញើចៅនឹងម៉ែសិនចុះ! |
| **ជីដូនមាលា** | ៖ | អើ! ទៅចុះអ៊ីចឹងណាកូនណា! ទុកឱ្យវានៅជាមួយម៉ែហ្នឹងហើយ! |
| **តេជ័យ** | ៖ | បាទ! |

## ឈុតទី ៤

**(ពោល) លុះវេលាកន្លងដប់វស្សា នាងមាលាពេញវ័យស្អាតអស្ចារ្យ ដូចទេពធីតាចាកសួគ៌ា។**

## ឆាកទី ៤

| | | |
|---|---|---|
| **មាលា** | ៖ | ដប់ឆ្នាំមកហើយ ដែលខ្សែជីវិតកំព្រារបស់ខ្ញុំ បានទទួលការឃុំគ្រងក្នុងសំណាក់ជីតាខ្ញុំ! ថ្វីបើជីវភាពនៅទីនេះ ពុំសំបូររុងរឿងដូចជានៅផ្ទះលោកឪពុកខ្ញុំមែន ប៉ុន្តែខ្ញុំមានសេចក្ដីសុខសប្បាយគ្រប់គ្រាន់ ខុសពីកុមារភាពដែលខ្ញុំរស់នៅជាមួយម្ដាយចុងរបស់ខ្ញុំ! យាយនិងតាខ្ញុំស្រឡាញ់ខ្ញុំណាស់! ខ្ញុំក៏ស្រឡាញ់លោកយាយលោកតាខ្ញុំដែរ! (ច្រៀង) បុប្ផាក្រពុំ សាយនូវ សាយនូវគន្ធា (ពីរដង) ស្នេហាប្រាថ្នាថ្មមបី (បន្ទរៈ អ្នកផង ស្នេហាប្រាថ្នាថ្មមបី) រូបអើយរូបខ្ញុំ ពុំមាន ពុំមានខុសអ្វី (ពីរដង) ខំផ្សងរាល់ថ្ងៃ សេចក្ដីសុខសាន្ត! (និយាយ) លោកយាយស្រឡាញ់ចៅណាស់ ឃើញចៅមានរូបរាងស្អាតពេក លោកយាយពុំដែលបណ្ដោតបណ្ដោយ |

ឱ្យចៅដើរចេញទៅណាឆ្ងាយពីផ្ទះទេ! អឺ ព្រោះខ្លាចជនពាលសាមាន្យធ្វើបាប! ពេលទៅបុណ្យទានម្ដងៗ លោកយាយនិងលោកតាតែងឱ្យចៅអង្គុយក្បែរខ្លួនជានិច្ច! យី! អ្នកណាដើរចូលមកលឿនស្លេវនោះ! អូ៎ា! ខ្ញុំគេចសិន!

ចំរុង ៖ ឈប់សិនអ្នកនាង! អ្នកនាងឈប់សិន! ហេតុអីគ្រាន់តែខ្ញុំមកដល់ភ្លាម អ្នកនាងគេចទៅអ៊ីចឹងហ៎?

មាលា ៖ ទេ! ទេ! ខ្ញុំអត់គេចពួនអីទេ ប៉ុន្តែខ្ញុំត្រូវការចូលទៅក្នុងផ្ទះវិញដើម្បីធ្វើការងារទៀតតើ!

ចំរុង ៖ អូ៎! ខ្ញុំនិយាយលេងទេ! សូមអ្នកនាងកុំប្រកាន់អីណ៎ា! ប៉ុន្តែសូមអ្នកនាងអនុញ្ញាតឱ្យខ្ញុំសួរបន្តិចបានទេ?

មាលា ៖ អឺ! ខ្ញុំប្រញាប់ណាស់ ប៉ុន្តែលោកចង់សួរអី សួរឱ្យឆាប់មកចុះ!

ចំរុង ៖ សូមអ្នកនាងបង្អង់សិនណ៎ា!

មាលា ៖ ហ៊ឺស! មិនដឹងជាចង់សួរអីទេ!

ចំរុង ៖ (ច្រៀង) គេល្បីសុសសាយគ្រប់ទិសា គ្រប់ទិសា គេថានៅក្នុងនគរនេះ មានយុទ្ធជនម្នាក់ ជាអ្នកចេះស្ទាត់មានតម្រិះខាងចម្លាក់!

មាលា ៖ អូ៎! មើល៍! មានប្រសាន៍ឱ្យអស់មកមើល៍!

ចំរុង ៖ (ច្រៀង) ល្បីល្បាញរន្ទឺឮយូរហើយ ឮយូរហើយ ឱអ្នកនាងអើយ ខ្ញុំសែនស្ម័គ្រ!

មាលា ៖ សែនស្ម័គ្រយ៉ាងម៉េច?

ចំរុង ៖ (ច្រៀង) ខ្ញុំស្គាត់ពីនាយឆ្ងាយខ្លាំងណាស់ រកជាវចម្លាក់...!

មាលា ៖ អូ៎! ចង់ជាវរូបចម្លាក់? លោកនិយាយមែន ឬក៏និយាយលេង?

ចំរុង ៖ បាទ! ពិតប្រាកដមែនហើយ! (ច្រៀង) ដូច្នេះសូមនាងអាណិតប្រាប់ អាណិតប្រាប់ ជាងនោះចំណាប់ចំនួនខ្លាំង តាទេពសិលាឈ្មោះលាក់កំបាំង តើនាងស្គាល់ផ្ទះគាត់ឬទេ?

មាលា ៖ មិនជាការទាស់ខុសអីទេ!

ចំរុង ៖ បើអ្នកនាងស្គាល់ផ្ទះ សូមអ្នកនាងប្រាប់ខ្ញុំផងណ៎ា?

មាលា ៖ (ច្រៀង) អ្នកសួរប៉ះឈ្មោះជីតាខ្ញុំ ជីតាខ្ញុំ ម៉្លេះម៉ុម សូមប្រាប់ឥតរិះរេ ពេលនេះលោកតាគាត់នៅទំនេរ កុំបាច់គ្នាន់គ្នេរចូលទៅចុះ!

# ឆាកទី ៥

មាលា ៖ អឺ! លោកតាគាត់កំពុងតែធ្វើការនៅទីនោះ!

ចំរុង ៖ ខ្ញុំមិននឹកស្មានថានៅផ្ទះលោកតាទេពសិលា មានទេពកញ្ញាអ៊ីចឹងសោះ!

មាលា ៖ ហ៊ឺស! ខ្ញុំលាសិនហើយ!

ចំរុង ៖ ទេ! ទេ! អឺ...! សូមអ្នកនាងជួយជូនខ្ញុំទៅផងអ្នកនាង ព្រោះខ្ញុំពុំដែលស្គាល់គាត់សោះណ៎ា!

មាលា ៖ ហ៊ឹស! ល្មើយខ្ញុំជូនលោកទៅជួបលោកតាខ្ញុំ ព្រោះលោកជាអតិថិជនរបស់គ្រួសារខ្ញុំ!

ចំរុង ៖ បាទ! អឺ! អ៊ីចឹងនែ៎ អ្នកនាង! តើអ្នកនាងឈ្មោះអីទៅ?

មាលា ៖ លោកមកជាវរូបចម្លាក់ ឬ មកស្រង់បញ្ជីកំណើតមនុស្សនៅក្នុងភូមិនេះ?

ចំរុង ៖ បាទ! ទេ! ខ្ញុំមកសុំជាវរូបចម្លាក់បាទ!

មាលា ៖ លោកតា! លោកតា!

ទេពសិលា ៖ ហ៊ឹស! អ៊ូ! តាជាប់ដៃបង្ហើយរូបចម្លាក់នេះមួយ! ចៅ! តោះទៅហូបបាយជាមួយលោកយាយរបស់ចៅមុនទៅណ៎ា!

មាលា ៖ លោកតា! ចៅ... ចៅជូនភ្ញៀវម្នាក់មកណ៎ា!

ទេពសិលា ៖ អ៊ូ! ចុះចៅនាំគេមកពីណាមក៎?

មាលា ៖ អឺ! គាត់មកដល់ផ្ទះរបស់យើងតែម្ដង! លោក! នេះ គឺជីតាខ្ញុំដែលលោកចង់រក! អឺ! ខ្ញុំ...ខ្ញុំសូមលាសិនហើយលោក!

ចំរុង ៖ បាទ! អរគុណហើយអ្នកនាង!

ទេពសិលា ៖ អឺ! លោកចៅសុំអញ្ជើញអង្គុយទៅ! តើលោកចៅមករកខ្ញុំមានការអ្វី?

ចំរុង ៖ បាទ! ខ្ញុំជានិស្សិតម្នាក់នៅសាលាទិសាបាមោក្ខលោកតា! ខ្ញុំបានឮនូវកិត្តិសព្ទដ៏ល្បីល្បាញអំពីស្នាដៃសិល្បៈនេះ ជាយូរឆ្នាំមកហើយ ទើបតែពេលនេះ ខ្ញុំបានមកស្គាល់លោកតាណាលោកតា!

ទេពសិលា ៖ ប៉ុន្តែរូបចម្លាក់ទាំងប៉ុន្មាននៅក្នុងផ្ទះនេះ ខ្ញុំឆ្លាក់នេះគឺសូមប្រាប់ជាវ

ជូនអតិថិជន មិនមែនទុក សម្រាប់អ្នកទៅចូលទស្សនាហើយសសើរនោះទេណាលោកថៅ!

**ចំរុង** ៖ បាទ! ខ្ញុំក៏យល់ដែរក្នុងរឿងនេះ! រីឯខ្ញុំមកនេះ គឺប្រាថ្នាជាវរូបចម្លាក់របស់លោកតាហើយណាលោកតា!

**ទេពសិលា** ៖ អឺ! បើអ៊ីចឹង សូមលោកថៅដើរតាមតាមក! តាបង្ហាញឱ្យឃើញរូបចម្លាក់ទាំងអស់នេះ! ថៅមើលណ៎ា! នេះគឺរូបសិម្ពលី! នេះរូបនាគរាជ! បន្ទាប់មកនេះរូបអវតា! នេះរូបគន្ធប! នេះរូបបិសាច! នែ៎! រូបនេះតាយកថ្មភ្នំមកឆ្លាក់! ថ្មនេះបើគិតទៅទុករាប់ពាន់ឆ្នាំក៏វាអត់ខូចអត់ខាតទៅណាដែរណាថៅ!

**ចំរុង** ៖ ល្អណាស់លោកតា! រូបអស់នេះ មើលទៅរស់រវើកដូចមានជីវិតពិតណាលោកតា! ពេលនេះទើបខ្ញុំដឹងថាស្នាដៃរបស់លោកតាវិសេសវិសាល លើសពីការល្បីល្បាញរបស់កេរ្តិ៍ឈ្មោះ លោកតាទៅទៀតណ៎ាលោកតា!

**ទេពសិលា** ៖ អឺ! ប៉ុន្តែតាសូមនិយាយជាលើកទីពីរណ៎ា ថារូបចម្លាក់អស់នេះមិនមែនតាក់តែងដើម្បី រងចាំទទួលពាក្យស្ញើចសរសើរទេណ៎ា!

**ចំរុង** ៖ សូមអភ័យទោសលោកតា! តាមការពិត ខ្ញុំចង់មកជាវរូបចម្លាក់របស់លោកតា ដើម្បីយកទៅដាក់តាំងនៅក្នុងផ្ទះរបស់ខ្ញុំសិក្សានៅវត្តបឹងដែលលោកឪពុករបស់ខ្ញុំ គាត់ទើបនឹងកសាងថ្មីៗនេះ! ប៉ុន្តែដោយសារខ្ញុំស្ថិតនៅក្នុងយុវវ័យ ដូច្នេះខ្ញុំមិនពេញចិត្តនឹងរូបបិសាច រូបអារក្សអីអស់នេះទេណាលោកតា!

**ទេពសិលា** ៖ អឺ! តាយល់ហើយ! អ៊ីចឹងថៅចូលមកល្វែងខាងនេះណ៎ា!

**ចំរុង** ៖ បាទ! បាទ!

**ទេពសិលា** ៖ នេះគឺរូបទេពធីតា! នេះរូបនាងសុមាវតី មហេសីព្រះឥសូរ! នេះគឺរូបនាងនាគ មហេសីព្រះថោង! នេះរូបនាងសីតាមហេសីព្រះរាម! ហើយនេះទៀតរូបនាងផ្សោតទេព! នេះរូបនាង គង្ហីងព្រះធរណី! ហើយរូបទេវនារីផ្សេងៗទៀតក៏មានហូរហៃដែរ! ចូលដើរមើលចុះ រូបទាំងអស់នេះ បើតាមការគិតមើលទៅប្រហែលជាងសែសិប!

**ចំរុង** ៖ លោកតា! លោកតា ជាមនុស្សម្នាក់មានទេពកោសល្យសិល្បៈ

ខ្ពស់ណាស់ ព្រោះគ្រាន់តែស្រមៃតាមបទនិពន្ធរបស់រឿងនិទាននានា លោកតាអាចឆ្លាក់នូវទេពនារីម្នាក់ តម្រូវទៅតាមការពិពណ៌ក្នុងសាច់រឿងដែលមានលក្ខណៈខុសៗគ្នា ហើយមានចលនារស់រវើកគួរឱ្យស្រឡាញ់ជាទីបំផុត!

**ទេពសិលា** ៖ តើចៅចង់បានរូបចម្លាក់ណា?

**ចំរុង** ៖ រូបទេពនារីទាំងអស់នេះស្អាតណាស់ ស្នាដៃលោកតាខ្ពស់ណាស់ ប៉ុន្តែខ្ញុំអត់ស្រឡាញ់រូបណាមួយសោះ!

**ទេពសិលា** ៖ ចុះម៉េចចឹង! វាទាស់អី?

**ចំរុង** ៖ ពិតជាគ្មានទាស់! ពិតជាល្អគ្រប់ដប់! ប៉ុន្តែរូបទាំងនេះមិនដូចរូបនារីម្នាក់ដែលខ្ញុំស្រមៃទាល់តែសោះ!

**ទេពសិលា** ៖ តែផ្កាសមែន! វាទៅជាចង់បាន រូបស្រមៃឯណាឯណីទៅវិញ!

ធ្វើម៉េចឱ្យខ្ញុំដឹងថា ឯងស្រមៃចង់បានរូបនារីរបៀបណា?

**ចំរុង** ៖ លោកតា! នៅសាលាទិសាបាមោក្ខ និងនៅក្នុងព្រះរាជធានីទាំងមូលគេបានឱ្យតម្លៃថា រូបចៅនេះជាវិចិត្រករឯកក្នុងចំណោមវិចិត្រករវ័យក្មេង! ដូច្នេះប្រាំពីរថ្ងៃទៀត ចៅនឹងយករូបគំនូររបស់នារីដែលខ្ញុំស្រមៃមកជូនលោកតាឆ្លាក់! លោកតាខ្ញុំអាចគូររូបនារីហ្នឹងបានទៀត បានមួយរយមួយពាន់ដងទៀតណាលោកតា!

## ឆាកទី ៦

**ចំរុង** ៖ ហ៊ឺស! ចំជាចង្អៀតចង្អល់មែន មិនគ្រាន់តែមិនព្រមឆ្លាក់ទេ ថែមទាំងខឹងទៀត! ចៃដន្យអ្វីបានជាខ្ញុំស្រឡាញ់នាង?

**មាលា** ៖ អេៗ! លោកវិចិត្រករ!

**ចំរុង** ៖ អ្នកនាង! អ្នកនាង ខ្ញុំនឹកអ្នកនាងណាស់! នៅក្នុងរោងជាងអម្បាញ់មិញខ្ញុំខំរំពៃរកមើលអ្នកនាង ប៉ុន្តែអត់ឃើញស្រមោលសោះ!

**មាលា** ៖ យី! ផ្កាសម្លេះ ហេតុអីក៏លោកនឹកខ្ញុំ? ហេតុអីក៏លោកចង់ឃើញខ្ញុំ?

**ចំរុង** ៖ បាទ! ព្រោះខ្ញុំនឹកហើយខ្ញុំចង់ឃើញអ្នកនាងណាអ្នកនាង!

**មាលា** ៖ ហ៊ឺស! លោកអតិថិជន លោកលេបខាយនេះ លោកប្រមាថមើល

ងាយខ្ញុំហើយ ខ្ញុំទៅជម្រាបលោកតាខ្ញុំសិន!

ចំរុង ៖ ទេៗ! អ្នកនាងកុំធ្វើអ៊ីចឹងខ្ញុំសូមអង្វរ! លោកតាទេពសិលាកំពុងតែខឹងនឹងខ្ញុំ ដាច់ក្បាលដាច់កន្ទុយផង! បើអ្នកនាងពាំនាំពាក្យពុំគប្បីទៅជម្រាបគាត់ ពុំខុសពីយកប្រេងទៅចាក់លើភ្លើងទេអ្នកនាង!

មាលា ៖ ហេតុអ្វីបានជាលោកតាខ្ញុំខឹងនឹងរូបលោក?

ចំរុង ៖ ព្រោះអឺ! អឺ! នែ៎....ព្រោះ.......!

មាលា ៖ ព្រោះស្អី? .....ព្រោះស្អីទៅ?

ចំរុង ៖ ចាំខ្ញុំប្រាប់អ្នកនាង!

មាលា ៖ និយាយភ្លាមទៅ! លោកនិយាយមិនគប្បីទេអ្វី បានជាលោកតាខឹងអ៊ីចឹង?

ចំរុង ៖ (ច្រៀង) គាត់ខឹងនឹងខ្ញុំ គួររូបថៅស្រី (ពីរដង) គាត់ដៀលជេរស្តីខ្ញុំថាផ្តេសផ្តាស (បន្ទរ៖ គាត់ដៀលជេរស្តីថាខ្ញុំផ្តេសផ្តាស)!

មាលា ៖ (ច្រៀង) រឿងហ្នឹងខ្ញុំដឹង ព្រោះលបឃើញច្បាស់ (ពីរដង) ហេតុអីឥតខ្មាស លួចគួររូបគេ (បន្ទរ៖ ហេតុអីឥតខ្មាស លួចគួររូបគេ)!

ចំរុង ៖ (ច្រៀង) ប្រហែលនិស្ស័យ សាងពីបុព្វេ (ពីរដង) ឃើញរូបមាសមេ បងគួចស្នេហា!

មាលា ៖ ហ៊ឹស! លោកតាខ្ញុំថាលោកផ្តេសផ្តាស គឺពិតជាត្រឹមត្រូវណាស់ ព្រោះលោកចូលចិត្ត ប្រើពាក្យសម្តីផ្តេសផ្តាសមែនហ្នឹង!

ចំរុង ៖ បើអ្នកនាងថា ខ្ញុំផ្តេសផ្តាសនោះ ពុំខុសពីដៀលមនុស្សនៅក្នុងលោកនេះ ថាសុទ្ធតែផ្តេសផ្តាសទេ!

មាលា ៖ ទេ! ខ្ញុំមិនមែនដៀលមនុស្សទូទៅទេ! ខ្ញុំនិយាយតែចំពោះរូបលោកតែម្នាក់ប៉ុណ្ណោះ!

ចំរុង ៖ ប៉ុន្តែមនុស្សក្នុងលោកិយ អ្នកណាក៏តែងតែមានស្នេហាដែរ! បើសិនជាសេចក្តីស្នេហារបស់ខ្ញុំ ចំពោះអ្នកនាងជារឿងផ្តេសផ្តាស តើមនុស្សទាំងអស់មិនសុទ្ធតែផ្តេសផ្តាសទេអែស?

មាលា ៖ តាមការពិត លោកមិនត្រឹមតែវិចិត្រករដែឯកប៉ុណ្ណោះទេ ថែមទាំងជាអ្នកប៉ិនខាងសំនួនវោហារទៀតផង! ខ្ញុំលាហើយ!

ចំរុង ៖ ឈប់សិនអ្នកនាង! ឈប់សិន!

## ឆាកទី ៧

**មាលា** ៖ ឱ! ផ្កាំងគំនូរ! គាត់គូររូបខ្ញុំរស់រវើកដូចជាមានជីវិតពិតៗ ពុំខុសពីកំសួលចិត្តខ្ញុំដែលពុះកញ្ជ្រោលឥតឈប់ឈរនោះទេ! ហ៊ីស! កាលពីថ្ងៃដែលគាត់យកផ្ទាំងគំនូរមកនោះ ខ្ញុំបានស្ដីថាឱ្យគាត់ច្រើនណាស់ ប្រហែលជាគាត់ខឹងនឹងខ្ញុំហើយ! អឺ! ខ្ញុំចង់តែទៅនិយាយសុំទោសគាត់ ប៉ុន្តែ អឺ...! ប៉ុន្តែពុំអាចធ្វើទៅកើតព្រោះខ្លួនជាស្រី!

## ឈុតទី ៥

**(ពោល) កាលអើយកាលនោះណា រសៀលថ្ងៃមួយនាងធីតា បានចាកចេញឆ្ងាយពីគេហា ជួបជនឫស្យាពាលសាមាន្យ។**

## ឆាកទី ៨

**មាលា** ៖ ថ្ងៃនេះ ជាថ្ងៃឧបោសថសីល ខ្ញុំទៅរកកាច់ផ្កាមកថ្វាយព្រះសិន! ផ្កាក្រោក យុទ្ធាមហាហង្សរីកល្អៗម្ល៉េះទេ អឺ! ខ្ញុំមកឆ្ងាយពីភូមិបន្តិចហើយ ប៉ុន្តែផ្កាល្អៗណាស់! អឺ! កាច់ថែមមួយសន្ទុះទៀតក៏មិនទាស់អីដែរ!

**អ្នូងស្នងតាន់** ៖ អីយ៉ា! យី! នារីនេះរូបស្អាតណាស់តើ! អីយ៉ូយ! ស្អាតម្លឹងៗ អាអ្នូងមិនឱ្យរបូតទេ (សើច)!

**មាលា** ៖ កាច់ផ្កាបន្ថែមតិចទៀតចុះ!

**អ្នូងស្នងតាន់** ៖ នែ៎! នាងកាច់ផ្កាយកទៅធ្វើអីច្រើនម្ល៉េះ?

**មាលា** ៖ អឺ! ចុះអ្នកឯង! អ្នកឯងដើរចូលមករកខ្ញុំធ្វើអីហ្នឹង?

**អ្នូងស្នងតាន់** ៖ (សើច) ស្អាតដូចទេពអប្សរតាម៉ងហើយ ហ៊ីស! (ជញ្ជក់មាត់)!

**មាលា** ៖ យី! ម៉េចក៏ចាប់ដៃខ្ញុំ! លែង...លែង...! លែងដៃខ្ញុំទៅ!

**អ្នូងស្នងតាន់** ៖ នែ៎! កុំស្រែកឡូឡាណ៎ា! មកតាមបងមក បងស្រឡាញ់អូនណ៎ា!

**មាលា** ៖ ទេ...! ទេ...! អូសខ្ញុំទៅណា? លែង...! លែងខ្ញុំ...!

**អ្នូងស្នងតាន់** ៖ យើស! ឈប់ស្រែក ប្រយ័ត្នអញប្រើធម៌ក្តៅណ៎ា! ធម្មតាសត្វខ្លាកំពុងស្រេកឃ្លាន លុះចាប់បានម្រឹគហើយវាពុំដែលបណ្តោយឱ្យចំណីល្បូតពីមាត់វិញបានទេណ៎ា!

**ចំរុង** ៖ ឯងពុំមែនជាសត្វខ្លាទេ តាមការពិតឯងជាសត្វឆ្កែណា! ឆ្កែដ៏ថោក

ទាបបំផុត!

មាលា ៖ លោកចំរុងជួយខ្ញុំផង!

ចំរុង ៖ កុំភ័យអីនាង ខ្ញុំមកជួយអ្នកនាងហើយ! ឆ្កែកម្លៅឯងលែងអ្នកនាងមាលាភ្លាមទៅ!

មាលា ៖ លែងអញទៅ! លែង!

អ្លួងស្នងតាន់ ៖ ចុះបើអញមិនលែងវាយ៉ាងម៉េច?

ចំរុង ៖ បើឯងមិនលែងទេ ឯងនឹងអស់ធ្មេញទំពាបាយក្នុងថ្ងៃហ្នឹងហើយ!

មាលា ៖ លោកចំរុងជួយខ្ញុំផង!

អ្លួងស្នងតាន់ ៖ មិននឹកស្មានថា ឯងហ៊ាននិយាយពាក្យហ្នឹង ជាមួយអញសោះ! ប្រហែលជាឯងមិនទាន់ស្គាល់ឈ្មោះអញទេមើលទៅ! (ច្រៀង) អង្គអញឈ្មោះអ្លួងស្នងតាន់ គេក៏ឈ្មោះសំខាន់ល្បីពេញស្រុកហ្នឹង (ពីរដង) ហេតុអីអាធ្វើមិនដឹង ខំប្រឹងក្លាហានបង្ខូតដាក់ស្រី ទោះជាអញដើរទៅណា គេខ្លាចរអាឥតមានឃ្មើសអ្វី (ពីរដង) ...!

ចំរុង ៖ (ច្រៀង) នែ៎ជនអន្ធពាលអប្បលក្ខណ៍ អ្នកលេងកាប់ចាក់អាងចិត្តមោហា (ពីរដង) ថ្ងៃនេះអញប្រដៅអា កុំឱ្យឫស្យាកោងកាចអប្រិយ!

អ្លួងស្នងតាន់ ៖ (សើច) អ៊ំ! ជាមួយអ្លួងស្នងតាន់ស្មោះហ៎ា!

ចំរុង ៖ ឯងមិនមែនឆ្អឹងដែកស្បែកស្ពាន់ទេ!

អ្លួងស្នងតាន់ ៖ បើក្លាហានចូលម៉ោ! ចូលមក!

**(ឆាកប្រយុទ្ធ)**

អ្លួងស្នងតាន់ ៖ អូយៗៗ...!

ចំរុង ៖ យ៉ាងម៉េចឯងរាងចាលហើយឬនៅ?

អ្លួងស្នងតាន់ ៖ បាទ! បាទ! ខ្ញុំ....សុំលោកកុំធ្វើបាបខ្ញុំអីលោក!

ចំរុង ៖ យើងមិនមែនធ្វើបាបឯងទេ! គឺឯងទេជាអ្នកធ្វើបាបនារីភេទនេះ!

អ្លួងស្នងតាន់ ៖ បាទសូមលោកអភ័យទោសឱ្យខ្ញុំផងខ្ញុំខ្លាចលោកហើយ!

ចំរុង ៖ អឺ! អ្នកនាងមាលា!

មាលា ៖ ចាស៎!

ចំរុង ៖ ម៉ោះ! ខ្ញុំជូនអ្នកនាងទៅផ្ទះវិញណ៎ា!

មាលា ៖ ចាស៎!

## ឆាកទី ៩

| | | |
|---|---|---|
| **ចំរុង** | ៖ | អ្នកនាងប្រហែលជាភ័យណាស់អម្បាញ់មិញ មែនទេហ៎! |
| **មាលា** | ៖ | ចាស៎! អឺ! ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក! បើកុំតែបានលោកមកជួយទាន់ម្លេះត្រូវអាមនុស្សពាលនោះអឺ!.... សូមអភ័យទោសលោកមានដំណើរទៅណាដែរ បានជាលោកអញ្ជើញមកដល់ទីនេះ? |
| **ចំរុង** | ៖ | អឺ! ខ្ញុំមិនអាចប្រាប់បានទេ ព្រោះខ្លាចអ្នកនាងថាខ្ញុំជាមនុស្សផ្តេសផ្តាសទៀតណ៎ា! |
| **មាលា** | ៖ | អឺ! ខ្ញុំក៏មានបំណងសុំទោសលោក អំពីពាក្យសម្តីរបស់ខ្ញុំកាលថ្ងៃមុននោះដែរ! ឥឡូវនេះ ខ្ញុំឈប់និយាយថាលោកជាមនុស្សផ្តេសផ្តាសទៀតហើយ! ដូច្នេះសូមលោកប្រាប់មកមើលថាលោកអញ្ជើញមកពីណា? |
| **ចំរុង** | ៖ | តាមការពិតគឺខ្ញុំមកទីហ្នឹង! ប៉ុន្មានថ្ងៃកន្លងមកដែលខ្ញុំតែងតែយកពេលទំនេរមកលបមើលអ្នកនាង ប្រៀបដូចស្រមោលអន្ទោលតាមប្រាណអ៊ីចឹងណាអ្នកនាង! |
| **មាលា** | ៖ | លបមើលខ្ញុំ? |
| **ចំរុង** | ៖ | បាទ! |
| **មាលា** | ៖ | ហេតុអីក៏លបមើលខ្ញុំ? |
| **ចំរុង** | ៖ | ខ្ញុំពុំដឹងជាមកពីហេតុអីដែរ!ប៉ុន្តែចិត្តខ្ញុំវាចេះតែចង់ឃើញអ្នកនាង! |
| **មាលា** | ៖ | ហាស៎! ដល់ផ្ទះហើយ! សូមអញ្ជើញលោកចូលលេងសិន! |
| **ចំរុង** | ៖ | ទេ! ខ្ញុំមិនហ៊ានចូលទេអ្នកនាងមាលា ព្រោះលោកតាទេពសិលាគាត់ខឹងនឹងខ្ញុំណាស់ អឺ..! ខ្ញុំសូមលាសិនហើយណ៎ា! |

## ឆាកទី ១០

| | | |
|---|---|---|
| **មាលា** | ៖ | ពុក! អឺ...ពុក! |
| **តេជ័យ** | ៖ | អឺ! កូនទើបនឹងមកពីណាហ្នឹង? ពុកមកចាំកូនយូរហើយណ៎ា! |
| **ជីដូនមាលា** | ៖ | ចៅស្រីរបស់ជីដូនឥឡូវនេះដូចចេះដើរហើរប្លែកពីមុនណាស់! |
| **មាលា** | ៖ | ចាស៎! ចៅទើបនឹងមកពីផ្ទះបងសន ជួយរៀបផ្ទះសម្បែងគាត់! |
| **ជីដូនមាលា** | ៖ | អូហូ! ចៅ! |

| | | |
|---|---|---|
| **មាលា** | ៖ | អឺ! ព្រោះគាត់ជិតរៀបអាពាហ៍ពិពាហ៍ហើយណាលោកយាយ! |
| **ជីដូនមាលា** | ៖ | អឺ! នែ៎! ប៉ុន្មានខែកន្លងមកនេះ ចៅចេះជួយទុក្ខធុរៈអ្នកជទៃសឹងរាល់ថ្ងៃតាហ្មងហើយ! |
| **មាលា** | ៖ | អឺ! លោកយាយ! |
| **ជីដូនមាលា** | ៖ | ជីដូនមិនថាអីទេ! នែ៎! ប៉ុន្តែពុករបស់ឯងគេមកនេះគេមានការណ៎ាចៅ! |
| **មាលា** | ៖ | លោកពុកមានការអីទៅ? |
| **តេជ័យ** | ៖ | អឺ! កូនពេញរូបពេញរាងហើយណ៎ា! |
| **ជីដូនមាលា** | ៖ | មែនហើយចៅ! ចៅឯងកាន់តែពេញរូបពេញរាងហើយ! |
| **មាលា** | ៖ | ចុះមានការអីទៅពុក? |
| **តេជ័យ** | ៖ | (ច្រៀង) ដប់ឆ្នាំកន្លងផុតមកហើយ ប្រហែលកូនស្ដើយពីហិង្សា (ពីរដង) ពុកមកនាំកូនទៅគេហា បីបាច់រក្សានៅក្បែរប្រាណ! |
| **មាលា** | ៖ | ពុក! កូនមិនចង់ទៅវិញទេពុក! |
| **តេជ័យ** | ៖ | (ច្រៀង) ព្រោះពេលនេះកូនធំពេញវ័យ បើនៅទីទៃពុកពុំក្សាន្ត (ពីរដង) ដូច្នេះចូរកូនស្រីវិលថ្កានឱ្យបានជួបជុំវង្សត្រកូល! |
| **ជីដូនមាលា** | ៖ | អឺ! ត្រូវហើយចៅ ទៅនៅជាមួយឪពុកម្ដាយឯងវិញទៅណ៎ា! |
| **មាលា** | ៖ | ទេ! លោកយាយខ្ញុំមិនចង់ទៅវិញទេ! |
| **ជីដូនមាលា** | ៖ | អឺ! នែ៎! ពុកចៅឯងគេនិយាយត្រូវណាស់ បើនៅជាមួយជីដូនជីតាឯងស្រុកស្រែអ៊ីចឹងតទៅទៀត ក្រែងអនាគតរបស់ចៅវាមិនបានត្រចះត្រចង់ណាចៅ! |
| **មាលា** | ៖ | អូ! លោកតា! |
| **ទេពសិលា** | ៖ | កាលពីមុននោះឯងវានៅក្មេង រស់នៅមិនចុះសំរុងគ្នានឹងម្ដាយចុងតែឥឡូវនេះ មីងរបស់ឯងវាចាស់ចិត្តចាស់គំនិតលែងឆ្នាស់លែងឆ្មើមទៀតហើយ! ដូច្នេះគួរចៅទៅរស់នៅជាមួយនឹងឪពុកទៅណាដើម្បីកុំឱ្យញាតិគេនិន្ទាណ៎ា! ឮទេចៅ? |
| **តេជ័យ** | ៖ | មាលាកូន! |
| **មាលា** | ៖ | ចាសពុក! |
| **តេជ័យ** | ៖ | ប្រុងប្រៀបរៀបចំទៅ! ខានស្អែក ពុកឱ្យរទេះសេះមកដឹកកូនទៅផ្ទះវិញ! ពុកនឹងរៀបចំបន្ទប់មួយយ៉ាងស្អាតឱ្យកូន! |

ទេពសិលា ៖ អឺ! យាយវាឯងក៏ត្រូវជូនដំណើរចៅទៅដែរឬទេ?

ជីដូនមាលា ៖ ចាស! ចាំខ្ញុំជូនចៅទៅ ហើយទៅលេងបានពីរបីថ្ងៃ ព្រោះខានទៅលេងចន្ទីយូរដែរហើយណាតាវ៉ា!

## ឈុតទី ៦

(ពោល) នាពេលរសៀលព្រះសូរិយា មាលាស្កាត់ទៅជួបនឹងសង្សារ ដើម្បីរៀបរាប់ប្រាប់ហេតុការណ៍ ហើយបានសន្យាទាំងពីរនាក់។

## ឆាកទី ១១

មាលា ៖ (ច្រៀង) បងអើយអូននឹងត្រូវឃ្លាត លែងបានជួបទៀត ហើយប្រុសជីវ៉ា (ពីរដង) ទៅរស់ក្នុងគ្រួសារ ជាមួយបិតា នៅឯធានី (បន្ទរ៖ ជាមួយបិតា នៅឯធានី)!

ចំរុង ៖ (ច្រៀង) មិនថ្វីទេស្រស់ឆោមឆាយ យើងមិនបែកឆ្ងាយ ទេណាឆវី (ពីរដង) បងនឹងទៅរាជធានី ជួបជូននារី មិនឱ្យឃ្លាតឆ្ងាយ!

មាលា ៖ បើអ៊ីចឹងបងទៅព្រះរាជធានីដែរហ៎?

ចំរុង ៖ បងបានបញ្ចប់ការសិក្សារួចហើយអូន! ពីរបីថ្ងៃទៀត សិស្សទាំងអស់នឹងប្រារព្ធពិធីថ្វាយបង្គំលាលោកគ្រូ វិលត្រឡប់ទៅគេហដ្ឋានវិញរៀងៗខ្លួន! ដូច្នេះបងក៏ត្រូវទៅរស់នៅជាមួយឪពុកម្តាយនៅឯព្រះរាជធានីដែរណាអូនណ៎ា!

មាលា ៖ អ៊ូ! អូន! អូនមានសេចក្តីត្រេកអរណាស់បង!

## ឆាកទី ១២

(ច្រៀង) រទេះបោះពួយទៅ ដល់ទីលំនៅកល្យាណ រួមរស់ក្បែរប្រាណ សង្ឃឹមបានក្តីសុខសាន្តអឺយ។

អ្នកបម្រើ ៖ បាទ! លោកម្ចាស់ខ្ញុំដឹកអ្នកនាងមកដល់ផ្ទះហើយទាន!

តេជ័យ ៖ អឺ! ពិសីបងរបស់ឯងមកដល់ហើយ!

ពិសី ៖ ចាសពុក!

ជីដូនមាលា ៖ មាលាចុះទៅចៅ!

ពិសី ៖ លោកយាយ! ចៅសូមជម្រាបសួរ!

ជីដូនមាលា ៖ ក្រមុំឱ្យស្លូកតែម្តងពិសី! ស្អាតណាស់!

**ពិសី** ៖ បងស្អាតណាស់!

**មាលា** ៖ អូនពិសីសុខសប្បាយទេ?

**ពិសី** ៖ ចាស៎! ខ្ញុំបានសុខទេបង! ហេតុអីបងមិនដែលមកលេងសោះ អ៊ីចឹង? មកបងខ្ញុំជួយយួរហិបទុកណ៎ា!

**តេជ័យ** ៖ ម៉ែ! ទុកឱ្យកូនយួរកន្ត្រកស្លាចូល!

**ជីដូនមាលា** ៖ អឺៗៗ...អឺ!

**តេជ័យ** ៖ មាលាឡើងផ្ទះទៅកូន!

**មាលា** ៖ ចាសពុក!

**ពិសី** ៖ សូមអញ្ជើញលោកយាយ!

**មាលា** ៖ ខ្ញុំជម្រាបសួរអ្នកមីង!

**ចន្ទី** ៖ អឺ! កូនគេស្អាតណាស់ណ៎!

**តេជ័យ** ៖ ចូលក្នុងផ្ទះទៅកូន!

**មាលា** ៖ ចាសពុក!

**ចន្ទី** ៖ ហ៊ឺស! ពិសី!

**ពិសី** ៖ ចាស!

**ចន្ទី** ៖ ហ៊ឺស! អីក៏រាក់ទាក់នឹងវាខ្លាំងម្ល៉េះ? មិនឃើញវាស្អាតជាងកូនឯង ទេហ្អែ!

**ពិសី** ៖ ចុះមានទៅទាស់ខុសអីម៉ែបើបងគាត់ស្អាតជាងខ្ញុំនោះ!

**ចន្ទី** ៖ កូននេះល្ងង់មែនណ៎!

**ពិសី** ៖ ស្អីទេម៉ែ!

**តេជ័យ** ៖ មាលា!

មាលា ៖ ចាស៎ពុក!

តេជ័យ ៖ នេះជាបន្ទប់របស់កូនឯងហើយណ៎ា!

មាលា ៖ ចាស៎!

**ពិសី** ៖ បងមាលា! ពីម្សិលមិញខ្ញុំ និងអ្នកបម្រើក្នុងផ្ទះខំរៀបចំបន្ទប់នេះ ទុកឱ្យបងអស់មួយព្រឹកធំណ៎ា!

**មាលា** ៖ អឺ! អរគុណអូនពិសីច្រើនណាស់!

**ពិសី** ៖ ចាសបង!

# ឈុតទី ៧

## (ពោល) ពេលវិលត្រឡប់ដល់គេហា ទទួលនូវការបង្ខំចិត្តអឺយ។

# ឆាកទី ១៣

**ម្ដាយចំរុង** ៖ នែ៎! ចំរុង!

**ចំរុង** ៖ បាទ!

**ម្ដាយចំរុង** ៖ ម្ដាយ និងឪពុករបស់កូន បានស្ដីដណ្ដឹងគេរួចហើយណាកូន! មិនត្រូវប្រកែកទេ! (ច្រៀង) ចំរុងកូនប្រុសមាសម្ដាយ ចុះហេតុម្ដេចឡើយកូនប្រកែក ធ្វើឱ្យម៉ែតឹងទ្រូងស្ទើរបែក ព្រោះអីកូនប្លែកកែប្រែចិត្ត!

**ចំរុង** ៖ (ច្រៀង) កូនទើបត្រឡប់ពីសិក្សា លន់តួមាតាកូនអាណិតរឿងគូស្រករកុំឱ្យគិត ព្រោះឆាកជីវិតនៅវែងឆ្ងាយ!

**ម្ដាយចំរុង** ៖ (ច្រៀង) កូនអឺយកិត្តិយសយើងធំណាស់ បើកូនក្រឡាស់គួរឱ្យស្ដាយ ពុកម៉ែនឹងខ្មាសមនុស្សទាំងឡាយ ចូរបុត្រឆោមឆាយពិចារណា!

**ចំរុង** ៖ អ្នកម៉ែ! សូមអ្នកម៉ែមេត្តាកូនផង!

**ម្ដាយចំរុង** ៖ នែ៎! មិនកើតទេចំរុងកូន តែពុករបស់ឯងដឹងច្បាស់ជាគាត់ខឹងដាច់ក្បាលដាច់កន្ទុយហើយណ៎ា! ព្រោះមុនពេលដែលឯងចេញទៅសិក្សានៅសាលាទិសាបាមោក្ខ ពោលគឺកាលពីបីឆ្នាំមុន ពុក និងម៉ែបានសាកសួរចិត្តកូនពីរឿងស្ដីដណ្ដឹង នាងសុខារីកូនលោកមហាសេដ្ឋី! កាលនោះកូនយល់ព្រម ចុះហេតុយ៉ាងណា បានជាវិលត្រឡប់មកពីសិក្សាវិញ កូនស្រាប់តែប្រកែកពុំព្រមរៀបការយ៉ាងនេះ?

**ចំរុង** ៖ សូមអ្នកម៉ែអភ័យទោសឱ្យកូនផង ពេលវេលាធ្វើឱ្យចិត្តគំនិតរបស់កូនប្រែប្រួលអស់ហើយ!

**ម្ដាយចំរុង** ៖ ហ៊ឺស! ផ្ដាស! នែ៎! ឈប់និយាយទៅចំរុង! ប្រយ័ត្នដឹងដល់ឪពុករបស់កូន! នែ៎! ឥឡូវនេះជូនម៉ែទៅផ្ទះលោកសេដ្ឋីមួយភ្លែតណ៎ា!

**ចំរុង** ៖ ខ្ញុំពុំចង់ទៅទេម៉ែ!

ម្ដាយចំរុង ៖ ទោះចង់ ឬ ពុំចង់ក៏ត្រូវតែទៅដែរ!

## ឆាកទី ១៤

**(ច្រៀង) រួតរះចេញទៅ (ពីរដង) ដល់ទីលំនៅមហាសេដ្ឋី។**

**មហាសេដ្ឋីចក់៖** អ៊ូ! អ្នកជន្លងអញ្ជើញមកហើយហ្អែស?

**ម្ដាយចំរុង ៖** សុខសប្បាយជាទេលោក?

**មហាសេដ្ឋីចក់៖** បាទ (សើច)! រួចក្មួយចំរុងមកដែរ?

**ចំរុង ៖** បាទ! ខ្ញុំសូមជម្រាបសួរលោកពូ!

**មហាសេដ្ឋីចក់៖** អឺៗ! អើ! ល្អហើយក្មួយ រកកន្លែងគួរសមទៅណ៎ា! អឺ! ទើបនឹងមកពីសាលាទិសាបាមោក្ខវិញ កាន់តែស្អាតហើយសង្ហារលើសដើមតែម្ដងហើយវ៉ឺ! អឺ! សុខារីកូន!

**សុខារី ៖** ចាសពុក!

**មហាសេដ្ឋីចក់៖** អឺ! នែ៎ៗ! លោកជំទាវគាត់អញ្ជើញមកលេងណ៎ា! ចេញមកកូន!

**សុខារី ៖** ចាស៎! អ៊ូ! ជម្រាបសួរអ្នកមីង!

**ម្ដាយចំរុង ៖** អឺ! ក្មួយសុខារីដូចជាពុំសូវដើរចេញទៅណាមកណាសោះតាហ្មង!

**មហាសេដ្ឋីចក់៖** ហ៊ឺ!អ្នកជន្លងអើយ កូនខ្ញុំនេះណា វាដូចតែសំពត់នៅក្នុងផ្នត់អ៊ីចឹង!

**ម្ដាយចំរុង ៖** នែ៎! ចំរុង!

**ចំរុង ៖** បាទ!

**ម្ដាយចំរុង ៖** ម៉េចឯងមិននិយាយស្ដីអ៊ីចឹងហ៎ា?

**សុខារី ៖** ជម្រាបសួរបងចំរុង!

**មហាសេដ្ឋីចក់៖** នែ៎! រួចលោកឧត្ដមមន្ត្រី ដែលត្រូវព្រះរាជាចាត់តាំងជាទូតទៅកាន់ឧត្ដរបុរីនោះ ពុំទាន់ឃើញអញ្ជើញមកវិញទេហ្អែស ឬ យ៉ាងម៉េច?

**ម្ដាយចំរុង ៖** ចាស៎! នែ៎! ពុកវាពុំទាន់ត្រឡប់មកវិញទេលោកសេដ្ឋី! ខ្ញុំរងចាំឱ្យតែគាត់អញ្ជើញមក ដើម្បីគិតគូរពីរឿងកូនចៅយើងហ្នឹងណ៎ា!

**មហាសេដ្ឋីចក់៖** អ៊ូ! មកលោកជំទាវ អញ្ជើញចូលមកក្នុងមក!

**ម្ដាយចំរុង ៖** ចាស៎!

**មហាសេដ្ឋីចក់៖** នែ៎! ខ្ញុំមានកិច្ចត្រូវពិភាក្សាបន្ដិចណ៎ា! អញ្ជើញៗមកក្នុង!

**ម្ដាយចំរុង ៖** ចាសៗ!

មហាសេដ្ឋីចក់ៈ　អឺ! ក្មេងៗនៅលេងឯណុងសិនហើយណ៎ា!

## ឆាកទី ១៥

**មហាសេដ្ឋីចក់ៈ** នែ៎! លោកជំទាវ!

**ម្ដាយចំរុង** ៖ ចាសលោក!

**មហាសេដ្ឋីចក់ៈ** នែ៎! មើលនែ៎! មើលអ៊ូ! ព្រំយ៉ាងស្អាតៗ នែ៎! ដែលមកពីនគរឆ្ងាយៗ ខ្ញុំទើបនឹងទិញណ៎ា! ទុកសម្រាប់ឱ្យកូនយើងហ្នឹងនែ៎!

**ម្ដាយចំរុង** ៖ ចាស៎ៗ! អ៊ូ! ល្អៗណាស់លោក!

## ឆាកទី ១៦

**សុខារី** ៖ លោកចំរុង! ត្រឡប់មកពីរៀនវិញ ហាក់ដូចជាប្លែកជាងពីដើម ឬមួយនៅសាលាទិសាបាមោក្ខនោះ គេបង្រៀនមនុស្សមិនឱ្យចេះនិយាយស្ដីចឹងហ្អេស?

**ចំរុង** ៖ អ្នកនាងសុខារី! ក្នុងលោកនេះគ្មានអ្វីទៀតទាត់ទេ! រីឯចិត្តមនុស្សក៏តែងតែវិវត្តដែរ!

**សុខារី** ៖ ហាស! ថាម៉េច? អឺ! ចិត្តគំនិតវិវត្តយ៉ាងម៉េច? ខ្ញុំដូចជាមិនយល់សោះ!

**ចំរុង** ៖ សូមអភ័យទោសចុះ អ្នកនាងសុខារី! ខ្ញុំពុំអាចរៀបរាប់ឱ្យអស់សេចក្ដីនៅពេលនេះបានទេ គ្រាន់តែសុំផ្ដាំអ្នកនាងថា ទៅថ្ងៃក្រោយ ទោះបីមានរឿងហេតុបែបយ៉ាងណាក៏ដោយ ក៏សុំអ្នកនាងកុំខឹងនឹងខ្ញុំឱ្យសោះ!

**សុខារី** ៖ ខ្ញុំមិនយល់សោះ ហេតុអីបានជាលោកនិយាយបែបនេះទៅវិញ?

**ចំរុង** ៖ ថ្ងៃក្រោយអ្នកនាងគង់តែយល់ទេអ្នកនាង!

## ឈុតទី ៨

**(ពោល) ដំណាលតាមកាលសេចក្ដី អស់ទាំងនាម៉ឺនមុខមន្ត្រី ទទួលបញ្ជានាំបុត្រីចូលគាល់ចក្រីក្នុងរាជវាំង។**

## ឆាកទី ១៧

ព្រះតេជគុណ អស់លោក ជំទាវ ឃុនណាងទាំងអស់ថា ព្រះរាជពិធីចម្រើនព្រះជន្មថ្វាយព្រះអង្គម្ចាស់ តាមព្រះរាជប្បវេណីនេះ បានចប់សព្វគ្រប់ហើយ ដូច្នេះសូមព្រះតេជគុណ និងអស់លោកដែលមានកូនក្រមុំទាំងប៉ុន្មាន ហើយដែលបានទទួលព្រះ

រាជបញ្ញាឱ្យនាំមកនោះ ត្រូវនាំកូនស្រីចេញមក ហើយឱ្យអ្នកនាងទាំងអស់ឡើងមកថ្វាយព្រះពរដល់ព្រះអង្គម្ចាស់ម្តងម្នាក់ៗជាបន្តបន្ទាប់។

**(ច្រៀង) អស់នាងពិសីស្រីបង្ហាញខ្លួន អស់នាងបវរកញ្ញាកូនលោកឧកញ្ញាសព្វមុខមន្ត្រី (ពីរដង) តាក់តែង តែងកាយប្រិមប្រិយ គួរឱ្យមេត្រីគួចចិត្តស្នេហា! រាងល្វន់ដំណើរញ៉ៀងញ៉ង នាំគ្នាត្រសងឡើងគាល់ក្សត្រា (ពីរដង) ថ្វាយព្រះអឺយសព្វសាធុកាពិធីខ្មៀវខ្មារអធឹកអធម។**

**មាលា** ៖ ខ្ញុំម្ចាស់សូមថ្វាយព្រះពរ សូមព្រះអង្គម្ចាស់ទ្រង់ប្រកបតែនឹងសេចក្តីសុខ សេចក្តីចម្រើន មានព្រះជន្មាយុ យឺនយូរក្រាបទូល!

**អង្គឆ័យយ៉ា** ៖ អើ! ល្អហើយណ៎ា! នែ៎! អឺ នែ៎...! អ៊ុំ! ឈប់សិនៗ! យី! ស្អាតណាស់នែ៎! រួចនាងនេះជាកូនចៅរបស់លោកណា?

**មាលា** ៖ អឺ! ព្រះពរខ្ញុំម្ចាស់! អឺ! ឪពុករបស់ខ្ញុំម្ចាស់ឈ្មោះ តេជ័យ ក្រាបទូល!

**អង្គឆ័យយ៉ា** ៖ អ៊ុំ! កូនរបស់លោកតេជ័យហ្អី?

**មាលា** ៖ ព្រះពរ!

**ចន្ទី** ៖ ហ៊ឺស! កូនឯងឃើញទេហ៎? ព្រះអង្គម្ចាស់ ទ្រង់សព្វព្រះរាជហឫទ័យនឹងមីចង្រៃហ្នឹងហើយ! ហ៊ឺស!

**ពិសី** ៖ កូនជួយត្រេកអរនឹងបងមាលាណាម៉ែ!

**ចន្ទី** ៖ ចំជាឆ្កួតមែន! ខ្លួនឯងឡើងថ្វាយព្រះពរ គ្មានបានផលប្រយោជន៍អីសោះ ប៉ុណ្ណឹងហើយនៅជួយត្រេកអរនឹងវាទៀត!

**អង្គឆ័យយ៉ា** ៖ អ៊ុំ! នែ៎! (សើច) នែ៎! ងើបមុខឡើងនាង រួចនាងឈ្មោះស្អីដែរអ្នកនាង?

**មាលា** ៖ អឺ! ព្រះពរខ្ញុំម្ចាស់! ខ្ញុំម្ចាស់ឈ្មោះមាលាក្រាបទូល!

**អង្គឆ័យយ៉ា** ៖ អ៊ុំ! ឈ្មោះមាលា!

**មាលា** ៖ ព្រះពរ!

**អង្គឆ័យយ៉ា** ៖ ស្អាតណាស់នេះ! (ច្រៀង) បានឃើញស្រីភ្លាម រៀមគួចស្នេហាស្អាតដូចកញ្ញា ចុះចាកសួគ៌ា (ពីរដង) ល្អលើសអស់ស្រី ទូទាំងធារា អូននឹងបានជាអគ្គមហេសី!

**មាលា** ៖ ព្រះអង្គម្ចាស់ សព្វព្រះហឫទ័យខ្ញុំម្ចាស់! (ច្រៀង) បពិត្រព្រះអង្គ

ទ្រង់មានឫទ្ធី សូមព្រះភូមី មេត្តាប្រណី (ពីរដង) ដល់ខ្ញុំម្ចាស់ វ័យក្មេង ល្ងង់សព្វសេចក្ដី ពុំហ៊ានឈោងដៃ ដល់ពង្សក្សត្រា!

**អង្គផ័យយ៉ា** ៖ (ច្រៀង) អូនកុំប្រកែក នាំឱ្យរាមខ្វល់ បងស្នេហ៍និមល ពេញគាប់ចិន្ដា (ពីរដង) បានយល់ភក្ដ្រហើយ មិនឱ្យបុប្ផា ផុតពីហត្ថាយើងបានទេ! (និយាយ) កុំភ័យអីណាអូន!

**មាលា** ៖ ព្រះអង្គម្ចាស់! ខ្ញុំម្ចាស់នៅក្មេងយ៉ាងនេះ ខ្ញុំម្ចាស់មិនហ៊ានទេ! ខ្ញុំម្ចាស់ថ្វាយបង្គំលាសិនហើយក្រាបទូល!

**អង្គផ័យយ៉ា** ៖ អើៗ! ទៅចុះៗណ៎ា! នែ៎! ចាំបងទូលព្រះបិតា! អ៊ូ! ស្អាតណាស់មិនអីទេ! (សើច) សមតាំងពីដំណើរ សមតាំងពីស្រមោលតាហ្មងហើយ! (សើច)

## ឆាកទី ១៨

**(ច្រៀង) ព្រះអង្គម្ចាស់នាមផ័យយ៉ា បានទូលបិតាថាសព្វព្រះទ័យ ព្រះអង្គបញ្ជារាជមន្ត្រីឱ្យចូល ដណ្ដឹងស្រីនាងមាលា។**

**តេជ័យ** ៖ កូនមាលា! មកនេះ!

**មាលា** ៖ ចាស៎ពុក! មានការអីពុក?

**តេជ័យ** ៖ (សើច) ម៉េវ៉ា! មើលឯងជាមនុស្សស្រី និយាយប្រាប់កូនទៅ!

**ចន្ទី** ៖ ហ៊ឺស! នែ៎! លោកមន្ត្រី និងអ្នកមុខអ្នកការ ដែលមកផ្ទះយើងពីព្រឹកមិញនេះ បានប្រាប់ថាព្រះអង្គផ័យយ៉ា ទ្រង់សព្វព្រះរាជហឫទ័យលើរូបឯងហើយណ៎ា!

**តេជ័យ** ៖ (សើច) តាមការពិត ក្នុងពិធីចម្រើនព្រះជន្ម ព្រះអង្គម្ចាស់ផ័យយ៉ាឆ្នាំនេះ ព្រះករុណា ព្រះអង្គម្ចាស់ទ្រង់មានព្រះរាជបំណងជ្រើសរើសនារីឱ្យបុត្រារបស់ព្រះអង្គ ដូច្នេះហើយបានជាព្រះអង្គត្រាស់បញ្ជាឱ្យគ្រប់មន្ត្រី សេនាបតីទាំងអស់ អ្នកណាមានកូនក្រមុំទាំងប៉ុន្មានត្រូវនាំកូនទៅថ្វាយព្រះពរដល់ព្រះអង្គម្ចាស់ ឥឡូវនេះកូនមានសំណាងខ្ពស់ណាស់! រៀបចំខ្លួនទៅ ថ្ងៃស្អែកពុកនាំកូនទៅថ្វាយព្រះករុណាហើយ!

**មាលា** ៖ ទេ! ទេពុក! ហេតុអីបានជាពុកមិនសួរចិត្តកូនសិន?

**ចន្ទី** ៖ រួចម៉េចបានជាអ៊ីចឹងទៅវិញ?

តេជ័យ ៖ ហាស់! សួរចិត្ត? បានធ្វើជន្លងជាមួយស្ដេចទៅហើយ ហេតុអីពុក ចាំសួរចិត្តកូនឯងទៀត!

មាលា ៖ ទេ! កូនមិនព្រមទេពុក ទោះជាពុកសម្លាប់កូនក៏កូនពុំព្រម ស្រឡាញ់ព្រះអង្គម្ចាស់នោះដែរ!

តេជ័យ ៖ ផ្ដេសផ្ដាសមែន!

ចន្ទី ៖ យ៉ាងម៉េច? សមមុខលោកហើយ! ឃើញទេកូនស្រីសំណព្វចិត្ត របស់លោក ខ្ញុំថាកុំនាំវាទៅវាំងធ្វើអី លោកចេះតែនាំវាទៅ! ឃើញ ទេហ៎? របៀបហ្នឹង!

តេជ័យ ៖ មាលា!

មាលា ៖ ចាស៎!

តេជ័យ ៖ កូនឯងនិយាយពិត ឬមួយក៏កូនអៀនខ្មាសទេហាស់?

មាលា ៖ ទេៗ! កូនមិនអៀនខ្មាសទេ ព្រោះនេះ បញ្ហាវាសនាអនាគត របស់កូន! សូមជម្រាបពុកតាមត្រង់ទៅចុះ កូនពុំអាចទទួលយក ព្រះអង្គម្ចាស់នោះបានទេពុក!

តេជ័យ ៖ ហ៊ឺស! ពុកឆ្ងល់ណាស់!នារីទូទៅនរណាក៏គេប្រាថ្នាចង់បានជាកូន ប្រសារស្ដេចដែរ! ចុះហេតុអីបានជាកូនប្រកែក? ហ៊ឺស! ហេតុអី បានជាកូនប្រកែក?

មាលា ៖ ពុក!

តេជ័យ ៖ ម៉េចមិននិយាយម៉ោ? ហ៊ឺស!

មាលា ៖ សូមពុកអាណិតកូនផង! (ច្រៀង) លោកឪពុកមានគុណ ធ្ងន់ លើសផែនដី (បន្ទរ៖ ធ្ងន់លើសផែនដី) តែសូមប្រណីអភ័យកូន ផង (បន្ទរ៖ អភ័យកូនផង) ទោះកូនធ្វើខុស សូមពុករំលង ពេល ដែលកន្លង កូនមានសង្សារ!

តេជ័យ ៖ កូនមានសង្សារ?

មាលា ៖ ចាសពុក!

ចន្ទី ៖ ហ៊ឺស! សមមុខលោកហើយ! ព្រះម្ចាស់ថ្លៃអឺយ ខូចដល់កូនស្រីខ្ញុំ ហើយ! មីកំពូជថោកនេះ ខ្ញុំមិនសុខចិត្តទេ! ខ្ញុំមិនសុខចិត្តទេ!

តេជ័យ ៖ អូនចន្ទី! សម្រន់កំហឹងសិនទៅ!

ចន្ទី ៖ ហ៊ឺស! សុទ្ធតែមានសង្សារ!

តេជ័យ ៖ ឥឡូវនេះអញ្ជេះទៅចុះមាលា!

មាលា ៖ ចាស៎!

តេជ័យ ៖ ដើម្បីលុបលាងកំហុស ចូរកូនដកចិត្ត ឈប់ស្រឡាញ់អាសង្សារនោះទៅ! ហើយទៅរស់នៅក្នុងវាំង វាផុតកង្វល់អស់ទៅហើយ!

មាលា ៖ ទេៗ! លោកឪពុក កូនពុំអាចធ្វើបែបនេះបានទេ កូនស្រឡាញ់គាត់ណាស់! ពួកកូនពុំអាចបែកគ្នាបានទេពុក!

តេជ័យ ៖ យើស! មាលា!

មាលា ៖ ចាស៎!

តេជ័យ ៖ សង្សាររបស់ឯងនោះ វាថ្កុំថ្កើងរុងរឿងជាងព្រះរាជបុត្រស្តេចទៅទៀតហាស៎?

មាលា ៖ គាត់ពុំមានឋានៈ ថ្កុំថ្កើងរុងរឿងដូចព្រះអង្គម្ចាស់ទេ ប៉ុន្តែគាត់ជាបុរសដែលកូនស្រឡាញ់ណាពុក!

តេជ័យ ៖ កូនដឹងទេ? បើសិនជាកូនបានធ្វើជាកូនប្រសារស្តេច ពុកនឹងបានឡើងបុណ្យសក្តិធំដុំជាមិនខាន!

មាលា ៖ ពុក! លោកឪពុក ប្រាថ្នាបុណ្យសក្តិរបៀបនោះបានប្រយោជន៍អ្វី បើជាបុណ្យសក្តិដែលយកកូនក្រមុំទៅប្តូរអ៊ីចឹងនោះ! ធម្មតាស្តេចមានស្រីស្នំរាប់រយ មានមហេសីរាប់មិនអស់ ដូច្នេះវាគ្មានន័យអ្វីសម្រាប់នារីទេពុក!

តេជ័យ ៖ (ច្រៀង) អញមិនគួរអី កូនស្រីឫស្សា (ពីរដង) លួចមានសង្សារ ងប់ងល់នឹងស្នេហ៍ (បន្ទរ៖ លួចមានសង្សារ ងប់ងល់នឹងស្នេហ៍) រហូតប្រឆាំង បំណងឪម៉ែ (ពីរដង) ទុកដូចកូនឆ្កែ កាត់បោះចោលចុះ!

មាលា ៖ ពុក! ម៉េចពុកមានប្រសាសន៍ដូច្នេះ? អត់ពីម៉ែទៅ គឺកូនរស់នៅជាមួយពុក!

ចន្ទី ៖ ត្រូវហើយ បើលោកនៅតែឱបក្រសោប មីមាលាឱ្យនៅក្នុងផ្ទះទៀតនឹងខូចឈ្មោះដល់កូនស្រីរបស់យើងជាមិនខានទេ! ហ៊ឺស!

តេជ័យ ៖ មាលា!

មាលា ៖ ចាសពុក!

ចន្ទី ៖ ខ្មាសគេណាស់លោកអើយ ប្រេះទ្រូងខ្ញុំស្លាប់ឥឡូវហ្នឹងហើយខ្ញុំ!

តេជ័យ ៖ បើឯងនៅតែពុំព្រមលះបង់សង្សារឯងទេ! ចូរឯងចុះចេញពីផ្ទះអញឱ្យឆាប់ឡើង!

មាលា ៖ សូមពុក! សូមពុក អាសូរកូនផង!

តេជ័យ ៖ ហ៊ឹស! គ្មានឪពុកគ្មានកូន គ្មានអាណិតអាសូរអីទៀតទេ!

មាលា ៖ ពុកបណ្ដេញកូន?

តេជ័យ ៖ អឺ! អញពុំអាចទ្រាំទ្រនឹងកូនក្រពើវង្វេងបឹងរបៀបនេះបានទេ! ចុះពីផ្ទះអញភ្លាមទៅ! តែសំពត់អាវម៉ាចង្កេះហ្នឹងបានហើយ មិនឱ្យយកស្អីទៅជាដាច់ខាត!

មាលា ៖ កូនមិនចង់បានអ្វីទេ! ប៉ុន្តែៗកាលពីដប់មួយឆ្នាំមុន...!

តេជ័យ ៖ វាយ៉ាងម៉េច?

មាលា ៖ (យំ) អ្នកមីងចន្ទីបានបណ្ដេញកូនចេញពីទ្រនំដដែលនេះ! កូនអភ័ព្វណាស់! កូនសូមលាពុកសិនហើយ!

## ឈុតទី ៩

**(ពោល) កាលអើយកាលនោះណា អនិច្ចាវាសនាមាលា ត្រាច់រង្គត់សែនកំព្រាដល់ឆ្នេរគង្គារឈរសោកា។**

## ឆាកទី ១៩

មាលា ៖ (យំ) បើខ្ញុំមានម្ដាយដូចគេឯង ប្រហែលជាខ្ញុំមិនត្រូវខ្វាត់ព្រាត់រកទីពំនាក់គ្មានដូច្នេះទេ! (ច្រៀង) ជីវិតកំព្រា រងាឯកា (បន្ទរ៖ ហាអឺ ហាអឺង អឺយ ហាអឺ ហាអឺង អឺយ) ព្រោះគ្មានមាតា រក្សាថ្នមថៃ! ពីតូចដល់ធំ រងទុក្ខឥតល្ហែ (បន្ទរ៖ ហាអឺ ហាអឺង អឺយ ហាអឺ ហាអឺង អឺយ) មានឪពុកដែរ តែមិនប្រណី! ពេលនេះខ្លួនខ្ញុំ ទុក្ខធំលើសអ្វី (បន្ទរ៖ ហាអឺ ហាអឺង អឺយ ហាអឺ ហាអឺង អឺយ) ខ្លួនអឺយជាស្រី គ្មានឋានទ្រនំ! (និយាយ) លោកតា និងលោកយាយប្រហែលជាពុំដឹងថា ចៅត្រូវពុកបណ្ដេញចេញពីផ្ទះទេ លោកតាលោកយាយស្រលាញ់ និងអាណិតចៅណាស់ ប៉ុន្តែចៅពុំហ៊ានទៅរកលោកទាំងពីរទៀតទេ ព្រោះចៅ... ព្រោះចៅមានឈ្មោះអាក្រក់ទៅហើយ! ឱ! ទឹកស្ទឹងអឺយ អ្នកប្រឹងហូរធ្វើអ្វី បើបញ្ហាជីវិត

របស់ខ្ញុំ ដោះស្រាយពុំរួចយ៉ាងនេះ! ឱ! ជិតព្រលប់ទៅហើយ បក្សីនៅក្នុងសម្បុកនាចុងឈើ វាមានភ័ព្វសំណាងជាងខ្ញុំ ព្រោះវាមានមេរបស់វា ពាំចំណីមកបញ្ចុក ហឺ...ហឺ...!

**ចំរុង** ៖ អូនមាលា! អូនមាលា!

**មាលា** ៖ យី! អឺ! បងចំរុង បងចំរុង!

**ចំរុង** ៖ អូនមាលា! បងតាមរកអូនតាំងពីថ្ងៃត្រង់មកម្ល៉េះ ណាអូន!

**មាលា** ៖ បង! បងដឹងរឿងរបស់អូនហើយ ហ្ន៎?

**ចំរុង** ៖ បងដឹងអស់ហើយ ព្រោះជារៀងរាល់ថ្ងៃ បងតែងតែទៅលបមើលអូនពីក្រៅរបង ពុំដែលមានខានទេ! ថ្ងៃមុនចាំយូរពេកពុំឃើញសោះ បងក៏លបសាកសួរគេគ្រប់ដែលជាអ្នកបរទេះឱ្យគ្រួសារអូន ទើបបងបានដឹងថា អូនត្រូវឪពុកបណ្ដេញចេញពីផ្ទះ ព្រោះ... ព្រោះតែរឿងរបស់យើងហ្នឹងណា!

**មាលា** ៖ ទេ! សូមបងត្រឡប់ទៅវិញចុះ! អូនជាមនុស្សគ្មានផ្ទះសម្បែង គ្មានគ្រួសារទៀតទេ ហឺ! អូន សូមលាបងហើយ!

**ចំរុង** ៖ ទេ! ទេ! ទេ! តែប៉ុណ្ណេះហើយ យើងត្រូវតែប្ដូរស្លាប់រស់ជាមួយគ្នា បងមិនឱ្យអូនទៅណាទេអូន បងនាំអូនទៅផ្ទះបង ទៅជួបនឹងម្ដាយបងណាអូនណ៎ា!

## ឆាកទី ២០

**(ច្រៀង) ឱ! អ្នកម្ដាយថ្លៃ សូមអ្នកមេត្តា កូននាំ កូននាំសង្សារ មកផ្ទះយើងហើយ (បន្ទរ៖ កូននាំ កូននាំសង្សារ មកផ្ទះយើងហើយ)។**

**ម្ដាយចំរុង** ៖ នែ៎! មិនបានទេចំរុង កូនធ្វើអ៊ីចឹងម៉េចនឹងកើត ឱ្យនាងត្រឡប់ទៅវិញទៅកូន!

**ចំរុង** ៖ ម៉ែ! ឱ្យនាងទៅរស់នៅទីណា បើឪពុករបស់នាងគាត់កាត់កាលនាង ហើយបណ្ដេញនាងចុះពីផ្ទះនោះ!

**ម្ដាយចំរុង** ៖ អឺ... នាងនេះមានរូបស្អាតបាតណាស់ ឫកពាចរិយាក៏មិនទាស់ចិត្តម៉ែដែរ! ប៉ុន្តែកូនឯងមានគូដណ្ដឹង ចាំតែថ្ងៃរៀបការទៅហើយណាកូន!

**មាលា** ៖ ហ្អាស! យី! បងចំរុងមានគូដណ្ដឹងរួចទៅហើយ?

ចំរុង ៖ ពិតមែនហើយអូន! ប៉ុន្តែបងបានជម្រាបម៉ែ តាំងពីថ្ងៃទើបនឹងមកពីសាលាម្ល៉េះ ថាបងពុំរៀបការទេណាអូន!

ម្ដាយចំរុង ៖ ធ្វើអ៊ីចឹងមិនកើតទេចំរុង! កិត្តិយសគ្រួសារយើងធំណាស់កូន មិនត្រូវនិយាយបាតដៃជាខ្នងដៃទេ ម៉្យាងទៀតលោកសេដ្ឋី ចក់ មិនមែនជាមនុស្ស ដែលយើងអាចបង្អាប់បង្អោនគាត់បានស្រេចនឹងចិត្តទេណា!

ចំរុង ៖ ម៉ែដឹងទេ! អូនមាលាត្រូវឪពុកកាត់កាល ព្រោះតែរឿងស្នេហាជាមួយរូបកូន លើសពីនេះកូនបានប្ដេជ្ញាតាំងពីយូរមកហើយថា កូនយករូបនាងជាភរិយារហូតអវសានជីវិត ដូច្នេះតើកូនមានចិត្តឯណាទៀតនឹងទៅ ស្រឡាញ់នាងសុខារី កូនលោកសេដ្ឋីនោះណាម៉ែ!

ម្ដាយចំរុង ៖ ឯងជាកូនរបស់ម៉ែ ពុំទាន់បានតបស្នងសងគុណ ឪពុកម្ដាយផង កូនឯងចង់ធ្វើឱ្យកេរ្ដិ៍ឈ្មោះ របស់អ្នកមានគុណស្អុយអសោចហ្មស៎?

មាលា ៖ បងចំរុង! ដើម្បីកុំឱ្យខូចកិត្តិយស ដល់វង្សត្រកូលគ្រួសាររបស់បង! ដើម្បីកុំឱ្យកើតទុក្ខព្រួយ ព្រោះដោយសារអូន អូនបានគិតឃើញហើយ ស្នេហាពិតត្រូវចេះលះបង់! អ្នកមីងខ្ញុំជម្រាបលាសិនហើយ ហឺ! បងចំរុង អូនសូមលាបងហើយ!

ចំរុង ៖ ទេ! ទេ! មាលាអូនឈប់សិន! ម៉ែបើម៉ែពុំព្រមប្រណីដល់នាងទេ រូបកូនក៏សូមលាម៉ែដែរណាម៉ែ ព្រោះពីពេលនេះតទៅ កូនពុំអាចបែកឃ្លាតពីនាងបានទេ កូនលាហើយម៉ែ!

ម្ដាយចំរុង ៖ យី! ចំរុង! ចំរុងកូន! ឈប់សិនកូន!

ចំរុង ៖ ម៉ែ! ឃាត់កូនធ្វើអី កូនពុំអាចលះបង់អូនមាលាចោលបានទេ!

ម្ដាយចំរុង ៖ អឺ! ឥឡូវនេះ អ៊ីចេះទៅចុះ អឺ! ឱ្យនាងនៅនឹងផ្ទះយើងសិនចុះ ចាំឪពុករបស់កូនត្រឡប់មកពីឧត្ដរបុរីវិញ សឹមគិតទៀតណា! ព្រោះបើរឹងទទឹង ដាច់ខាតដូច្នេះ ម៉ែទល់ចំណោះហើយ!

ចំរុង ៖ ហ្អាស! អូនមាលា! ម៉ែយល់ព្រមហើយអូន! តោះឡើងទៅលើផ្ទះទៅអូន!

មាលា ៖ ចាស៎! ស្រេចតែបងទេ!

# ឈុតទី ១០

(ពោល) កាលអើយកាលនោះ លុះរំលងឆ្លងខែថ្មី លោកឧត្តមមន្ត្រីវិលវែដល់គេហា ភរិយារៀបរាប់ប្រាប់ហេតុការណ៍ ក្រេវក្រោធអស្ចារ្យពេកកន្លង។

# ឆាកទី ២១

**ឪពុកចំរុង** ៖ ហ៊ឺស! មិនបានដាច់ខាត!

**ចំរុង** ៖ សូមលោកឪពុកអាណិតកូនផង!

**ឪពុកចំរុង** ៖ (ច្រៀង) ឱ្យវារៀនសូត្រ រហូតពេញវ័យ ឯងត្រូវបណ្ដេញ វាចេញឆាប់រ៉ា ហើយទៅអើយរៀបការ កូនមហាសេដ្ឋី!

**ចំរុង** ៖ លោកឪពុកកូនពុំអាចធ្វើដូច្នេះកើតទេ! សូមពុកអាណិតកូនផង!

**ឪពុកចំរុង** ៖ ហ៊ឺស! ហ៊ឺស! ឪពុក ហ្អេស! ជាឧត្ដមមន្ត្រីល្បីពេញនគរ បានជាទីសព្វព្រះរាជហឫទ័យរបស់ព្រះរាជា ទៅណាក៏គេគោរពកោតខ្លាចពុកដែរ ឪពុកខំបណ្ដុះបណ្ដាលកូនឱ្យរៀនសូត្រសព្វមុខវិជ្ជាតាំងពីតូចរហូតមកដល់ប៉ុណ្ណេះ ព្រោះមានបំណង ចង់ឱ្យឯងស្នងពូជពង្សវង្សត្រកូល ឱ្យបានខ្ពង់ខ្ពស់តទៅទៀត មិនតែប៉ុណ្ណោះបានទាំងស្ដីដណ្ដឹងកូនលោកមហាសេដ្ឋី ទុកឱ្យឯងទៀតផង! ឥឡូវនេះឯងបែរជាទៅមានស្រីឯណាមកនៅលើផ្ទះទៅវិញ!

**ម្ដាយចំរុង** ៖ ពុកវា! កុំប្រឡេតពេក ឥឡូវនេះអង្ករវាដាំទៅជាបាយទៅហើយណាពុកវា!

**ឪពុកចំរុង** ៖ ហ៊្អឺស! ទោះវាទៅជាស្អីក៏ដោយ យើងមានបុណ្យសក្តិខ្ពង់ខ្ពស់ លោកមហាសេដ្ឋីមាន ទ្រព្យសម្បត្តិស្ដុកស្ដម្ភ អ្នកណាក៏ស្ងើចសរសើរដែរ ឃើញអនាគតចំរុង វានឹងបានរុងរឿងផុតគេឯង ដូច្នេះដាច់ខាតខ្ញុំមិនឱ្យវាយកនាងនេះទេ!

**មាលា** ៖ ហ្អាស! លោកឪពុក សូមលោកឪពុកអាណិតកូនផង កូនបានជាស្រឡាញ់គ្នារួចទៅហើយ សូមលោកឪពុកមេត្តាអភ័យទោសផងពុក!

**ឪពុកចំរុង** ៖ កុំមកហៅអញពុក! គ្មានពុកគ្មានកូនអីជាមួយនាងឯងទេ! នោះទ្វារហ្អស់! ឆាប់ចុះចេញ ភ្លាមទៅ!

**ចំរុង** ៖ ពុក! ឈប់សិនពុក!

**ឪពុកចំរុង** ៖ ទៅនាំគ្នាទៅ!

**មាលា** ៖ (យំ) បងចំរុង!

**ចំរុង** ៖ (ច្រៀង) សេចក្តីស្នេហាមានការបង្ខំ រុងរឿងឧត្តមក៏ពុំសុខសាន្ត
(ពីរដង) ដូច្នេះសូមពុកមេត្តាប្រោសប្រាណ ឱ្យកូនរស់បានរួបអូន
មាលា!

**ឪពុកចំរុង** ៖ មិនបានទេ! អញថាមិនបានគឺមិនបានហើយ!

**ម្តាយចំរុង** ៖ ហ៊ឺស! ពុកវាខ្ញុំពិបាកចិត្តណាស់! ពុកវាគួរតែគិតបន្តិចសិនណ៎ា!

**ឪពុកចំរុង** ៖ មិនបាច់គិត មិនបាច់គួរអីទេ! នែ៎! មីស្រីថោកទាប ចុះចេញពីផ្ទះ
អញភ្លាមទៅ!

**ចំរុង** ៖ ពុក! ពុក!

**ឪពុកចំរុង** ៖ យ៉ាងម៉េចហ្អាស!

**មាលា** ៖ (យំ) បងចំរុង! ការឈឺចាប់ខាងផ្លូវកាយ! អូនអាចទ្រាំទ្របាន
ប៉ុន្តែការឈឺចាប់ខាង ផ្លូវចិត្តគ្មានវិធីណានឹងទ្រាំទ្របានទេ! ជាង
១០ឆ្នាំមុននេះ ម្តាយចុងបណ្តេញអូនចេញពីផ្ទះ ដោយជេរថាមី
កំពូជថោក! ពីរខែមុននេះ ឪពុករបស់អូនបានបណ្តេញអូនចេញពី
ផ្ទះដោយជេរថាមីកូនថោកទាប! ឥឡូវ...ឥឡូវនេះឪពុករបស់បង
បណ្តេញអូនចុះចេញពីផ្ទះដោយជេរអូនមីស្រីថោកទាប! ពាក្យ
ថោកទាបនេះចេះតែអន្ទោលតាមរួបអូនខ្លាំងម្ល៉េះ? ខ្ញុំ! ខ្ញុំលាបង
ហើយ! ខ្ញុំលាបងហើយ!

**ចំរុង** ៖ អូនមាលា! អូនមាលា! អូនចាំបងផង! ពុក! បើពុកមិនឱ្យប្រពន្ធ
ខ្ញុំរស់នៅជាមួយទេ ខ្ញុំក៏មិននៅដែរណាពុក ខ្ញុំពុំអាចបោះបង់
ចោលនាងកើតទេពុក!

**ឪពុកចំរុង** ៖ ហ៊ឺស! ប្រពន្ធ?

**ចំរុង** ៖ បាទ!

**ឪពុកចំរុង** ៖ អ្នកណារៀបការឱ្យឯងពីអង្កាល់? ឯងចង់ទៅតាមវាហ្អេស៎?

**ចំរុង** ៖ បាទ! ខ្ញុំស៊ូលំបាកវេទនាជាមួយប្រពន្ធខ្ញុំ ហើយណាពុក!

**ឪពុកចំរុង** ៖ ល្អ ហាស! ហាស! ទុកដូចជាកាត់សាច់មួយដុំ បោះឱ្យឆ្កែស៊ីទៅ
ចុះ! ឯងទៅចុះកូន សម្លាញ់!

**ចំរុង** ៖ កូនសុំលាហើយពុក!

**ម្ដាយចំរុង** ៖ យី!

**ចំរុង** ៖ ពុកម៉ែ! កូនសូមលាហើយ!

**ម្ដាយចំរុង** ៖ ចំរុង! ចំរុងកូនម៉ែ! កូនទៅណា?

## ឈុតទី ១១

(ពោល) កាលអើយកាលនោះណា ប្ដីប្រពន្ធកម្សត់សែនខ្លោចផ្សា គ្មានទីលំនៅ គ្មានអាហារ ស្រាប់តែមាតាតាមជួយផ្ដល់។

## ឆាកទី ២២

**មាលា** ៖ (យំ) បងមិនគួរមករងទុក្ខវេទនា ជាមួយអូនដូច្នេះសោះ!

**ចំរុង** ៖ ហេតុអី អូននិយាយអ៊ីចឹង?

**មាលា** ៖ បងចំរុង!

**ចំរុង** ៖ ប្រពន្ធសម្លាញ់ នេះមិនមែនជារឿងរបស់អូនទេ! គឺជាបញ្ហាជីវិតរបស់យើងទាំងពីរនាក់ណាអូន!

**មាលា** ៖ (យំ) បើបងតស៊ូប្ដូរផ្ដាច់ជាមួយនឹងអូនដូច្នេះ ទោះជាលំបាកវេទនាយ៉ាងណា ក៏អូនសប្បាយចិត្តដែរ!

**ចំរុង** ៖ មិនអីទេអូន! បងប្ដេជ្ញាចិត្តថា ទោះជាត្រូវស៊ីឈ្នួល គេទាត់ជេរក៏ដោយ ក៏បងសុខចិត្តដែរ ឱ្យតែយើងបានរស់នៅជិតគ្នាណា!

**មាលា** ៖ ហ្អាស! យីបង! មានរទេះសេះឈប់នៅមាត់ផ្លូវនោះ ដូចជា...!

**ចំរុង** ៖ គឺជារទេះរបស់បង!

**មាលា** ៖ បង! ឪពុករបស់បងមកតាមរកយើងហើយទេដឹង? នោះ... នោះម្ដាយរបស់បង!

**ម្ដាយចំរុង** ៖ ឱ! ចំរុង! ចំរុងកូន!

**ចំរុង** ៖ ម៉ែ! ម៉ែ! អញ្ជើញទៅណាម៉ែ?

**ម្ដាយចំរុង** ៖ យី! ម៉ែតាមរកកូន ពុទ្ធោ! ពុទ្ធោអើយ! ហេតុអី? ហេតុអីក៏នាំគ្នាមកអង្គុយក្នុងខ្ទមអ្នកតា ដូចលលកញីឈ្មោលអ៊ីចឹង?

**ចំរុង** ៖ ពេលមុននេះ មានភ្លៀងកូនគ្មានកន្លែងជ្រក ក៏នាំគ្នាមកជ្រកក្នុងខ្ទមអ្នកតាណាម៉ែ!

**ម្ដាយចំរុង** ៖ កូនអើយ! ម៉ែពុំដឹងជួយឯងរបៀបណាទេ តាមការពិតជាស្ត្រីភេទ

ដូចគ្នា ម៉ែក៏មានចិត្តអាណិតមាលាណាស់ដែរ ប៉ុន្តែកូនដឹងស្រាប់ ឪពុករបស់កូន តែថាយ៉ាងម៉េច គាត់ធ្វើអ៊ីចឹងហើយ! ឥឡូវនេះ លោកមហាសេដ្ឋី ក៏កំពុងតែខឹងច្រឡោតដាក់ឪពុករបស់កូន ណាស់ដែរ! ដូច្នេះមានតែផ្លូវម៉្យាងទេ គឺ...គឺកូននាំគ្នាទៅរស់នៅ ឱ្យឆ្ងាយពីរាជធានី ក្រែងលោយូរឆ្នាំយូរខែទៅ គាត់រសាយកំហឹង ម៉ែនឹងរកមធ្យោបាយអង្វរករគាត់ណាកូន!

**មាលា** ៖ (យំ) ម៉ែ! សូមម៉ែជួយកូនផង កូនគ្មានម្ដាយបង្កើតនឹងគេទេ! ឥឡូវនេះម៉ែធ្វើល្អនឹងកូន! កូនរំភើប ត្រេកអរណាស់ម៉ែ!

**ម្ដាយចំរុង** ៖ នេះ! ប្រាក់មួយបង្វិចនេះ កូនអាចយកទៅសង់ផ្ទះសម្បែង និងធ្វើជាដើមទុនប្រកបអាជីវកម្មចិញ្ចឹមជីវិតបានហើយណាកូន!

**ចំរុង** ៖ ម៉ែ!

**ម្ដាយចំរុង** ៖ ហ៊ឹម...! ម៉ែដើរសួរគេសព្វ ចប់តែផ្លូវ ទម្រាំរកកូនឃើញ ឥឡូវនេះម៉ែត្រឡប់ទៅវិញហើយខ្លាចក្រែងពុកឯង ត្រឡប់មកពីធ្វើការវិញទាន់ ព្រោះម៉ែមកនេះអត់ឱ្យគាត់ដឹងទេណាកូន!

**មាលា** ៖ ម៉ែ! កូនសូមអរគុណម៉ែច្រើនណាស់!

**ម្ដាយចំរុង** ៖ អើ! ម៉ែទៅហើយណាមើលថែរក្សាគ្នាឱ្យមែនទែនណា ម៉ែទៅហើយកូន!

## ឆាកទី ២៣

**(ច្រៀង) រូបកូនពីរនាក់ ទទួលបានប្រាក់ អំណោយពីម្ដាយ ដោយចិត្តត្រេកអររីករាយសប្បាយ ដោះទុក្ខទៅឆ្ងាយ ដោយចិត្តប្រណី។**

**ចំរុង** ៖ យ៉ាងម៉េចទៅអូន ផ្ទះរបស់យើងទើបនឹងសង់ហើយថ្មីនេះ? តើអូនពេញចិត្តទេ?

**មាលា** ៖ ចាស! អឺ... អូនស្រឡាញ់ណាស់បង! ផ្ទះរបស់យើងនេះមិនជាធំស្កឹមស្កៃអីទេ ប៉ុន្តែទ្រុងទ្រាយ សមសួន ស្អាតសង្ហារណាស់ បើគយគន់ពីចម្ងាយមក ឃើញហាក់ដូចជា ផ្ទះនេះមានបង្កប់នូវភាពសិល្បៈអ្វីមួយ យ៉ាងអាថ៌កំបាំងដែលអូនពិបាកនឹងរកពាក្យមកនិយាយបញ្ជាក់ឱ្យច្បាស់ណាស់បង!

**ចំរុង** ៖ ហាស! ហាស! ហាស! អេ! អូនមិនមែនជានារីឆោតល្ងង់ឯ

ណា?

មាលា ៖ ដឹងស្អីទេ! បងឥឡូវចេះនិយាយបញ្ជោរអូនផងហ្ន៎? អឺ... ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ អូនសង្ឃឹមយ៉ាងកក់ក្ដៅថា គេហដ្ឋានហ្នឹង គឺជាទ្រនំជីវិតដ៏ពោរពេញទៅដោយសុភមង្គលរបស់យើងលុះត្រា ដល់ថ្ងៃស្លាប់ណាបង!

ចំរុង ៖ អូន! អូនយល់ត្រូវណាស់មាលា! (ច្រៀង) ឧត្តរបុរី ទឹកដីថ្មីសុទ្ធ តែគួរជីវិត សាកសមវាសនា អូនអើយគន់មើល ដួងចន្ទភ្លឺថ្លា ដូចដួងចិន្ដា យើងស្មោះនឹងគ្នា!

មាលា ៖ (ច្រៀង) ប៉ុន្តែអូនព្រួយ ថ្ងៃក្រោយទៅ មានពពកខ្មៅ បាំងដួងចន្ទ្រា ដូចចិត្តប្រុសបង បែកពីមាលា ហើយងាកសារ៉ា រកគូថ្មី!

ចំរុង ៖ (ច្រៀង) បើសិនពុះទ្រូង រូងបេះដូងបាន បងនឹងក្លាហាន បើកបង្ហាញស្រី! ឱ្យឃើញច្បាស់ពិត នូវចិត្តភក្តី ចូរកែវពិសី នាងកុំសង្ការ!

មាលា ៖ (ច្រៀង) គូអើយគូព្រេង អូនរ៉ែងសង្ឃឹម ជីវិតញញឹម ក្នុងផ្លូវវាសនា សូមឱ្យចិត្តបងដូចពាក្យសន្យា អូនផ្ញើជីវ៉ា រស់រូបបងហើយ!

ចំរុង ៖ ការរស់នៅ របស់អ្នកនគរឧត្តរបុរីនេះ ប្រហាក់ប្រហែលនឹងការរស់នៅរបស់មនុស្សក្នុងនគរយើងដែរ មែនទេអូន?

មាលា ៖ ហ៊ឹ! ចាស! អ្នកនគរនេះភាគច្រើនស្លូតបូត និងមានសីលធម៌គួរឱ្យចូលចិត្តណាស់!

ចំរុង ៖ បងសង្កេតឃើញថា ការរកស៊ីជំនួញជួញព្រៃ ក្នុងនគរនេះងាយស្រួលជាងនគរយើងខ្លាំងណាស់អូន!

មាលា ៖ ចាស! អឺ... យប់ជ្រៅណាស់ហើយបង ល្មមចូលសម្រាន្តហើយព្រោះស្អែកនេះបងត្រូវក្រោកពីព្រឹកព្រលឹមទៅធ្វើជំនួញផងណា!

ចំរុង ៖ មែនហើយអូន!

## ឈុតទី ១២

**(ពោល) រួមរស់សុខសាន្តបានជាងមួយវស្សា មុខរបរលូតលាស់ផ្លែផ្ការហ័សជាក់ ថ្ងៃមួយចំរុងជួបមិត្តភក្តិ នាំឱ្យចិត្តអ្នកចង់ឃ្លាតឆ្ងាយ។**

# ឆាកទី ២៤

| | | |
|---|---|---|
| មាលា | ៖ | អឺ! បងត្រឡប់មកវិញហើយហ្អេ? អូនមានរឿងអស់សំណើចមួយចង់ជម្រាបបង! |
| ចំរុង | ៖ | រឿងអីទៅអូន? |
| មាលា | ៖ | ចាស! អូនបានដឹងថាសព្វថ្ងៃនេះ អ្នកបណ្ដាជំនួញទាំងអស់គ្នានៅក្នុងក្រុងឧត្តរបុរីនេះ គេនាំគ្នាហៅបងថា នាយពាណិជ្ជក្មេង! នាយពាណិជ្ជក្មេង! |
| ចំរុង | ៖ | ហាស! ហាស! |
| មាលា | ៖ | (សើច) |
| ចំរុង | ៖ | រឿងនេះបងបានដឹងខ្លះហើយដែរ! ថ្ងៃនេះបងមានកិច្ចការសំខាន់ពិគ្រោះជាមួយអូនណា! |
| មាលា | ៖ | ហ៊ឹម...! មានការអីទៅបង សូមបងមានប្រសាសន៍មកមើល? និយាយទៅ អូនចាំស្ដាប់ណា! |
| ចំរុង | ៖ | (ច្រៀង) គេថាទៅនោះចំណេញណាស់ ទ្រព្យឡើងរហ័សជួយឱ្យសប្បាយ (ពីរដង)! |
| មាលា | ៖ | ទៅណាបង? |
| ចំរុង | ៖ | (ច្រៀង) រកស៊ីរាប់ឆ្នាំអើយហត់នឿយណាយ មិនស្មើទៅឆ្ងាយតែមួយជើង! |
| មាលា | ៖ | អឺ! បងចង់មានប្រសាសន៍ថាម៉េចហ្នឹង? បងចង់ជួញផ្លូវឆ្ងាយ? |
| ចំរុង | ៖ | មិនត្រឹមតែចង់ទេអូន! បងបានទាំងទាក់ទងជួលសំពៅរបស់គេរួចហើយណាអូន! |
| មាលា | ៖ | ហ៊ឹម...! បងជួលសំពៅរួចហើយ? |
| ចំរុង | ៖ | មែនហើយ! |
| មាលា | ៖ | ហឺស! ប្ដីសម្លាញ់! ចិត្តអូន អូនពុំចង់ឱ្យបងឃ្លាតទៅណាឆ្ងាយសោះ! ជាយូរឆ្នាំមកនេះ យើងរកស៊ីបានធូរធារណាស់ ប៉ុណ្ណេះវាសមល្មមហើយបង! ជាពិសេសបងជាវិចិត្រករគួរតែយកតម្រិះវិជ្ជាដ៏ថ្លៃថ្នូរនេះ មកប្រកបរកចិញ្ចឹមជីវិតយើងទៅណាបង! |
| ចំរុង | ៖ | បងដឹងចិត្តរបស់អូនណាស់! រូបបងក៏ពុំចង់ឃ្លាតពីអូនដែរ ប៉ុន្តែ |

បងគិតថាយើងត្រូវខំ រកស៊ីឱ្យក្លាយទៅជាអ្នកមានស្តុកស្តម្ភឆាប់រហ័ស! ដើម្បីវិលត្រឡប់ទៅនគរវិញឱ្យឪពុករបស់បង គាត់សប្បាយចិត្តទទួលស្គាល់អូន ហើយឱ្យគាត់យល់ថា ទ្រព្យសម្បត្តិវាគង់នឹងកើតក្រោយទេ ឱ្យតែគូស្វាមីភរិយាស្មោះស្ម័គ្រនឹងគ្នាណាអូនណា! ហើយរបស់អស់នេះគឺជាសុភមង្គលក្នុងគ្រួសារយើងណាអូន!

**មាលា** ៖ ប៉ុន្តែអូនព្រួយបារម្ភណាស់បង!

**ចំរុង** ៖ កុំបារម្ភអីមាលា! បើតាមពាក្យរបស់នាយសំពៅ និងមិត្តរបស់បងគេនិយាយ ទៅតែមួយខែនឹងដល់នគរសាគរភារាសហើយ! ទាំងលក់ទំនិញ ទាំងទៅទាំងមកយ៉ាងយូរណាស់បីខែ បងត្រឡប់មកដល់វិញហើយ! អូនដឹងទេ?

**មាលា** ៖ ចាស!

**ចំរុង** ៖ បងប្រមូលដើមទុនទាំងអស់នេះ! ទាំងអស់នេះដើមទុនរបស់យើងណាអូន! ទិញទំនិញសព្វសារពើដាក់បានមួយភាគបីនៃចំណុះរបស់សំពៅ! ដូច្នេះទុនរបស់យើងមិនតិចទេណាអូន!

**មាលា** ៖ បើបងគិតគូររួចទៅហើយនោះ អូនមិនដឹងជាធ្វើដូចម្តេចទេបង! ហ៊ឹម...!

## ឆាកទី ២៥

**(ច្រៀង) ដល់ថ្ងៃចេញទៅ សំពៅឱលឿនលយ លើកដៃដង្ហើយ លាពៅទៅឆ្ងាយ (បន្ទរ៖ លើកដៃដង្ហើយ លាពៅទៅឆ្ងាយ)។**

**ចំរុង** ៖ (ស្រែក) អូនមាលា! បងលាហើយ!

**មាលា** ៖ បងចំរុង!

**ចំរុង** ៖ អូនមាលា!

**មាលា** ៖ បងចំរុងទៅឱ្យបានក្តីសុខណាបង!

**ចំរុង** ៖ បងលាហើយអូន!

**(នៅលើសំពៅ)**

**ភូរិន្ទ** ៖ សំឡាញ់! ប្រពន្ធឯងស្អាតណាស់! អ៊ូ! នាងខ្ទប់មុខយំហើយ!

**ចំរុង** ៖ សំពៅចាកចេញកាន់តែឆ្ងាយ ឃើញប្រពន្ធយំនៅលើផែដូច្នេះ គ្នា

ពិបាកចិត្តណាស់សំឡាញ់ សឹងតែលោតទឹកហែលទៅវិញទេវ៊ី!

**ភូរិន្ទ** ៖ កាត់ចិត្តមួយគ្រាទៅសំឡាញ់! នែ៎! ចាំពេលទំនេរឯងនិយាយប្រាប់គ្នាអំពីប្រវត្តិស្នេហារបស់ឯងឱ្យគ្នាដឹងផងណា៎!

**ចំរុង** ៖ ភូរិន្ទសំឡាញ់! រឿងរ៉ាវស្នេហារបស់គ្នា បត់បែនវែងឆ្ងាយណាស់ ជាប្រវត្តិដ៏សែនកម្សត់នៃជីវិតរបស់មនុស្សទាំងពីរនាក់! ហ្អាស! ភូរិន្ទ ឯងដឹងទេ? មាលាប្រពន្ធរបស់គ្នា គឺជានារីអភ័ព្វម្នាក់គួរឱ្យអាណិត នាងជាភរិយាដល់ល្អគ្រប់លក្ខណៈគួរឱ្យស្រឡាញ់ណា៎!

**ភូរិន្ទ** ៖ នែ៎! ហាស់! ហាស់! កុំធ្វើមុខជូរពេកចំរុង! ឥឡូវឯងគិតពីការរកស៊ីរបស់ឯងម្តងណា!

**ចំរុង** ៖ ហ្អាស! គិតយ៉ាងម៉េចទៅភូរិន្ទ?

**ភូរិន្ទ** ៖ ចាំគ្នាប្រាប់ឯងពី របៀបជំនួញនៅសាគរភារាសណា៎! (ច្រៀង) ទំនិញមិត្តឯង មានស្នែងមានស្នក (ពីរដង) ភោគផលគ្រប់មុខ ខ្លឹមចន្ទន៍ក្រស្នា(បន្ទរ៖ ភោគផលគ្រប់មុខ ខ្លឹមចន្ទន៍ក្រស្នា) អ្នកនគរក្រៅ គេសែនត្រូវការ (ពីរដង) ទោះថ្លៃម្តេចម្តា ប្រាថ្នាចង់បាន (បន្ទរ៖ ទោះថ្លៃម្តេចម្តា ប្រាថ្នាចង់បាន) ឯងនឹងចំណេញ លើសលប់មិនខាន (ពីរដង) នឹងវិលវិញថ្កាន នាំទំនិញថ្មី!

**ចំរុង** ៖ ពេលណាយើងចំណេញ យើងទៅផ្ទះវិញ ប្រពន្ធយើងក៏សប្បាយចិត្ត ដោយសារយើងចំណេញដែរសំឡាញ់! នែ៎! ពាក្យសម្តីរបស់មិត្តធ្វើឱ្យគ្នាកាន់តែសង្ឃឹមលើមុខរបរនេះណា៎!

**ភូរិន្ទ** ៖ ត្រូវហើយចំរុង គឺឯងត្រូវចំណេញពីរលើកណា គឺទំនិញដែលយើងនាំយកទៅលក់នោះ វាចំណេញមួយសារទៅហើយ លុះត្រឡប់មកវិញយើងនាំយកកម្រាលព្រំ គ្រឿងកែវកងពិទូរ្យសូរ្យកាន្ត គ្រឿងក្រអូប និងគ្រឿងទេស យកពីនគរសាគរភារាសមកលក់វិញម្តង! ដូចមិត្តដឹងស្រាប់ហើយ ទំនិញទាំងនេះសុទ្ធតែជាទីនិយម របស់អ្នកនគរឧត្តរបុរីណាស់ណា៎!

**ចំរុង** ៖ ភូរិន្ទ! ភូរិន្ទយល់ដឹងច្រើនណាស់វ៊ី!

**ភូរិន្ទ** ៖ ដូច្នេះដូចចំរុងឯងដឹងស្រាប់ហើយថាគ្នា ជាមនុស្សកំព្រីកំព្រា គ្មាន

ក្រុមគ្រួសារ គ្មានញាតិមិត្តសាច់សារលោហិតអីនឹងគេទេ! តាំងពីចាក់ចេញពីសាលាទិសាបាមោក្ខជាមួយឯងមក គ្នាក៏បានធ្វើជាស្មៀន និងចាត់ចែងការលើសំពៅរហូតទល់សព្វថ្ងៃនេះ ជីវភាពរបស់គ្នាធូរធារគ្រប់បែបមែនទែន ប៉ុន្តែដោយគ្នា គ្មានផ្ទះសម្បែង លុយកាក់ ប្រាក់កាស ទាំងប៉ុន្មាននៅជាប់នឹងខ្លួននៅលើសំពៅតែប៉ុណ្ណោះ! នែ៎! កាលណាគ្នាមានប្រពន្ធ គ្នានឹងគិតគូររកស៊ីដោយខ្លួនឯង ដូចឯងអ៊ីចឹងណា!

**ចំរុង** ៖ ហ្អឺស! អើ...ឯងល្មមគិតគូររកប្រពន្ធកូនហើយភូរិន្ទ!

**ភូរិន្ទ** ៖ ត្រូវហើយ!

**ចំរុង** ៖ ក្រែងលោថ្ងៃក្រោយ យើងអាចធ្វើដន្លងនឹងគ្នាណ៎ា!

## ឈុតទី ១៣

(ពោល) **កាលអើយកាលនោះ លុះរំលងមួយសប្តាហ៍ សំពៅលឿនលយកណ្តាលជលសា ជួបនឹងហេតុការណ៍គ្រោះអាសន្ន។**

## ឆាកទី ២៦

**ភូរិន្ទ** ៖ ហ៊ឺម...! ស្តាប់តាមការរៀបរាប់របស់ឯង ប៉ុន្មានថ្ងៃកន្លងមកនេះគ្នានឹកអាណិតដល់មាលាប្រពន្ធឯងណាស់! ចំរុងតទៅថ្ងៃក្រោយទោះជានាង មានទាស់ខុសម្តេចម្តាក៏ឯងមិនត្រូវបោះបង់រូបនាងចោលទេណា!

**ចំរុង** ៖ ឱ! ភូរិន្ទគ្នាបានប្តេជ្ញារួចជាស្រេចមកហើយថា មួយជីវិតនេះ គ្នាពុំអាចបែកពីប្រពន្ធបានទេ ហើយគ្នានឹងអនុគ្រោះប្រោសប្រណីដល់នាងគ្រប់ពេលវេលាទាំងអស់!

**ភូរិន្ទ** ៖ ហ្អឺស! ហ្អឺស!

**ចំរុង** ៖ ភូរិន្ទ!

**ភូរិន្ទ** ៖ ហ្អាស់!

**ចំរុង** ៖ ឯងមើល មានចំណុចខ្មៅមួយនោះ លេចឡើងនៅឯជើងមេឃឯនោះ! ឯងមើល! មើល!

**ភូរិន្ទ** ៖ ហ្អឺ!

**ចំរុង** ៖ ម៉េចអ៊ីចឹងភូរិន្ទ?

**ភូរិន្ទ** ៖ គ្នាធ្លាប់ធ្វើដំណើរតាមផ្លូវនេះ ពីរបីដងហើយ! ហេតុអីបានជាមិនដែលឃើញ? តាមការពិត កោះខ្មោចនៅឆ្ងាយណាស់ ប្រហែលជាពីរថ្ងៃទៀត ទើបយើងអាចមើលឃើញ!

**ចំរុង** ៖ អេ៎! មានឈ្មោះកោះខ្មោចផង?

**ភូរិន្ទ** ៖ ហ្នឹងហើយចំរុង! កោះខ្មោចជាកោះអាថ៌កំបាំងគួរឱ្យខ្លាច អ្នកសំពៅតែងតែជៀសឆ្ងាយ មិនហ៊ានទៅជិតទេ ព្រោះគេតំណាលថាមានមនុស្សជាច្រើនដែលឡើងទៅលើកោះខ្មោច ហើយត្រូវបាត់ខ្លួនរហូត ពុំដែលមាននរណាវិលត្រឡប់វិញបានទេ!

**ចំរុង** ៖ គិតទៅនៅក្នុងសមុទ្រមានរឿងរ៉ាវប្លែកៗច្រើនណាស់!

**(សម្លេងខ្យល់បក់ខ្លាំង)**

**ចំរុង** ៖ ភូរិន្ទ! ហេតុអីក៏ចំណុចខ្មៅនោះកាន់តែរីកធំឡើងៗ យ៉ាងឆាប់រហ័សអ៊ីចឹងណ៎!

**ភូរិន្ទ** ៖ អូ! វីវរហើយសម្លាញ់!

**ចំរុង** ៖ វីវរអីទៅសម្លាញ់?

**(ខ្យល់ព្យុះនៅសមុទ្រ...)**

## ឈុតទី ១៤

**(ពោល) សំពៅត្រូវលិចលង់ក្នុងជលសា ដោយព្យុះសង្ឃរាដ៏ខ្លាំងក្លា ជីវិតក្សិណក្ស័យគួរខ្លាចផ្សា ភ័ព្វវាសនាភូរិន្ទបានរួចរស់។**

## ឆាកទី ២៧

**ភូរិន្ទ** ៖ ឱ! ធម្មជាតិអើយ! ហេតុម្ដេចបានជាកំណាចខ្លាំងម្ល៉េះ? វាសនាសំឡាញ់ខ្ញុំមិនដឹងជាយ៉ាងណាទេ? គួរឱ្យសោកស្ដាយណាស់ កណ្ដាលមហាសាគរដ៏ធំធេងយ៉ាងនេះ! (ច្រៀង) ឱ!ព្យុះព្យូមារលោកអើយ លោកទាមទារជីវិត (ពីរដង) គ្មានក្ដីអាណិត ឱ! ណាលោកអើយស្រណោះមេត្តា (បន្ទរះ គ្មានក្ដីអាណិត ឱណាលោកអើយស្រណោះមេត្តា) ឈើមួយបន្ទះ លោកអើយលោក ខ្ញុំតោងស្រវ៉ា (ពីរដង) ខ្ញុំផ្ញើ វាសនាលោកអើយ ដល់ចុងអើយបញ្ចប់! (និយាយ) ខ្ញុំសូមផ្ញើសង្ខារដល់ចុងបញ្ចប់ហើយ! បីយប់បីថ្ងៃមកហើយដែលខ្ញុំតោងបន្ទះក្ដារ បណ្ដែតខ្លួនតាមទឹករលក សំពៅត្រូវ

បែកធ្លុះធ្លាយលិចបាត់ទៅក្នុងមហាសាគរ! ចំរុង! ចំរុងមិត្តខ្ញុំ និងអ្នកឯទៀត ប្រហែលជាត្រូវស្លាប់អស់ហើយ! គ្មានអ្នកណានៅរស់មួយទេ! ចំណែកខ្ញុំ! ខ្ញុំក៏គ្មានសង្ឃឹមអ្វីដែរ! ឱ! បន្ទះក្តារដ៏មានគុណនេះ! គ្រាន់តែជួយបន្លាយជីវិតរបស់ខ្ញុំមួយ រយៈប៉ុណ្ណោះ! ហ្អាស! ហ្អាស! មានសំពៅពីចម្ងាយ អូ! ជួយផង! ជួយផង! ជួយខ្ញុំផង! ឱ! សំពៅគេងាកតម្រង់មក ហើយ ជួយផង! ជួយខ្ញុំផង! ជួយផង!

**អ្នកសំពៅ** ៖ មានមនុស្សលង់ទឹកទេតើ? លើកឡើងមកកុំអាលសួរនាំគ្នាអីហ្អាស! គ្នាកំពុងតែហេវហត់ ណាស់!

## ឆាកទី ២៨

**(ច្រៀង) ច្រើនថ្ងៃឱកន្លង ឱស្រីម៉ុមសាអ៊ុំបងអើយ ឆ្លងដល់អើយដីគោក លោកអើយ ឆ្លងដល់អើយដីគោក ប្រញាប់កាត់រក ឱស្រីម៉ុមសាអ៊ុំបងអើយ ផ្ទះមិត្តអើយសំឡាញ់ លោកអើយផ្ទះមិត្តអើយសំឡាញ់។**

**ភូរិន្ទ** ៖ នែ៎! ជម្រាបសួរអ្នកស្រី!

**មាលា** ៖ ឱ! ចាស៎! ជម្រាបសួរលោក លោកមានការអីហ្នឹង?

**ភូរិន្ទ** ៖ បាទ! នែ៎! ខ្ញុំឈ្មោះភូរិន្ទ ជាមិត្តរបស់ចំរុងណ៎ា!

**មាលា** ៖ ហ្អាស! គឺលោកភូរិន្ទទេតើ! អឺ! លោកត្រឡប់មកវិញហើយហ្មេ៎?

**ភូរិន្ទ** ៖ បាទ! ខ្ញុំទើបមកដល់កំពង់ផែក្រុងឧត្តរបុរីនេះ ពាក់កណ្តាលអធ្រាត្រយប់មិញនេះ!

**មាលា** ៖ យី! ចុះឯណាចំរុង! បងចំរុងប្តីខ្ញុំនោះ?

**ភូរិន្ទ** ៖ ហ្អាស! ចំរុងមិនទាន់មកដល់ផ្ទះហ្អេស?

**មាលា** ៖ ចាស! មិនទាន់ឃើញមកទេ! ហេតុអីបានលោកត្រឡប់មកវិញមុនកាលកំណត់ ហើយបាត់ប្តីខ្ញុំ គាត់នៅឯណា? យី! ហេតុអីបានជាលោកស្រក់ទឹកភ្នែកអ៊ីចឹង?

**ភូរិន្ទ** ៖ ចំរុង!

**មាលា** ៖ មានរឿងអី? មានរឿងអីទៅលោក?

**ភូរិន្ទ** ៖ ចំរុងមិត្តខ្ញុំប្រហែលជាលែងវិលត្រឡប់វិញហើយអ្នកស្រី!

**មាលា** ៖ យី! ហេតុអី? ហេតុអីលោកមានប្រសាសន៍ដូច្នេះ?

ភូរិន្ទ ៖ រឿងនេះ ពុំអាចលាក់បំបាំងបានទេ ប៉ុន្តែសូមអ្នកស្រីទប់ចិត្តថ្លើមឱ្យមែនទែនណា៎!

មាលា ៖ ខ្ញុំបារម្ភណាស់! រឿងបែបណាទៅ? មានរឿងបែបណាទៅលោក?

ភូរិន្ទ ៖ អ្នកស្រី! ពេលដែលសំពៅយើង ចាកចេញទៅមួយសប្តាហ៍ ស្រាប់តែជួបនឹងខ្យល់ព្យុះកំបុតត្បូង បណ្តាលឱ្យវាត្រូវលិចលង់ក្នុងមហាសាគរ!

មាលា ៖ (យំ) ពុទ្ធោ! សំពៅលិច! សំពៅលិច!

ភូរិន្ទ ៖ ដូចអ្នកស្រីជ្រាបស្រាប់ហើយ!

មាលា ៖ (យំ) បងចំរុង!

ភូរិន្ទ ៖ នូវទំហំវិនាសកម្ម នៅគ្រោះថ្នាក់បែបនេះ បណ្តាលព្យុះ និងក្រោមកម្លាំងរលកប៉ុនៗកូនភ្នំនោះ គ្មាននរណាអាចជួយនរណាបានទេ!

មាលា ៖ (យំ) បងចំរុង!

ភូរិន្ទ ៖ ហើយគេស្ទើរតែនឹងមិនជឿថា អាចមានជីវិតរស់នៅបានផង ជាភ័ព្វសំណាងល្អ ខ្ញុំស្រវាបាន ក្តារបន្ទះវែងក៏ជួយស្រង់ខ្ញុំឡើង! ដូច្នេះវាសនាចំរុង និងអ្នកឯទៀតពិបាកនឹងស្មានណាស់! ប៉ុន្តែខ្ញុំយល់ថា បើសិនជា ចំរុងជួបចៃដន្យល្អបែបណាមួយ ដែលអាចជួយគេបានរស់នោះ ម្ល៉េះពេលវេលាប៉ុណ្ណេះគេអាចមកដល់ឧត្តរបុរីនេះដែរ!

មាលា ៖ (យំ) ប្តីខ្ញុំ! ប្តីខ្ញុំប្រហែលជាស្លាប់នៅក្នុងសមុទ្រទៅហើយ ព្រះអើយ! ជួយខ្ញុំផង! ខ្ញុំពិបាកចិត្តណាស់! លោកភូរិន្ទ! ហេតុអីក៏លោកមិនជួយប្តីខ្ញុំផង?

ភូរិន្ទ ៖ ចំរ៉ុងមិនដឹងជាយ៉ាងណាទេ... មុននឹងស្លាប់មិនដឹងជាវេទនាយ៉ាងណាកណ្តាលមហាសាគរដ៏ធំធេងយ៉ាងនេះ?

មាលា ៖ (ច្រៀង) ស្រងេះស្រងោច អាណោចឱអភ័ព្វ (ពីរដង) ស្វាមី ស្វាមីឧត្តម ម្ចាស់ជីវិត (បន្ទរ៖ ស្វាមី ស្វាមីឧត្តម ម្ចាស់ជីវិត) អួលណែនឱរ៉ាខ្លោចផ្សាឱអាណិត (ពីរដង) រស់ផុត រស់ផុតជីវិត វេទនាយ៉ាងណា (បន្ទរ៖ រស់ផុត រស់ផុតជីវិត វេទនាយ៉ាងណា) រូបបងស្លាប់

ទៅ អូននៅឱឯកា (ពីរដង) ចង់ក្ស័យ ចង់ក្ស័យសង្ខារ រួមគ្នាទៅ អឺយ! (និយាយ) បងអឺយបង! សូមបងយកអូនទៅផង!

**ភូរិន្ទ** ៖ កាត់ចិត្តកាត់ថ្លើមពីគាត់ទៅអ្នកស្រី! កាត់ចិត្តទៅ គ្មាននរណាអាចជួយនរណាបានទេ!

**មាលា** ៖ (យំ) បង! លោកភូរិន្ទ! លោកភូរិន្ទជួយខ្ញុំផង! ប្ដីសំឡាញ់ចិត្តអូន! បងអឺយតើបងវេទនាយ៉ាងណា? សូមបង! សូមបងមកយកអូនទៅផង!

**ភូរិន្ទ** ៖ ហ្អាស! អ្នកស្រី! អ្នកស្រី! យី! អ្នកស្រីសន្លប់ទៅហើយ! បងប្អូន! បងប្អូនជួយអ្នកស្រី! បងប្អូនជួយអ្នកស្រីមាលាផង!

**អ្នកជិតខាង** ៖ ខ្យល់គទេដឹងក្អួយ? ក្អួយខ្យល់គទេអីក្អួយ?

**ភូរិន្ទ** ៖ គាត់សន្លប់ព្រោះរន្ធត់ចិត្តពេក!

**អ្នកជិតខាង** ៖ អូ! នាំគ្នាសែងលើផ្ទះទៅ! អ៊ូ! ត្រជាក់ល្អូកនេះ!

## ឆាកទី ២៩

**(ច្រៀង) គួរឱ្យអាណិត រាប់អាននិស្ស័យ ឱកន្លង កន្លងអើយយូរថ្ងៃ ទើបបានធូរស្បើយ (បន្ទរ៖ ឱកន្លង កន្លងអឺយយូរថ្ងៃ ទើបបានធូរស្បើយ)។**

**មាលា** ៖ ហ្អាស! ខ្ញុំសូមអរគុណនឹងអ្នកមីង និងអូនពិណនារី ដែលបានទៅជួយកំដរថែជម្ងឺរបស់ខ្ញុំបានរហូតដល់ជាសះស្បើយនេះ!

**អ្នកមីង** ៖ ក្អួយជាមែន! តែវាមិនទាន់មានកម្លាំងកំហែងណាក្អួយណា! សាច់នៅស្លេកស្លាំងនៅឡើយទេ!

**ពិណនារី** ៖ អឺ! កុំព្រួយអីអ្នកបង ខ្ញុំពុំទាន់ទៅណាចោលអ្នកបងទេណ៎ា!

**ភូរិន្ទ** ៖ ខ្ញុំត្រេកអរណាស់បានឃើញអ្នកស្រីជាសះស្បើយយ៉ាងនេះណ៎ា!

**អ្នកមីង** ៖ នែ៎!នាងមាលា! ពេលនាងសន្លប់សន្លិន បានក្អួយប្រុសនេះហើយដែលជាអ្នករត់រកថ្នាំសង្កូវ រកគ្រូហ្មទាំងយប់ទាំងថ្ងៃណាក្អួយ!

**មាលា** ៖ អូ! ខ្ញុំសូមអរគុណលោកភូរិន្ទដែលបានជួយខ្ញុំ!

**ភូរិន្ទ** ៖ ហ៊ឺស! អ្នកស្រីមិនត្រូវពោលពាក្យបែបនេះទេ ព្រោះចំរុង និងខ្ញុំគឺជាមិត្តយ៉ាងស្និទស្នាលជាទីបំផុត! ដូច្នេះការជួយព្យាបាល ជួយសង្គ្រោះដល់រូបអ្នកស្រីគឺជាភារៈរបស់ខ្ញុំសុទ្ធសាធ!

**មាលា** ៖ អឺ! លោកប្រហែលជាពុំទាន់បានទៅដល់ស្រុកភូមិ ជួបជុំគ្រួសារ

ទេមើលទៅ?

**ភូរិន្ទ** ៖ ហ្អឹស!

**មាលា** ៖ អឺ! ឥឡូវនេះ ខ្ញុំបានជាហើយ ដូច្នេះគួរតែលោកអញ្ជើញទៅស្រុកភូមិចុះណ៎ា!

**ភូរិន្ទ** ៖ ហឺ! ជម្រាបតាមត្រង់ទៅចុះណាអ្នកស្រី រូបខ្ញុំជាមនុស្សកំព្រាតាំងពីក្មេង គ្មានឪពុកម្ដាយ គ្មានក្រុមគ្រួសារអីនឹងគេទេ ក្រោយពីចេញពីសាលាទិសាបាមោក្ខ ខ្ញុំបានទៅធ្វើការឱ្យនាយសំពៅរហូតអត់ទាន់មានគិតគូរដល់ប្រពន្ធកូនទេ! ដូច្នេះពេលនេះអត់ពីចំរុងទៅ ខ្ញុំបានសម្រេចចិត្តហើយថា ត្រូវរស់នៅក្នុងក្រុងឧត្តរបុរីនេះហើយ!

**មាលា** ៖ អ៊ីចឹង?

**ភូរិន្ទ** ៖ ដើម្បីបានជួយមើលការខុសត្រូវ ដល់អ្នកស្រីពីចម្ងាយផង ព្រោះអ្នកស្រីគ្មានបងប្អូន និងក្រុមគ្រួសារនៅក្នុងនគរនេះដែរ!

**អ្នកមីង** ៖ អើ! ក្មួយនិយាយគិតដូច្នេះ ក៏ជាការប្រសើរដែរណ៎ា!

**ភូរិន្ទ** ៖ នៅក្នុងក្រុងនេះ មានរោងជាងធ្វើទេះធំមួយ ខ្ញុំបានទៅទាក់ទងក្រុមជាងទាំងនោះ ដើម្បីសុំរកស៊ីជាមួយគេ រួចជាស្រេចហើយ រីឯកន្លែងសំណាក់អាស្រ័យ គឺអារាមដែលនៅជាយក្រុងមាត់សមុទ្រ!

**មាលា** ៖ បើលោករស់នៅក្នុងក្រុងនេះដែរ ខ្ញុំបានកក់ក្ដៅមួយផ្នែក ព្រោះចង់ឱ្យលោកជួយក្នុងការស្រាវជ្រាវរកប្ដីរបស់ខ្ញុំ!

**ភូរិន្ទ** ៖ មិនអីទេ!

**មាលា** ៖ (យំ) ក្រែងលោ គាត់មានភ័ព្វវាសនា អាចនៅរស់រានមានជីវិតបាន! ប៉ុន្តែ! ប៉ុន្តែក្ដីសង្ឃឹមវាស្ថិតនៅក្នុង ការស្រមៃក្នុងចិត្តតែប៉ុណ្ណោះ!

**ភូរិន្ទ** ៖ ចាំខ្ញុំជួយរកណា!

**ពិណនារី** ៖ ឱ! អ្នកបង កុំយំប្រយ័ត្នធ្លាក់ខ្លួនឈឺទៀតណា!

**មាលា** ៖ (យំ)!

## ឈុតទី ១៥

(ពោល) ពេលវេលាកន្លងផុតមួយឆ្នាំ មាលារស់នៅចិត្តរងកម្ម ប្រមាត់បេះដូង ដូចប្រេះស្រាំ ទន្ទឹងរងចាំមើលផ្លូវប្ដី។

## ឆាកទី ៣០

មាលា ៖ (ច្រៀង) អូនរវែងទន្ទឹង អឺងអឺយ ឱណាបងអើយ និងរីតខ្លោចផ្សា អឺយ (ពីរដង) ព្រោះអី ព្រោះអី អើយវាសនា អឺងអឺយ ឱណាបងអើយ គ្មានត្រាប្រណី (បន្ទរ៖ ព្រោះអី ព្រោះអី អើយវាសនា អឺងអឺយ ឱណាបងអើយ គ្មានត្រាប្រណី) គួរស្នេហ៍កំសត់ អឺងអឺយ ឱណាលោកអើយ អឺយប្រវត្តិថ្មីអឺយ (ពីរដង) កម្មកាច កម្មកាចអើយអប្រិយ អឺងអឺយ ឱណាលោកអើយ ប្រល័យប្ដីខ្ញុំ (បន្ទរ៖ កម្មកាច កម្មកាចអើយអប្រិយ អឺងអឺយ ឱណាលោកអើយ ប្រល័យប្ដីខ្ញុំ)! (និយាយទាំងយំ) បងចំរុង អូននឹកបងណាស់ មិនគួរណាបងអាយុខ្លីអ៊ីចឹងសោះ... បងចំរុងដួងចិត្តអូន មិនគួរបងត្រូវស្លាប់ក្នុងមហាសាគរទាំងវ័យក្មេងអ៊ីចឹងសោះ មិនខុសពីក្បូនរសាត់កណ្ដាលសមុទ្រនោះទេ!

ភូរិន្ទ ៖ អ្នកស្រី...!

មាលា ៖ អូ! លោកភូរិន្ទទេតើ!

ភូរិន្ទ ៖ បាទ!

មាលា ៖ សូមអញ្ជើញឡើងមក! ក្រែងថ្ងៃមុនលោកបានសន្យានឹងខ្ញុំថា ឈប់ហៅខ្ញុំអ្នកស្រីៗ ហើយអ្ហែស?

ភូរិន្ទ ៖ អ៊ុំ បាទ! (សើច) សូមអភ័យទោសឱ្យខ្ញុំផងមាលា មកពីទម្លាប់ចាស់ធ្វើឱ្យខ្ញុំភ្លេចពាក្យសន្យាណា! នេះនែ៎! ខ្ញុំយករបស់របរទាំងនេះមកផ្ញើមាលា! នេះក្រណាត់ព្រែ ហើយនេះគ្រឿងសំអាង! ម៉េចមាលាពេញចិត្តទេ?

មាលា ៖ ស្លាប់ហើយបងភូរិន្ទ បងខិតខំធ្វើការនៅក្នុងរោងជាងរទេះ យ៉ាងហត់នឿយជារៀងរាល់ថ្ងៃ!

ភូរិន្ទ ៖ មិនអីទេ!

មាលា ៖ ដូច្នេះគួរតែបងសន្សំប្រាក់កាស ទុកបង្ការទៅថ្ងៃអនាគតរបស់បង

ទៅ! ហេតុអីបានជាបងចេះតែព្យាយាមទិញវត្ថុប្រណិតៗមកផ្ញើខ្ញុំយ៉ាងនេះ?

ភូរិន្ទ ៖ មាលា! ខ្ញុំដឹងណាស់នូវការខ្វះខាត និងការលំបាកក្នុងជីវភាពសព្វថ្ងៃរបស់មាលាចាប់តាំងពីបាត់រូបចំរុងទៅ! ដូច្នេះហើយបានជាខ្ញុំខំព្យាយាមជួយផ្គត់ផ្គង់មាលាតាមលទ្ធភាពរបស់ខ្ញុំ! ម្យ៉ាងទៀតកម្រៃដែលខ្ញុំរកបានប្រចាំថ្ងៃ វាធន់ល្មមនឹងឱ្យខ្ញុំចិញ្ចឹមជីវិតបានដោយសុខស្រួលដែរ សូមកុំបារម្ភអីណា!

មាលា ៖ (ដកដង្ហើមធំ) និយាយលាក់បាំងអី តាំងពីអត់ពីប្ដីខ្ញុំទៅបើកុំតែមានរូបលោករស់នៅក្នុងក្រុងនេះដែរ ម្ល៉េះសម ខ្ញុំមិនដឹងជាលំបាកវេទនាយ៉ាងណាទេ ព្រោះមាសប្រាក់ទាំងប៉ុន្មាន ប្ដីរបស់ខ្ញុំប្រមែប្រមូលទិញទំនិញសព្វសាររពើដាក់សំពៅអស់រលីង សព្វថ្ងៃនេះខ្ញុំសល់តែសំបកផ្ទះតែប៉ុណ្ណោះ ខ្ញុំចង់ទៅប្រកបរបររកស៊ីនឹងគេដែរ ប៉ុន្តែគ្មានដើមទុនអ្វីនឹងគេ!

ភូរិន្ទ ៖ (និយាយកាត់មាលា) ប៉ុន្តែបើភូរិន្ទនៅរស់ ភូរិន្ទមិនឱ្យមាលាលំបាកវេទនាពេកទេ ព្រោះខ្ញុំអាណិតមាលាណាស់! ខ្ញុំនឹកឃើញរឿងមួយហើយ!

មាលា ៖ រឿងអីទៅលោក?

ភូរិន្ទ ៖ នែ៎! បួនប្រាំថ្ងៃទៀត មានពិធីបុណ្យមួយយ៉ាងអធឹកអធមណាស់នៅក្នុងក្រុងឧត្តរបុរីយើងនេះ!

មាលា ៖ ពិធីបុណ្យ?

ភូរិន្ទ ៖ ក្នុងពិធីនោះមានកន្លែងកំសាន្តគ្រប់ប្រភេទ តាំងពីប្រណាំងរទេះប្រណាំងដំរីជាដើម! ដូច្នេះដើម្បីឱ្យបានលម្ហែការសោកសៅដ៏ត្រាំត្រែងក្នុងចិត្តអស់រយៈមួយឆ្នាំមកនោះ! មាលា!

មាលា ៖ ចាស៎!

ភូរិន្ទ ៖ គួរតែ ទៅលេងកំសាន្ត នឹងគេផងទៅ! ហើយរូបខ្ញុំក៏ចូលរួមប្រណាំងរទេះជាមួយនឹងគេដែរណ៎ា!

មាលា ៖ អ្ហា! លោកប្រណាំងនឹងគេដែរ?

ភូរិន្ទ ៖ បាទ! (សើច) ខ្ញុំកំពុងតែសំរឹតសំរាំងរទេះ និងថែបំប៉នគោមួយនឹម ដោយផ្ទាល់ដៃ ដើម្បីត្រៀមលក្ខណៈប្រកួតប្រជែងណ៎ា!

មាលា ៖ អ៊ូ! ប្រហែលជាសប្បាយណាស់ហើយមើលទៅ?

ភូរិន្ទ ៖ គួរតែទៅកំសាន្តលេង នៅក្នុងពិធីបុណ្យនោះទៅណា?

មាលា ៖ ចាស៎! ខ្ញុំនឹងទៅមើលបងប្រណាំងនឹងគេដែរហើយណា!

## ឆាកទី ៣១

(ច្រៀង) បុណ្យធំអស្ចារ្យ ខៀវខ្ចារពេកក្រៃ (ពីរដង) ហ្វូងមនុស្សប្រុសស្រី ណែនណាន់តាន់តាប់ (ពីរដង)។

(សម្លេងប្រណាំងរទេះ សម្លេងមនុស្សខៀវខ្ចារ)

ពិណនារី ៖ បងមាលា មនុស្សច្រើនណាស់ តែបងហាក់ដូចជាមិនសប្បាយចិត្តទៀត?

មាលា ៖ (ដកដង្ហើមធំ) ពិណនារី! ឃើញទិដ្ឋភាពអ៊ូអែខៀវខ្ចារបែបនេះ បងតែងតែនឹកដល់ប្ដីរបស់បង! បើសិនជាគាត់នៅរស់ និងបានដើរកំសាន្តជាមួយបងនៅទីនេះ មិនដឹងជាសប្បាយរីករាយយ៉ាងណាទេ?

ពិណនារី ៖ កុំគិតដល់រឿងខ្លោចផ្សាទៀតបង! តោះយើងដើរទៅមើលតវ៉ាន់យូរស្តេកស្ដាករបស់អ្នកភូមិវិញម្ដង!

មាលា ៖ ទេ! បងមិនចង់ទៅឯណាទេ! បងនៅចាំមើលក្បួនប្រណាំងរទេះ ព្រោះបងភូរិន្ទក៏ចូលរួមប្រណាំងនឹងគេដែរណ៎ា!

ពិណនារី ៖ យី! នោះបង បងភូរិន្ទគាត់ប្រណាំងរទេះមកហើយ!

គណៈកម្មការ៖ នែ៎! សូមបងប្អូនទាំងអស់គ្នា ជៀសចេញពីផ្លូវលំឱ្យអស់ឱ្យឆាប់ឡើង ព្រោះអីរទេះប្រណាំងជិតមកដល់ទីផ្ដាច់ព្រ័តនេះហើយណ៎ា! អ្នកលេខមួយមកដល់ហើយ ជៀសឆ្ងាយ! ជយោអ្នកលេខមួយមកដល់ហើយ!

ពិណនារី ៖ បងមាលា! ហ្ន៎ លោកភូរិន្ទឈ្នះបានលេខមួយហើយណ៎ា!

មាលា ៖ អ៎! អូនពិណនារី បងជួយត្រេកអរគាត់ច្រើនណាស់!

ពិណនារី ៖ គាត់ប្រាកដជាបាន ប្រាក់រង្វាន់ច្រើនហើយណ៎ា! ព្រោះការប្រណាំងនេះ គេសុទ្ធតែភ្នាល់ដាក់ប្រាក់ណាបង!

មាលា ៖ អ៊ីចឹង? អ៊ូ! បងមានសេចក្ដីត្រេកកអរណាស់អ៊ីចឹង!

ពិណនារី ៖ នោះមកហើយតើហ្ន៎! យី! រាងដូចសង្ហារហ្មងណាបងហ្ន៎?

# ឈុតទី ១៦
# ឆាកទី ៣២

**មាលា** ៖ តាមការពិត បងមិនមែនទៅសប្បាយនឹងបុណ្យនេះប៉ុន្មានទេ! គឺបងមកនេះ គ្រាន់តែចង់មើល លោកភូរិន្ទប្រណាំងរទេះតែប៉ុណ្ណោះ!

**ពិណនារី** ៖ ហ៊ឹម...! អ៊ីចឹងទេតើ បានតែការប្រណាំងរទេះចប់ បងបបួលខ្ញុំត្រឡប់ទៅផ្ទះភ្លាម! អឺ...! បងមានឃើញទេលោកភូរិន្ទ ចេះរបៀបប្រើរទេះស្ទាត់ពូកែណាស់ណ៎ា!

**មាលា** ៖ លោកភូរិន្ទជាមិត្តរៀនសាលាទិសាបាមោក្ខ ជាមួយនឹងប្ដីរបស់បងណ៎ា!

**ពិណនារី** ៖ អូ! អ៊ីចឹងហ្ន៎ោះ?

**មាលា** ៖ អ្នកដែលបានបញ្ចប់ការសិក្សានៅសាលាទិសាបាមោក្ខ មិនមែនជាមនុស្សធម្មតាទេ បងចំរុងតំណាលថា កាលនៅរៀនជាមួយគ្នាគាត់ពូកែខាងគូរ ឯលោកភូរិន្ទពូកែខាងឆ្លាក់ឈើ! គឺជំនាញម៉្យាងម្នាក់!

**ពិណនារី** ៖ លោកភូរិន្ទពូកែខាងឆ្លាក់ឈើអ៊ីចឹង បានជាសព្វថ្ងៃនេះ រទេះដែលចេញពីរោងជាងរបស់គាត់ ត្រូវគេទទួលស្គាល់ កោតសសើរ ហើយលក់ដាច់ជាងគេណាបង!

**មាលា** ៖ (មាលាសើច) យី! ម៉េចក៏រទេះនោះ? នែ៎! ពិណនារី!

**ពិណនារី** ៖ ចាស៎! បង!

**មាលា** ៖ ម៉េចក៏រទេះនោះ មកឈប់នៅទទឹងផ្លូវយើងអ៊ីចឹងហ្ន៎?

**ពិណនារី** ៖ រទេះនេះបរពីណាហ្ន៎?

**កូនចៅពណ្ណារិទ្ធ**៖ កុំឆ្ងល់អីស្រីស្រស់! រទេះនេះរងចាំទទួលយករូបអ្នកនាងណ៎ា!

**ពិណនារី** ៖ យីម៉េចអ៊ីចឹងបងមាលា?

**មាលា** ៖ នែ៎! អស់លោកជាអ្នកណា បានជាពួនស្ទាក់នៅ...នៅក្នុងគុម្ពោធ...យ៉ាងនេះ?

**ពិណនារី** ៖ បងមាលា មិនស្រួលឡើយ!

**មាលា** ៖ អូនពិណនារី! បងពិតជាភ័យណាស់ធ្វើម៉េចទៅ?

| | | |
|---|---|---|
| **កូនចៅពណ្ណារិទ្ធ** | ៖ | ពួកយើង ជាអ្នកមកចាំហែហមរូបនាង ហើយនិងលោកនាយត្រឡប់ទៅបស្ចឹមបុរីវិញ! មិនថាអ៊ីចឹងអស់លោក? (សើចព្រមគ្នា) |
| **មាលា** | ៖ | ពិណនារី! |
| **ពិណនារី** | ៖ | ចាស៎ បង! |
| **មាលា** | ៖ | មិនស្រួលទេយើងត្រឡប់ទៅក្រោយវិញ! |
| **ពិណនារី** | ៖ | ចាស៎! |
| **កូនចៅពណ្ណារិទ្ធ** | ៖ | ស្អាតម្លឹងៗបានជាលោកនាយស្រឡាញ់! ឃើញហ្អេះ? |
| **មាលា** | ៖ | តោះ! នែ៎ យើងត្រឡប់ទៅក្រោយវិញ ពិណនារី! |
| **កូនចៅពណ្ណារិទ្ធ** | ៖ | ទៅណាក៏មិនបានដែរ ក្រៅពីឡើងជិះរទេះ ជាមួយលោកនាយយើង! |
| **មាលា** | ៖ | ទេ...ទេ! អស់លោក... អស់លោក ប្រុងធ្វើបាបស្ត្រីភេទអ៊ីចឹងអ្ហែស៎? |
| **ពណ្ណារិទ្ធ** | ៖ | បងមិនធ្វើបាបអូនទេ តែបងមកនាំអូនទៅស្រុករបស់បង! ឡើងមកដួងចិត្តបង ឡើងមក! |
| **កូនចៅពណ្ណារិទ្ធ** | ៖ | (សើច) ឡើងទៅ...ឡើងទៅ កុំប្រកែកអី អត់ប្រយោជន៍ទេ! |
| **មាលា** | ៖ | អាថោកទាប! |
| **ពណ្ណារិទ្ធ** | ៖ | (សើច) កាលណាទៅដល់កន្លែងរបស់បង ពាក្យត្មេះតិះដៀលរបស់អូន វាក្លាយជាពាក្យស្នេហាផ្អែមដូចទឹកឃ្មុំវិញហើយ! |
| **មាលា** | ៖ | ជៀសផ្លូវខ្ញុំ! |
| **ពណ្ណារិទ្ធ** | ៖ | អាគ្រាក់! |
| **អាគ្រាក់** | ៖ | បាទទាន! |
| **ពណ្ណារិទ្ធ** | ៖ | ចាប់វាដាក់រទេះភ្លាមទៅ កុំឱ្យយូរការណ៎ា! |
| **ពិណនារី** | ៖ | នែ៎! ពួកឯងយកគាត់ទៅណា? |
| **កូនចៅពណ្ណារិទ្ធ** | ៖ | ឡើងទៅជាមួយលោកនាយទៅស្រីល្អ! |
| **មាលា** | ៖ | លែង... លែងអញទៅ...លែង ជួយផង...! |
| **ពិណនារី** | ៖ | ពួកឯងក៏ឃោរឃៅម្ល៉េះ? |
| **មាលា** | ៖ | ជួយខ្ញុំផង... |
| **ភូរិន្ទ** | ៖ | ឈប់សិន! អស់លោក! |
| **ពណ្ណារិទ្ធ** | ៖ | ហ៊ឹស! មានការអីអ្ហែស៎? |

| | | |
|---|---|---|
| **មាលា** | ៖ | បងភូរិន្ទជួយខ្ញុំផង! |
| **ពិណនារី** | ៖ | លោកភូរិន្ទជួយខ្ញុំ និងបងមាលាផង! |
| **ភូរិន្ទ** | ៖ | អស់លោកប្រើកម្លាំងបាយ ចាប់ស្រីទាំងថ្ងៃក្រឡែតអ៊ីចឹងដូចជាមិនល្អមើលសោះ! |
| **ពណ្ណារិទ្ធ** | ៖ | ហ៊ឹស! ក្នុងការប្រកួតប្រណាំងអម្បាញ់មិញនេះ រទេះរបស់លោកឈ្នះគេជាប់លេខមួយ ដូច្នេះប្រហែលជាលោកភ្លើតភ្លើននឹងជ័យជំនះពេកហើយ បានជាហ៊ានលូកដៃក្នុងរឿងរបស់យើងណ៎ា! ប្រាប់យកបុណ្យទៅចុះ ពណ្ណារិទ្ធយើងនេះ ជាន់ស្ទើរក្រឡាប់ផែនដីនៅបស្ចិមបុរីអស់រយៈដប់ឆ្នាំមកហើយណ៎ា! |
| **ភូរិន្ទ** | ៖ | ទោះលោកជាស្អីក៏ដោយ ពេលនេះដាច់ខាតក៏ត្រូវតែលែងមាលាវិញភ្លាម! |
| **ពណ្ណារិទ្ធ** | ៖ | នារីនេះមានទាក់ទងអីជាមួយនឹងលោក បានជាលោកឈឺឆ្អាលម្ល៉េះ? |
| **ភូរិន្ទ** | ៖ | នាងជាប្រពន្ធរបស់យើង! លុះត្រាឯងកន្លងខ្មោចយើងសិន ទើបអាចធ្វើបាបប្រពន្ធយើងបានណ៎ា! |
| **កូនចៅពណ្ណារិទ្ធ** | ៖ | ជ្រុលប៉ុណ្ណេះទៅហើយ ទោះជាប្រពន្ធវាក៏ដោយ កុំទៅគិតចៅហ្វាយ! ម៉េចៗ ទុកឱ្យអាគ្រាក់ចាត់ការវា! |
| **ពណ្ណារិទ្ធ** | ៖ | អ៊ឹម! អានេះវាជាមនុស្សម្នាក់ ដែលគេទទួលស្គាល់វាពេញទីក្រុងឧត្តរបុរីនេះ ថាជាជាងរទេះចំណាន និងជាជាងចម្លាក់ឈើដែលមានទេព្យកោសល្យខ្ពស់បំផុត! លើសពីនេះ ក្នុងការប្រកួតប្រណាំងរទេះ មានរទេះរាប់រយពីគ្រប់ស្រុក គ្រប់នគរជិតឆ្ងាយរួមតែត្រូវចាញ់វាទាំងអស់ ដូច្នេះវាកំពុងតែមានកិត្តិយសសម្បើមណាស់ បើយើងចាប់ប្រពន្ធរបស់វា ក៏មុខជាពុំអាចចេញពីឧត្តរបុរីនេះបានដែរវ្ហឺ! |
| **ភូរិន្ទ** | ៖ | យ៉ាងម៉េចអស់លោកព្រមលែងប្រពន្ធយើង ឬមិនលែង? |
| **ពណ្ណារិទ្ធ** | ៖ | (សើច) លោកភូរិន្ទ ឱ្យខ្ញុំសូមអភ័យទោសទៅចុះ ព្រោះខ្ញុំពុំបានស្គាល់ថាអ្នកស្រីនេះ ជាភរិយារបស់លោក! ពួកអាដែង លែងដៃអ្នកស្រីភ្លាមទៅ! |
| **ពិណនារី** | ៖ | មកបងមាលា យើងឆាប់ចុះទៅណ៎ា! |

ពណ្ណារិទ្ធ ៖ អ្នកស្រីខ្ញុំសូមអភ័យទោសណ៎ា! លោកភូរិន្ទថ្ងៃក្រោយបើមានការប្រណាំងរទេះទៀត ខ្ញុំសូមជួបលោកជាថ្មី! ទៅពួកយើង...!

មាលា ៖ បងភូរិន្ទ ខ្ញុំ...ខ្ញុំសូមអរគុណ!

ភូរិន្ទ ៖ នាំគ្នាឡើងរទេះមកមាលា! ខ្ញុំជូនទៅផ្ទះវិញ!

មាលា ៖ ចា៎!

## ឆាកទី ៣៣

ភូរិន្ទ ៖ នែ៎! នេះបង្វិចប្រាក់ សូមមាលាយកទៅថែរក្សាទុកចុះណ៎ា!

មាលា ៖ គឺប្រាក់រង្វាន់ប្រណាំងរទេះមែនទេ?

ភូរិន្ទ ៖ ត្រូវហើយ!

មាលា ៖ អឺ! ហេតុអ្វីបានជាលោកឱ្យខ្ញុំទុក?

ភូរិន្ទ ៖ ប្រាក់កាសជាវត្ថុដែលមនុស្សអាចក៏បានទេ!

ពិណនារី ៖ លោកភូរិន្ទ! នែ៎! ឈប់រទេះបន្តិចទៅ! ឱ្យខ្ញុំសូមចូលទៅលុបលាងខ្លួនក្នុងព្រៃនេះសិនណ៎ា! ព្រោះអម្បាញ់មិញ ពួកអាអ្នកលេងអស់នោះ វាចាប់ខ្ញុំអូសដួលច្រងាប់ច្រងិលប្រឡាក់ដីស្រមកពេញទាំងខ្លួនតែម្តងហើយនែក៎!

ភូរិន្ទ ៖ មិនអីទេពិណនារី! ចុះទៅលុបលាងចុះណាខ្ញុំនៅចាំណ៎ា!

ពិណនារី ៖ ចា៎!

ភូរិន្ទ ៖ ការចរចារបស់ខ្ញុំ ជាមួយនឹងពួកអ្នកលេងអម្បាញ់មិញ ប្រហែលជា... ប្រហែលជាធ្វើឱ្យមាលាខឹងហើយមើលទៅ? ខ្ញុំសូមអភ័យទោសណ៎ា!

មាលា ៖ យី! បងភូរិន្ទសង្គ្រោះខ្ញុំ ហេតុអីបានជាខ្ញុំត្រូវខឹងនឹងបងទៅវិញ?

ភូរិន្ទ ៖ ព្រោះខ្ញុំ...ព្រោះខ្ញុំ បានប្រាប់វាថា មាលាជាប្រពន្ធរបស់ខ្ញុំ!

មាលា ៖ ខ្ញុំបានយល់ខ្លះដែរ ថាបងនិយាយដូច្នេះព្រោះចង់សង្កត់ធ្ងន់ ដើម្បីកុំឱ្យពួកវាប្រឆាំងទៀត!

ភូរិន្ទ ៖ ត្រូវហើយមាលា! បើមិនកុហកថាជាប្រពន្ធទេ ជួនកាលវាពុំព្រមបញ្ឈប់សកម្មភាពយ៉ាងថោកទាបរបស់វាងាយៗទេ!

មាលា ៖ បងវាងវៃទាន់ពេលវេលាណាស់!

ភូរិន្ទ ៖ ប៉ុន្តែ...ប៉ុន្តែ ខ្ញុំចង់... មាលាខ្ញុំសូមនិយាយបន្តិចបានទេ?

មាលា ៖ ហេតុអីបងហាក់ដូចជាញញើតញញើមម្ល៉េះ?

ភូរិន្ទ ៖ នែ៎! ខ្ញុំ...ខ្ញុំចង់ឱ្យពាក្យថាប្រពន្ធនោះក្លាយទៅជាការពិត!

មាលា ៖ យី! ចង់ឱ្យក្លាយទៅជាការពិត?

ភូរិន្ទ ៖ ប្រាកដហើយមាលា!

មាលា ៖ ម៉េចបានជាទៅអ៊ីចឹងទៅវិញ? ហ៊ឺម! ខ្ញុំដូចជាមិនយល់ចិត្តបងសោះ?

ភូរិន្ទ ៖ (ច្រៀង) សព្វថ្ងៃមាលារស់នៅឯកោ ពួកចោរអន្ធពាលវាហ៊ានប្រមាថ (ពីរដង) សមនឹងអ្នកមានរូបឆោមល្អស្អាត ជាទីសង្វាតនៃជនឫស្យា! ខ្ញុំសែនខ្លោចចិត្ត អាណិតអ្នកថ្លៃ ខ្ញុំនឹកស្រមៃគួចចិត្តប្រាថ្នា (ពីរដង) ចង់បានជាគូ តែងផ្គាប់ជីវា ភក្តីស្នេហាលុះត្រាអវសាន!

មាលា ៖ (ច្រៀង) រូបអូនមេម៉ាយ ចំណាយពាក្យញាតិ ព្រោះប្ដីចាកឃ្លាតរហូតក្ស័យប្រាណ (ពីរដង) ក្រែងពុំសាកសមនឹងប្រុសកល្យាណគួរតែរាប់អានគ្នាដូចធម្មតា!

ភូរិន្ទ ៖ សេចក្ដីស្នេហារបស់មនុស្សជាតិ ពុំត្រូវខណ្ឌញែក ភាពក្រមុំ ឬមេម៉ាយនោះទេមាលា!

មាលា ៖ ប៉ុន្តែ...ប៉ុន្តែ ខ្ញុំនឹកប្ដីខ្ញុំណាស់!

ភូរិន្ទ ៖ ជាងមួយឆ្នាំកន្លងមកហើយ ពេលវេលាវែងអន្លាយនេះ បានបញ្ជាក់ឱ្យដឹងថាចំរុងមិត្តរបស់ខ្ញុំ ច្បាស់ជាត្រូវស្លាប់ក្នុងសមុទ្រទៅហើយ! បើពុំនោះសោត គេច្បាស់ជាត្រឡប់មកផ្ទះវិញជាមិនខានទេ!

មាលា ៖ ត្រង់នេះហើយដែលខ្ញុំចេះតែនឹកខ្លោចផ្សាដល់រូបគាត់!

ភូរិន្ទ ៖ មនុស្សដែលស្លាប់ទៅហើយ ពុំអាចរស់វិញបានទេ! បើមាលាចង់ឱ្យវិញ្ញាណក្ខន្ធរបស់ចំរុងបានសេចក្ដីសុខស្ងប់រំងាប់នោះ មាលាត្រូវតែចេះទុកដាក់ខ្លួន ឱ្យមានជីវិតភ្លឺស្វាងដូចគេឯង មិនត្រូវបណ្ដែតបណ្ដោយ ឱ្យខ្លួនតែលតោលកំព្រីកំព្រាឯកោយ៉ាងនេះទេណា៎!

មាលា ៖ បងមានប្រសាន៍នេះត្រូវណាស់! និយាយលាក់បាំងអី តាំងពី

យើញអត្តចរិតរបស់បងនៅគ្រាដំបូង អូនទទួលស្គាល់ថាបងជាមនុស្សចិត្តល្អ ថ្លៃថ្នូរគួរគោរពរាប់អានណាស់ ហើយការជួយឈឺឆ្អាលដោះទុកធុរៈ និងជួយឧបត្ថម្ភរបស់បងចំពោះរូបខ្ញុំជាងមួយឆ្នាំមកនេះ បានធ្វើឱ្យខ្ញុំមានការកក់ក្តៅ ហើយមានចិត្តអាណិតបងបន្តិច ម្តងៗដោយមិនដឹងខ្លួន!

ភូរិន្ទ ៖ បើដូច្នេះមែន ខ្ញុំត្រេកអរណាស់មាលា!

## ឆាកទី ៣៤

(សម្លេងភ្លេងបាយខុនចងដៃ)

ចាស់ទុំ ៖ សូមចៅទាំងពីរ កាន់ដៃគ្នាជាស្វាមីភរិយា ដល់ចាស់ព្រឹទ្ធចាស់ព្រេងណាចៅ!

ពិណនារី ៖ សូមឱ្យបងទាំងពីរ បានប្រកបតែនឹងសេចក្តីសុខ ហើយ...ហើយខ្ញុំនឹងបានក្ងួយពរណា!

## ឈុតទី ១៧

(ពោល) បន្ទាប់ពីពិធីតាមប្រពៃណី មាលារស់នៅសាងស្នេហ៍ថ្មី ជាមួយភូរិន្ទជាស្វាមី ស្មោះស្មគ្រ័ភក្តីគ្រប់វេលា។

## ឆាកទី ៣៥

មាលា ៖ អ៎! បង...បងត្រឡប់មកវិញហើយអ្ហេស៎?

ភូរិន្ទ ៖ បងមកវិញហើយអូន! មើលនែ៎! នេះស្អីនែក៎?

មាលា ៖ ហាក៎! កូនរទេះ? កូនរទេះនេះស្អាតវិចិត្រ មានរាងរៅសមសួនដូចរទេះធំពិតៗ! អូននឹងដាក់តាំងវាលើតុថ្លើមថ្មតូចនៅក្នុងបន្ទប់ទទួលភ្ញៀវណាបង?

ភូរិន្ទ ៖ អូនចេះរៀបចំបន្ទប់ណាស់!

មាលា ៖ បងប៉ិនប្រសប់ មានការព្យាយាមណាស់ ទើបធ្វើកូនរទេះនេះបានល្អអ៊ីចឹង!

ភូរិន្ទ ៖ តើអូនដឹងទេថា ហេតុអីបានជាបង ធ្វើកូនរទេះមកតាំងនៅក្នុងផ្ទះយើង?

មាលា ៖ ធ្វើម៉េចនឹងអូនដឹង! តើពីហេតុអីទៅបានជាបងធ្វើអ៊ីចឹង?

ភូរិន្ទ ៖ បងនឹកគុណវាណ៎ា! ព្រោះបងបានប្រាក់កាស មករៀបអាពាហ៍

ពិពាហ៍ជាមួយនឹងអូនយ៉ាងអធឹកធអមនេះ ក៏ដោយសារប្រណាំង
រទេះឈ្នះដែរណ៎ា!

មាលា ៖ គំនិតបងវែងឆ្ងាយណាស់!

## ឈុតទី ១៨

(ពោល) ថ្លែងបន្តរឿងស្វាមីភរិយា រួមរស់នឹងគ្នាជិតមួយឆ្នាំ មាលាមានផ្ទៃពោះឆ្លង ខែប្រាំ ភូរិន្ទថៃទាំថ្នាក់ថ្នមក្រៃ។

## ឆាកទី ៣៦

ភូរិន្ទ ៖ (ច្រៀង) បងទៅធ្វើការ ជីវ៉ាអូនថែខ្លួន ឱណាអូនអើយថែខ្លួន (ពីរដង) ការពារមាំមួន ស្ងួនទាំងចំណី (បន្ទរ៖ ការពារមាំមួន ស្ងួនទាំងចំណី) កុំឱ្យប៉ះពាល់ ដល់បុត្រក្នុងផ្ទៃ ឱណាអូនអើយក្នុងផ្ទៃ (ពីរដង) ការធូន់ស្រាលក្តី ស្រីទុកឱ្យបង (បន្ទរ៖ ការធ្ងន់ស្រាលក្តី ស្រីទុកឱ្យបង)!

មាលា ៖ (ច្រៀង) សូមបងទៅចុះ អ្នកប្រុសកុំសៅហ្មង ឱណាបងអើយសៅហ្មង (ពីរដង) អូនយល់បំណង ថ្លៃថ្លើមជីវិត (បន្ទរ៖ អូនយល់បំណង ថ្លៃថ្លើមជីវិត) អនាគតយើង សុភមង្គលពិត ឱណាបងអើយមង្គលពិត (ពីរដង) ភ្លឺលែងងងឹត លុះគ្រាអវសាន!

ភូរិន្ទ ៖ ថ្ងៃមុនបងមកដល់ អូនបុកអង្ករ! ចូរអូនឈប់ធ្វើកិច្ចការហ្នឹងទៅណ៎ា! ចាំបងមកវិញណ៎ា?

មាលា ៖ ចាស៎! មិនអីទេបង ថ្ងៃក្រោយអូននឹងពឹងពាក់អ្នកជិតខាង ឱ្យគាត់ជួយធ្វើអូនម្តងណ៎ា?

ភូរិន្ទ ៖ ត្រូវហើយអូន! ព្រោះអូនមានផ្ទៃពោះកាន់តែធំហើយ! នែ៎! នៅតែបួនខែទៀត យើងនឹងបានឃើញមុខកូនយើងហើយណ៎ា!

មាលា ៖ អ៊ើ...នែ៎...បងស្រឡាញ់កូនប្រុស ឬ ស្រីអ្ហ៎ះ?

ភូរិន្ទ ៖ ទោះប្រុសក៏ដោយ ស្រីក៏ដោយក៏បងស្រឡាញ់វាទាំងអស់ ព្រោះវាជាសាច់ឈាមរបស់យើង! វាជាចំណងដៃស្នេហារបស់យើងណាអូន!

មាលា ៖ បងប្រសប់រកពាក្យមកនិយាយឱ្យអូនសប្បាយចិត្តណាស់!

ភូរិន្ទ ៖ អ៊ីចឹងបងទៅធ្វើការហើយណ៎ា!

មាលា ៖ ចាស៎ បង!

ភូរិន្ទ ៖ បងលាហើយណាអូន!

មាលា ៖ ចាំ!

## ឆាកទី ៣៧

(ច្រៀង) ជីវិតបត់បែន បញ្ហាម៉ឺនសែន មានគ្រប់ប្រការ ទោះស្មានមិនដល់ ខ្វាយខ្វល់ពេកណា អួលណែនឱរ៉ា ខ្លោចផ្សាអាល័យ។

(សម្លេងឆ្កែព្រុស និងគោះទ្វារ)

មាលា ៖ យី! អ្នកណាហ្នឹង? អ្នកណា?

ចំរុង ៖ គឺអូនមាលាមែនទេ?

មាលា ៖ ចាស៎!

ចំរុង ៖ បងណាអូន! បើកទ្វារឱ្យបងផងអូន?

មាលា ៖ បង... បង...! យី! បងនៅរស់ទេ! ប្តីសំឡាញ់អីយ! បង...! (យំ)

ចំរុង ៖ អូនសុខសប្បាយទេអ្វី? ឱ្យបងសុំឱបអូនឱ្យអស់ចិត្តសិន! បងនឹកអូនណាស់!

មាលា ៖ (យំ) ប្តីសំឡាញ់អីយ! ខ្ញុំស្មានថាបងស្លាប់ទៅហើយ! អូនកើតទុក្ខណាស់! ហេតុអីគេថាបង...គេថាបង លេចសំពៅ? បងចំរុង...!

ចំរុង ៖ សំពៅលេចមែន ហើយក្នុងចំណោម មនុស្សមួយសំពៅនោះ ប្រហែលជាមានតែរូបបងមួយទេ ដែលមានភ័ព្វវាសនាអាចនៅរស់រានមានជីវិត! ឈប់យំទៅអូន...!

មាលា ៖ (យំ) បង...! អូន... ព្រោះអូនត្រេកអរពេក! រឿងដែលអស់សង្ឃឹមទៅហើយនោះ បែរជាក្លាយទៅជាមានភ័ព្វវាសនាទៅវិញ! ប្តីសំឡាញ់និយាយប្រាប់អូនមើល... ហេតុអ្វីបានជា...បានជាបងនៅរស់ ប៉ុន្តែ...ប៉ុន្តែពេលវេលាកន្លងផុតទៅពីរឆ្នាំ... ទើបបងត្រឡប់មកផ្ទះវិញអ៊ីចឹង? ហេតុអ្វីក៏បងមិនមកតាំងពីយូរណាស់ហើយ? បង...!

ចំរុង ៖ អង្គុយលើភ្លៅបងមកអូន! ចាំបង រៀបរាប់រឿងកំសត់របស់បងប្រាប់អូនឱ្យដឹងណ៎ា!

មាលា ៖ (យំ) ប្តីសំឡាញ់ចិត្តអូន! តើមានរឿងអីទៅ សូមបងនិយាយមកមើល!

ចំរុង ៖ (ច្រៀង) សំពៅជួបមហាព្យុះសង្ឃរា នាវាត្រូវលេចទៅក្នុងជលស័យ លង់ក្នុងសមុទ្របងស្លុតក្រៃ នឹកថាត្រូវក្ស័យសូន្យសង្ខារ (បន្ទរ៖ ហា អឺ អឹង អឺយ ហា អឺ អឹង អឺយ) ឈើខ្លះអណ្តែតតាមរលក ប្រហែលមកពីភ័ព្វវាសនា ឱ្យបងប្រទះប៉ះឈើក្តារ ស្រវាតោងជាប់បណ្តែតកាយ (បន្ទរ៖ ហា អឺ អឹង អឺយ ហា អឺ អឹង អឺយ) ហែវហាត់អត់បាយក្រហាយទឹក ភ្លឹតភ្លឹកវិញ្ញាណសែនខ្វល់ខ្វាយ រសាត់អណ្តែតជាយូរថ្ងៃ ចៃដន្យទៅទើរលើកោះខ្មោច!

មាលា ៖ (យំ) បង...! កោះខ្មោចនៅឯណាបង?

ចំរុង ៖ តាមការពិត កោះខ្មោចជាឈ្មោះដែលអ្នកដើរសំពៅ គេនាំគ្នាហៅទេ ព្រោះកាលដើមឡើយ តែងមានសំពៅទៅចតនៅក្បែរនោះ ហើយបញ្ជូនមនុស្សឱ្យឡើងទៅលើកោះ ប៉ុន្តែ...ប៉ុន្តែអ្នកដែលឡើងទៅទាំងប៉ុន្មានពុំដែលត្រឡប់មកសំពៅវិញសោះ! ដូច្នេះហើយបានជាគេនាំគ្នាសន្និដ្ឋានថា នៅលើកោះនោះមានខ្មោចបិសាចចាំយាយីជីវិតមនុស្សណាអូន! ហើយគេក៏នាំគ្នាហៅថាកោះខ្មោចៗជារៀងរហូតមក!

មាលា ៖ (យំ) បង...! ខ្ញុំស្តាប់ពាក្យសម្តីបងរៀបរាប់ អូនព្រឺខ្លួនណាស់ ប៉ុន្តែហេតុអីក៏បង... ក៏បងទៅដល់កោះនោះហើយបានសុខសប្បាយ?

ចំរុង ៖ សុទ្ធតែជារឿងភ័ព្វសំណាងទេអូន!

មាលា ៖ (យំ) ប្តីសំឡាញ់...!

ចំរុង ៖ តាមការពិត នៅលើកោះនោះ គ្មានខ្មោចបិសាចឯណាទេ! ដូចដែលគេនាំគ្នាស្មាននោះទេ! ប៉ុន្តែនៅទីនោះមានកុលសម្ពន្ធរស់នៅ! ជនជាតិភាគតិចទាំងនោះមានច្រើនណាស់អូន! ថ្ងៃដំបូងពេលដែលបងកំពុងតែដេកអស់កម្លាំងល្វិតល្វៃ នៅលើឆ្នេរខ្សាច់នោះ ពួកអ្នកកោះក៏ផ្អើលឈូរឆរមកមើល ហើយគេក៏ចាប់បងយកទៅចងផ្អោបនឹងបង្គោលឈើកណ្តាលភូមិ ដោយនិយាយខៀវខ្វារតាមភាសារបស់គេ ដែលបងស្តាប់ពុំបានទាល់តែសោះ!

| | | |
|---|---|---|
| | | អស់រយៈពេលកន្លះថ្ងៃ ទើបមេកន្ទ្រាញរបស់ពួកកុលសម្ពន្ធគេមកមើលបង! មេកន្ទ្រាញនោះ ជាបុរសមាឌធំដូចយក្ស ហើយទឹកមុខ ...ទឹកមុខរបស់គេគួរឱ្យខ្លាច... គួរឱ្យខ្លាចណាអូនណ៎ា! បន្ទាប់ពីនិយាយរកស្ដាប់គ្នាពុំបាននោះ គេក៏ត្រឡប់ទៅវិញ! បន្ទាប់មកគេយកបងទៅដាក់ក្នុងទ្រុងឈើមួយ ដោយស្រាយចំណងចេញទាំងអស់! |
| **មាលា** | ៖ | ហេតុអីគេយកទៅដាក់ក្នុងទ្រុង? |
| **ចំរុង** | ៖ | ថ្ងៃក្រោយមកទៀត ទើបបងដឹងថាមនុស្សចម្លែកណា ដែលឡើងទៅដល់លើកោះ សុទ្ធតែត្រូវគេចាប់ច្រកទ្រុងយកទៅទម្លាក់សម្លាប់ក្នុងទឹកអណ្ដូងកណ្ដុរអស់ ព្រោះគេយល់ថាមនុស្សទាំងអស់នោះសុទ្ធតែ... សុទ្ធតែជាអ្នកទន្ទ្រានដីរបស់គេ ប្រាថ្នាដណ្ដើមយកកោះដែលជាទីកន្លែងកេរ្ដិ៍ដូនតារបស់គេណាអូន! |
| **មាលា** | ៖ | គួរឱ្យព្រឺស្ញើបណាស់បង? |
| **ចំរុង** | ៖ | នៅពេលជាប់ទ្រុងនោះ បងបានជួបនឹងភ័ព្វវាសនាដោយចៃដន្យ ទើបបានរួចខ្លួនពីសេចក្ដីស្លាប់! |
| **មាលា** | ៖ | (យំ) បងកំសត់វេទនា ព្រោះតែដើររកស៊ីចិញ្ចឹមប្រពន្ធ! ខ្ញុំពិបាកចិត្តណាស់! តើហេតុអី...ហេតុអីបានជាបងរួចខ្លួន? |
| **ចំរុង** | ៖ | នៅក្នុងទ្រុងឈើនោះ បងឃើញស្បែកសត្វមួយបន្ទះធំ! បងដឹងខ្លួនថាគេប្រុងប្រៀបនឹងសម្លាប់បងហើយណាអូន ប៉ុន្តែតាមវិធីណានោះបងពុំដឹងទេ! ដោយក្ដីតក់ស្លុត និងអស់សង្ឃឹមហួសហេតុ បងក៏តាំងចិត្តឱ្យបានស្ងប់ទៅវិញដើម្បីរង់ចាំទទួលសេចក្ដីស្លាប់! ពេលនោះបងរើសបានធ្យូងមួយដុំ បងក៏គូររូបមុខមេកន្ទ្រាញកោះខ្មោចនៅលើស្បែក ព្រោះមុខរបស់គាត់កាចសាហាវធ្វើឱ្យជិតដាមជាប់ក្នុងអារម្មណ៍របស់បង! ដឹងអីលទ្ធផលនៃការរពឹសដៃនេះ អាចជួយឱ្យបងរួចជីវិត...ឱ្យបងរួចជីវិតណាអូន! |
| **មាលា** | ៖ | (យំ) ជួយបែបណាទៅបង? |
| **ចំរុង** | ៖ | នៅពេលដែល គេមកយកបងប្រុងទៅសម្លាប់ ឃើញរូបគំនូរនៅ |

លើស្បែកនោះ ក៏លើកយកទៅបង្ហាញមេកន្ទ្រាញ! អូនដឹងទេ ពួកកុលសម្ពន្ធនោះ ប្រហែលជាពុំដែលឃើញរូបគំនូរទេ! លុះឃើញបងគូររូបគាត់ដូចបេះបិទ គេក៏ដោះលែងបងទៅណាអូន!

មាលា ៖ (យំ) យីចម្លែកណាស់!

ចំរុង ៖ បន្ទាប់មកគេក៏ដោះលែងបងឱ្យរស់នៅជាមួយពួកគេ ហើយបានពួកកុលសម្ពន្ធលើកោះស្រឡាញ់រាប់អានគ្រប់គ្នាទាំងអស់! ជារៀងរាល់ថ្ងៃគេគ្មានឱ្យបងធ្វើអីក្រៅពីគូររូបទេ! ក្រោយមកបងបានស្លរជ័រ... ស្លរជ័រឈើនានាផ្សំបានជាថ្នាំគ្រប់ពណ៌ច្រើនមុខណាអូន! ធ្វើឱ្យពួកអ្នកនោះកាន់តែជក់ចិត្តទៅលើរូបគំនូររបស់បង! យូរទៅបងក៏ចេះភាសាគេខ្លះ!

មាលា ៖ (យំ) ថៃដន្យល្អណាស់បង!

ចំរុង ៖ ច្រើនខែក្រោយមក មានសំពៅមួយ បើកនៅឆ្ងាយពីកោះអាចមើលឃើញ! បងទទូចសុំឱ្យគេជូនទូកចូលទៅរកសំពៅ ប៉ុន្តែមេកន្ទ្រាញ ទាំងអ្នកកោះទាំងអស់ប្រកែកពុំព្រមឱ្យបង... ពុំព្រមឱ្យបងធ្វើការត្រឡប់មកដីគោកវិញសោះ!

មាលា ៖ (យំ) យី! ពួកកុលសម្ពន្ធនោះ គឺជាអ្នកបំផ្លាញសុភមង្គលរបស់យើង! គួរឱ្យសោកស្តាយណាស់!

ចំរុង ៖ បងរស់នៅដោយគ្រាំគ្រា ក្នុងក្តីទុក្ខព្រួយអស់រយៈពេល ជិតពីរឆ្នាំទើបនឹកឃើញ មធ្យោបាយមួយ! បងបានកាប់ឈើធ្វើជាក្បូនមួយ គឺថាធ្វើមួយថ្ងៃបន្តិច មួយថ្ងៃបន្តិច លាក់ទុកក្នុងព្រៃរហូតទាល់តែសម្រេចបានជាក្បូនធំមួយ ហើយលាក់ស្បៀងបម្រុងទុកផង! អូនអើយ រាត្រីមួយឆ្លៀតពេលទឹកជោរ បងបែរវាក្បូនទម្លាក់ចេញដំណើរពីកោះយ៉ាងស្ងាត់ស្ងៀម! បងរស់លើក្បូនអស់រយៈជិតដប់ថ្ងៃ ទើបជួបនឹងសំពៅមួយ បងក៏សុំដោយសារនឹងគេមកដល់ឧត្តរបុរីវិញ!

## ឈុតទី ១៩

## ឆាកទី ៣៨

មាលា ៖ (ច្រៀង) ប្តីទាំងពីរហ្នឹង អឺ អឺ អឺង អឺយ ដឹងចោលមួយណា (ពីរ

ដង) ចិត្តអឺយ ចិត្តអឺយ ខ្លោចផ្សា ឱណាលោកអើយដល់ផ្លូវបំបែក! (និយាយទាំងយំ) បងភូរិន្ទ! អូនពិបាកចិត្តណាស់! បងចំរុងជាគូស្នេហ៍កំសត់កម្រដឹកដៃគ្នាឆ្លងកាត់នគរមួយពីរនាក់ ពុំដែលប្រព្រឹត្តិអ្វីពុំគាប់បីមកលើរូបប្រពន្ធសោះ រីឯបងភូរិន្ទតាំងពីស្គាល់គ្នាមក គាត់បានជួយឧបត្ថម្ភរក្សាខ្ញុំគ្រប់ពេលវេលា រហូតបានរៀបការជាមួយគ្នាទៀត គាត់ស្មោះត្រង់នឹងប្រពន្ធ ស្រឡាញ់ប្រពន្ធ! ឱទេវតាលោកអើយ តើឱ្យខ្ញុំ...តើឱ្យខ្ញុំជ្រើសរើសយកផ្លូវណា! ឬមួយខ្ញុំត្រូវលោតទឹកសម្លាប់ខ្លួនតែម្នាក់ឯងទៅ ដើម្បីគេចចេញពីការដោះស្រាយនូវបញ្ហាផ្លូវបែកជាពីរនេះ! ទេ! ទេ! ធ្វើដូច្នេះមិនត្រូវទេ ព្រោះទារកដែលនៅក្នុងផ្ទៃនេះគ្នាគ្មានដឹងអ្វីទាល់តែសោះ ខ្ញុំមិនត្រូវសម្លាប់កូនទេ...មិនត្រូវសម្លាប់កូនទេ! ជីវិត...ជីវិត ហេតុអីក៏អ្នកចូលចិត្តផ្ទុកនូវរឿងអាថ៌កំបាំងម្ល៉េះ? ខ្ញុំកុហកបងចំរុង ដើម្បីមកឃាត់បងភូរិន្ទកុំឱ្យគាត់ទៅផ្ទះជួបគ្នា! ប៉ុន្តែ...ប៉ុន្តែ វាមិនមែនជាបញ្ហាដោះស្រាយវិបត្តិទេ!

**ជាងឈើទី១** ៖ នាងមាលាទេអ្វី? ហេតុអីក៏រលះរលាំងម្ល៉េះក្មួយ? មានពោះមានពង់ផង ប្រយ័ត្នប្រយែងណានាង!

**ជាងឈើទី២** ៖ នាងមករកប្ដីអ៊ែស៎?

**មាលា** ៖ ចាស៎! លោកពូ បងភូរិន្ទគាត់ទៅណាហើយ?

**ជាងឈើទី២** ៖ អ៎ូនែ៎! ភូរិន្ទ គាត់មកបង្ហើយក្បាលក្រពើរទេះថ្មីនោះ! រួចហើយគាត់ត្រឡប់ទៅផ្ទះហើយ! ទៅមួយសន្ទុះហើយនាង!

**មាលា** ៖ ខ្ញុំមកអម្បាញ់មិញនេះ ហេតុអីពុំប្រទះគាត់នៅតាមផ្លូវណាលោកពូ?

**ជាងឈើទី៣** ៖ ភូរិន្ទបានប្រាប់តាថា គេមានការ ទៅរោងជាងដែកណានាង! ហើយពេលចេញពីរោងជាងដែកនោះទៅ គេនឹងទៅផ្ទះតែម្ដង! ប្រហែលជាដូច្នេះហើយបានជាឃ្លៀងផ្លូវគ្នាណា!

**មាលា** ៖ អ៊ីចឹងខ្ញុំសូមលាលោកពូទាំងអស់គ្នាសិនហើយ!

**ជាងឈើទី២** ៖ អឺ! ទៅចុះ យីនាងអីក៏ដើរលឿនម្ល៉េះហាស់?

## ឆាកទី ៣៩

(ច្រៀង) ដូច្នេះរឿងធំ ឱស្រីមុំជាហ៊ុមបងអើយកក្រើកផែនដី លោកអើកក្រើកផែនដី ចិត្តអ្នកទាំងបី ឱស្រីមុំជាហ៊ុមបងអើយឈឺចាប់ខ្លោចផ្សា លោកអើយឈឺចាប់ខ្លោចផ្សា។

**ចំរុង** ៖ អ្ហ៎ា! កោរពុកមាត់ មុជទឹកស្អាតបាតអ៊ីចឹងទៅ ខ្ញុំក្លាយទៅជាចំរុងដូចដើមវិញហើយ មិនមែនជាចំរុងនៅលើកោះជាមួយពួកកុលសម្ពន្ធទៀតទេ! ផ្ទះខ្ញុំនៅដដែល អត់ប្រែប្រួលសោះ តុទូដាក់ត្រង់ណា នៅត្រង់នោះដូចដើមទាំងអស់! យី! ចុះអូនមាលាបានកូនរទេះនេះពីណាមក យកមកតាំងស្អាតម្ល៉េះអើស៎? យី! ស្អាតណាស់!

**(សម្លេងគោះទ្វារ)**

**ចំរុង** ៖ អ៎! អូនមាលាមកវិញហើយអ្ហី? អ្ហ៎ា! ភូរិន្ទ!

**ភូរិន្ទ** ៖ អ៊ូ! ចំរុង! អ៊ូ! មិត្តនៅរស់ទេអ្ហេស?

**ចំរុង** ៖ ស្មានតែភូរិន្ទស្លាប់បាត់ទៅហើយ?

**ភូរិន្ទ** ៖ គ្នាត្រេកអរណាស់! ខ្ញុំក៏មិននឹកស្មានថាឯងនៅរស់ដែរចំរុង!

**ចំរុង** ៖ ឯងមកជួនពេលល្អណាស់!នែ៎! គ្នានៅរស់លើកោះខ្មោចអស់រយៈពីរឆ្នាំណាភូរិន្ទ! គ្នាទើបនឹងមកដល់ផ្ទះមុននេះបន្តិចទេណ៎ា! ឯងអាចមករកផ្ទះគ្នាឃើញ? នែ៎ តាំងពីសំពៅលេចមក តើឯងទៅនៅឯណាភូរិន្ទ?

**ភូរិន្ទ** ៖ (នឹកក្នុងចិត្ត) ពុទ្ធោ! ចំរុងអត់ទាន់ដឹងរឿងទេ! តើខ្ញុំត្រូវដោះស្រាយយ៉ាងណាទៅ?

**ចំរុង** ៖ ហេតុអីបានជាឯងលែងនិយាយស្ដីអ៊ីចឹង? ក្ដីទុក្ខលំបាកក្នុងអតីតកាលនេះ វាកន្លងហួសទៅហើយ ឯងបំភ្លេចវាសិនទៅភូរិន្ទ! នែ៎! ប្រពន្ធរបស់គ្នាទៅផ្សារយូរហើយណ៎ា កាលណានាងត្រឡប់មកវិញ យើងបានម្ហូបឆ្ងាញ់ យើងផឹកស្រាឱ្យណាណី! មែនទេភូរិន្ទ?

**ភូរិន្ទ** ៖ គ្នាពិបាកចិត្តណាស់សំឡាញ់!

**ចំរុង** ៖ (សើច) ឯងចាំមើលចុះណា ប្រពន្ធរបស់គ្នាមិនមែនស្អាតតែរូបទេវើយ ថែមទាំងជាស្ត្រីគ្រប់លក្ខណ៍ទៀតផងណ៎ា! បន្ទាប់ពីបានស្គាល់គ្នាហើយ ឯងគង់ស្ងើចសសើរនាងជាមិនខានទេ! យី! ហេតុអីបានជាឯងមិននិយាយស្ដី... មិននិយាយស្ដីរកខ្ញុំអ៊ីចឹង?

| | | |
|---|---|---|
| **ភូរិន្ទ** | ៖ | ចំរុងសំឡាញ់! មិននឹកស្មានថាជីវិតមនុស្ស ជាជង្រុកដែលផ្ទុកនូវអាថ៌កំបាំងបត់បែនគ្មានទីបញ្ចប់អ៊ីចឹងសោះ! |
| **ចំរុង** | ៖ | យី! ឯងចង់និយាយពីអីទៅភូរិន្ទ? |
| **ភូរិន្ទ** | ៖ | អូន៎! គ្នាចង់និយាយពីវាសនារបស់មនុស្ស ដែលមើលមិនឃើញទាយមិនត្រូវ ដូចជារូបយើងទាំងពីរនាក់ ដែលលេចសំពៅកណ្ដាលសមុទ្រ គួរតែស្លាប់ទៅហើយ បែរជាជួបនឹងភ័ព្វវាសនាល្អ បានរស់រានមានជីវិតទាំងពីរ! ពីរឆ្នាំកន្លងមកនេះ គ្នាអាណោចអាធម្មក្នុងចិត្តចំពោះឯងណាស់! |
| **ចំរុង** | ៖ | អ៊ូ! គ្នាក៏នឹកស្រណោះដល់ឯងដែរភូរិន្ទ ព្រោះគិតថាឯងច្បាស់ជាស្លាប់ក្នុងទឹកទៅហើយណ៎ា? |
| **ភូរិន្ទ** | ៖ | ប៉ុន្តែ... ប៉ុន្តែចំរុងដឹងទេ? បានជួបមុខឯងនៅពេលនេះ គ្នាខ្លោចផ្សារក្នុងចិត្តលើសដើមទៅទៀត! |
| **ចំរុង** | ៖ | អ៊ូ! នោះប្រពន្ធរបស់គ្នាត្រឡប់មកវិញហើយភូរិន្ទ! អូនអ៊្ហា! នេះគឺភូរិន្ទជាមិត្តរបស់បងដែលទទួលគ្រោះថ្នាក់លេចសំពៅជាមួយគ្នា! អូនជម្រាបសួរគេទៅ! ភូរិន្ទ! នេះគឺមាលាប្រពន្ធរបស់គ្នា ដែលគ្នាតែងតំណាលអំពីរូបនាងប្រាប់ឯងនោះណ៎ា! (មាលាយំ)! យី ម៉េចក៏ស្ងៀមស្ងាត់ទាំងពីរនាក់អ៊ីចឹង? មាលាម៉េចក៏មិនជម្រាបសួរភ្ញៀវទៅអូន? អ៊្ហា! ហេតុអីក៏អូនយំអ៊ីចឹង? មានរឿងអីអ្ហែស៎? អូនត្រឡប់មកពីផ្សារវិញ អូនអត់ទិញបានម្ហូបអីទេអ្ហី បានជាអូនយំ? |
| **មាលា** | ៖ | អូនមិនទិញនោះទេ ព្រោះអូនដឹងថា ថ្ងៃនេះបងទទួលទានអ្វីក៏ពុំកើតដែរ! |
| **ចំរុង** | ៖ | អ៊ូមែនហើយ! បានមកដល់ផ្ទះជួបមុខប្រពន្ធ បងត្រេកអរពេកហាក់ដូចជាលែងឃ្លានអ្វីទាំងអស់? ម៉ោះមកអង្គុយជិតបងមកអូនអង្គុយជិតបងមកណ៎ា? |
| **មាលា** | ៖ | (យំ) អូនឈរនៅត្រង់នេះបានហើយ! |
| **ចំរុង** | ៖ | ពេលវេលាពីរឆ្នាំកន្លងមកនេះ បានធ្វើឱ្យប្រពន្ធរបស់បងមានអត្តចរិតប្លែកខុសពីដើមច្រើនណាស់? |
| **មាលា** | ៖ | (យំ) មិនត្រឹមតែប៉ុណ្ណឹងទេបង! ពេលវេលានេះបានខាំបំបែកសេចក្ដីស្នេហារវាងយើងទាំងពីរនាក់ទៀតផង! |

**ចំរុង** ៖ ទេ! ហេតុអីក៏អូននិយាយរបៀបនេះទៅវិញ? តើពាក្យសម្ដីរបស់អូនបានសេចក្ដីថាយ៉ាងម៉េច? ភូរិន្ទឯងជួយស្ដាប់សម្ដីរបស់ប្រពន្ធគ្នាមើល!

**ភូរិន្ទ** ៖ មាលានិយាយត្រូវណាស់សម្លាញ់! តាមការពិត គឺពេលវេលាទេដែលជាអ្នកលេបត្របាក់ឆក់យកសេចក្ដីស្នេហារបស់ឯង!

**ចំរុង** ៖ បានសេចក្ដីថា...បានសេចក្ដីថា គ្នាត្រូវបែកបាក់ពីមាលាហ្អែស៎?

**ភូរិន្ទ** ៖ ចំរុង! ចូរឯងពិនិត្យសង្កេតរូបរាងមាលាមើល! ពិនិត្យឱ្យច្បាស់ទៅមើល!

**ចំរុង** ៖ អ្ហា! មាលាមានផ្ទៃពោះ?

**មាលា** ៖ (យំ) ចាស៎! អូនមានផ្ទៃពោះជាង៥ខែហើយបង!

**ចំរុង** ៖ បងរវល់តែសប្បាយ ដោយសារបានជួបអូន អត់បានពិនិត្យមើលរូបរាងកាយរបស់អូនទេ! អូនមានផ្ទៃពោះជាមួយអ្នកណា?

**មាលា** ៖ (យំ) ចាស៎! អូនមានផ្ទៃពោះជាមួយ...ជាមួយ...!

**ចំរុង** ៖ ជាមួយអ្នកណាអូន?

**មាលា** ៖ (យំ) ជាមួយប្ដីអូន...!

**ចំរុង** ៖ ពុទ្ធោ!

**មាលា** ៖ (យំ) បងភូរិន្ទបានមកដល់ឧត្តបុរីនេះពីរឆ្នាំមកហើយ!

**ចំរុង** ៖ ភូរិន្ទមកពីរឆ្នាំហើយ?

**ភូរិន្ទ** ៖ ត្រូវហើយសម្លាញ់!

**មាលា** ៖ (យំ) ចាស៎! បាត់បងជាងមួយឆ្នាំអូនអស់សង្ឃឹមរលីង ព្រោះនឹកស្មានថាបងស្លាប់! ទីបំផុតអូនក៏សម្រេចចិត្ត រៀបការជាមួយបងភូរិន្ទ...!

**ចំរុង** ៖ អ្ហា! រៀបការជាមួយភូរិន្ទ? ដូច្នេះមាលា ជាប្រពន្ធរបស់ភូរិន្ទហ្អែស៎?

មាលា ៖ (យំ) ចាស៎!

ចំរុង ៖ ភូរិន្ទឯងជាប្ដីរបស់មាលាហ្អែស?

**ភូរិន្ទ** ៖ ត្រូវហើយ! សព្វថ្ងៃនេះនាងជាប្រពន្ធរបស់គ្នាណ៎ា!

**ចំរុង** ៖ ចុះអញជាស្អីទៅវិញ? អញជាស្អីទៅវិញ?

**មាលា** ៖ (យំ) សូមបងអភ័យទោសឱ្យអូនផង!

ចំរុង ៖ អញត្រូវសម្លាប់អាក្បួយរំចូត!

ភូរិន្ទ ៖ បើឯងប្រាថ្នាជីវិតគ្នា! គ្នាត្រូវការពាខ្លួនដែរណា៎!

ចំរុង ៖ អើ មិនអីទេ! ចូលមក!

មាលា ៖ (យំ) ទេ...! បងទាំងពីរសម្លាប់អូនមកចុះ! បងសម្លាប់អូនទៅ... សម្លាប់អូនទៅ...!

ចំរុង ៖ អូនមិនត្រូវមកឈរពាំងមុខអ៊ីចឹងទេ! ថយចេញទៅ!

ភូរិន្ទ ៖ ថយចេញមាលា!

មាលា ៖ (យំ) ទេ...! ទេ...! មុននឹងបងកាប់សម្លាប់គ្នា បងសម្លាប់អូនចោលសិនទៅ! បងចំរុង! កាំបិតរបស់បងចាក់អូនសម្លាប់មកចុះ! ពូថៅរបស់បងភូរិន្ទ! បង...បងកាប់អូនមកចុះ ព្រោះកំហុសនេះ... កំហុសគ្រប់បែបយ៉ាង គឺរូបអូនទេ... គឺរូបអូនទាំងអស់! បងសម្លាប់អូនចោលទៅ! សម្លាប់អូនទៅ!

ភូរិន្ទ ៖ ទេ...! ទេ...! តាមការពិតទៅអូនគ្មានកំហុសទេ ហើយបងក៏គ្មានកំហុសដែរ!

ចំរុង ៖ ដូច្នេះបានសេចក្ដីថា គឺអញនេះជាអ្នកមានកំហុសមែនទេ?

ភូរិន្ទ ៖ សម្លាញ់ក៏គ្មានកំហុសដែរ!

ចំរុង ៖ ឯងឃោរឃៅណាស់អាភូរិន្ទ! មាលា បងមិននឹកស្មានថាចិត្តអូនដល់ប៉ុណ្ណឹងសោះ?

មាលា ៖ (យំ) ប្ដីសម្លាញ់ចិត្តអូន...!

ចំរុង ៖ (ច្រៀង) ប្ដីត្រូវរងគ្រោះ ឱណាអូនអើយស្នើរក្សាយជីវ៉ា (ពីរដង) រស់នៅ រស់នៅខ្លោចផ្សា ឱណាអូនអើយលើកោះសែនឆ្ងាយ (ពីរដង) ប្រពន្ធនៅផ្ទះ ឱណាអូនអើយឥតមានខ្វល់ខ្វាយ (ពីរដង) រស់ត្រេក រស់ត្រេកសប្បាយ ឱណាលោកអើយជ្រកទ្រូងប្រុសថ្មី (ពីរដង) ព្រះអើយមើលចុះ ឱណាលោកអើយនេះហើយចិត្តស្រី (ពីរដង) សាវ៉ា សាវ៉ាអប្រិយ ឱណាលោកអើយគ្មានក្ដីស្រណោះ (ពីរដង)!

មាលា ៖ (យំ) បងចំរុង! អូនពិតជាខុសមែន សូមបងជេរស្ដីត្មេះតិះដៀលអូនឱ្យអស់ចិត្តចុះ ឱ្យសមនឹងកំហុសរបស់អូន!

ភូរិន្ទ ៖ អូនមាលា តាមការពិតរវាងយើងទាំងបីនាក់ សុទ្ធតែគ្មានកំហុស

ទាំងអស់គ្នា មិនអាចអ្នកណាបន្ទោសអ្នកណាបានទេ គឺមាគ៌ាជីវិតវានាំឱ្យយើងបត់បែនអ៊ីចឹងណា!

ចំរុង ៖ វាគ្មានមាគ៌ាជីវិតស្អីទេ! តាមការពិត ឯងនេះជាមនុស្សទ្រុស្តមិត្ត ឆ្លៀតពេលយើងមានគ្រោះថ្នាក់ ឯងមកឆក់ប្លន់សេចក្តីស្នេហារបស់យើង!

ភូរិន្ទ ៖ មិនមែនអ៊ីចឹងទេចំរុង មកពីគ្នាស្មានថា ឯងស្លាប់បាត់ទៅហើយណ៎ា!

ចំរុង ៖ អូនមាលា! ឥឡូវនេះដូចអូនបានឃើញស្រាប់ហើយថា បងនៅរស់ទេណាអូន! បងបានវិលត្រឡប់មកផ្ទះសម្បែងវិញហើយ! ដូច្នេះបើអូនបោះបង់ភូរិន្ទជាប្តីក្រោយនេះចោល បងនៅតែទទួលអូនជាភរិយា ហើយស្រឡាញ់ថ្នាក់ថ្នមដូចពីដើមដដែលណាអូន!

មាលា ៖ (យំ) បងចំរុង... បងចំរុង... បងល្អនឹងអូនណាស់ ប៉ុន្តែ...ប៉ុន្តែ...!

ចំរុង ៖ ប៉ុន្តែយ៉ាងម៉េច?

មាលា ៖ (ច្រៀង) អូនសែនស្រណោះ អាលោះអាល័យ រូបប្រុសចរណៃ ស្វាមីកំសត់ (បន្ទរ៖ រូបប្រុសចរណៃ ស្វាមីកំសត់) បងចិត្តអូន មិនមែនផិតក្បត់ ស្នេហ៍យើងត្រូវព្រាត់ ដោយព្រេងវាសនា (បន្ទរ៖ ស្នេហ៍យើងត្រូវព្រាត់ ដោយព្រេងវាសនា) ពេលនេះហួសហើយ អូនវង្វេងសោកា សូមម្ចាស់ជីវ៉ា មេត្តាអូនផង!

ចំរុង ៖ ហេតុអី... ហេតុអីបានជាអូនពុំព្រម? តើគេមានអនុស្សាវរីយ៍ ល្អជាមួយនឹងអូនច្រើនជាងបងឬស៎?

មាលា ៖ (យំ) មិនមែនដូច្នេះទេបងចំរុង! ចិត្តអូនដែលធ្លាប់ស្រឡាញ់បងប៉ុណ្ណា នៅតែស្រឡាញ់ដដែលអត់ស្រកស្រុតឡើយ! ប៉ុន្តែឥឡូវនេះអ្វីៗកន្លងហួសអស់ទៅហើយ ពុំអាចវិលត្រឡប់បានទេ! បង...លើសពីនេះអូនថែមទាំងមានផ្ទៃពោះជាមួយនឹងបងភូរិន្ទទៅហើយ អូនមិនចង់ឱ្យអនាគតរបស់កូន វាធ្លាក់ក្នុងភាពច្របូកច្របល់អាស្រូវដូចអូនទៀតទេ! សូមបងយល់ចិត្តអូនផង!

ចំរុង ៖ រវាងបង និងភូរិន្ទតើអូនស្រឡាញ់អ្នកណា?

មាលា ៖ (យំ) អូនស្រឡាញ់...អូនស្រលាញ់បង ប៉ុន្តែ... ប៉ុន្តែអូនអាណិតបងភូរិន្ទដែរ! អូនពុំអាចលះបង់គាត់បានទេ!

ចំរុង ៖ ចិត្តសាវាមែន! ចុះចេញពីផ្ទះរបស់យើងភ្លាមទៅស្រីថោកទាប!

មាលា ៖ (យំ) អូននឹងចុះចេញ! ប៉ុន្តែសូមបងកុំខឹងនឹងអូន!

ចំរុង ៖ យើងអនុញ្ញាតឱ្យនាងឯង យកសម្លៀកបំពាក់ ទៅតាមទាំងអស់! ឆាប់ចុះភ្លាមទៅ... ទៅ...!

មាលា ៖ (យំ)ចាស៎!

ចំរុង ៖ ភូរិន្ទ! អ្វីដែលសម្បត្តិរបស់ឯង ចូរឯងយកទៅចុះ ហើយឆាប់នាំគ្នាចុះចេញឱ្យផុតពីមុខពីមាត់អញភ្លាម!

ភូរិន្ទ ៖ ជិតមួយឆ្នាំមកនេះ គ្នាគ្មានទ្រព្យសម្បត្តិអ្វី ដែលមកតម្កល់ដាក់ទុកនោះទេ មានតែកូនរទេះតូច ដែលដាក់តាំងនៅលើតុនោះ! គ្នាសុំវាយកទៅតាមហើយ?

ចំរុង ៖ យ៉... យក! យកកូនរទេះហ្នឹង នាំប្ដីប្រពន្ធឆ្កួតលីលារបស់ឯងជិះទៅកាន់ឋាននរកភ្លាមទៅ! ចុះភ្លាម...!

មាលា ៖ (យំ) បងចំរុង... បងចំរុង...!

ចំរុង ៖ អើ...! រួចរាល់អស់ហើយឬនៅ?យកបង្វេចហ្នឹងចុះឱ្យផុតពីផ្ទះរបស់យើងភ្លាម! ចុះឱ្យផុតភ្លាម! ចុះទៅស្រីថោកទាប!

មាលា ៖ (យំ) ក្នុងមួយជីវិតរបស់អូន នេះជាលើកទីបួនហើយ ដែលត្រូវគេបណ្ដេញចុះពីផ្ទះ ហើយជេរស្ដីថាជាមនុស្សថោកទាប! ហេតុអី ... ហេតុអីក៏ពាក្យថោកទាបហ្នឹង ចេះតែអន្ទោលតាមរូបខ្ញុំឥតឈប់ឈរសោះ? ប៉ុន្តែលើកនេះ អូន... អូនមិនខឹងនឹងពាក្យត្មេះតិះដៀលរបស់បងទេ ព្រោះតាមការពិតបងគួរតែជេរ... បងគួរតែជេរ... បងចំរុង... អូនសូមលាបងហើយ... អូនលារហូត...!

ចំរុង ៖ (ស្រែក) អញលែងចង់ស្ដាប់ទៀតហើយ! ចុះភ្លាមទៅ... ចុះទៅ...!

ភូរិន្ទ ៖ សម្លាញ់គ្នាលាហើយណា!

ចំរុង ៖ គ្មានសម្លាញ់ គ្មានមិត្តនឹងឯងទៀតទេ! ហឹស ចុះឱ្យឆាប់... ចុះឱ្យឆាប់នឹងអាលអញគិតគូរ! អញមិនចង់ឃើញមុខពួកឯងទៀតទេ...!

**(ស្គររោទិ៍ ត្រឹមៗៗ...)**

ចំរុង ៖ ព្រះអើយ! គេដឹកដៃគ្នាទៅហើយ គេជាប្ដីប្រពន្ធនឹងគ្នា ចុះរូបខ្ញុំ...

រូបខ្ញុំជាស្អីទៅវិញ?

## ឆាកទី ៤០

**(ច្រៀង) មេឃខ្មៅងងឹត ជុំជិតពពក (បន្ទរៈ ជុំជិតពពក) ភ្លៀងបង្អុរមក នាំយករឿងខ្លោចផ្សា (បន្ទរៈ នាំយករឿងខ្លោចផ្សា)។**

**ភូរិន្ទ** ៖ ទទឹកប្រពន្ធអស់ទៅហើយ! អូនរងារទេ?

**មាលា** ៖ អូនហាក់ដូចជាលែងរងារអស់ហើយបង!

**ភូរិន្ទ** ៖ ភ្លៀងធំណាស់! ភ្លៀងនេះនឹងជួយលាងជម្រះ នូវអតីតកាលជូរចត់របស់យើង!

**មាលា** ៖ មិនមែនដូច្នេះទេបង! ទោះជាភ្លៀង រហូតដល់លេចផែនដីទាំងមូល ក៏វាពុំអាចផ្សះដំបៅជីវិតរបស់យើងបានដែរ! ប៉ុន្តែអតីតកាលជាស្រមោល បច្ចុប្បន្នជាការពិត អនាគតជារឿងដែលត្រូវដោះស្រាយ! អ្វីៗ ដែលកន្លងហួសទៅហើយ វាពុំអាចវិលត្រឡប់មកវិញបានទេ!

**ភូរិន្ទ** ៖ ឱ្យតែអូនមានគំនិតប្តេជ្ញាបែបនេះ ទោះជាក្រលំបាកយ៉ាងណាក៏ដោយក៏ជីវិត និងស្នេហារបស់យើងពោរពេញទៅដោយសុភមង្គលដែរណាអូន!

**មាលា** ៖ ចាស៎ ចាប់ពីថ្ងៃនេះតទៅ ជីវិតរបស់អូនសូមផ្ញើលើបងទាំងស្រុងហើយណ៎ា!

**(ពោល) យីកេសម្តែងរឿងក្បួនជីវិត ចែកជូនសន្តានញាតិឆ្ងាយជិត ចប់អស់សេចក្តីតាមគំនិត លាមិត្តអ្នកស្តាប់មួយគ្រាសិន។**

**(ច្រៀង) ខ្ញុំសូមលាហើយ ខ្ញុំសូមលាលាត (ពីរដង) ខ្ញុំលាទាំងញាតិ សន្តានប្រុសស្រី ខ្ញុំលាលោកតា ខ្ញុំលាលោកយាយ (ពីរដង) ទាំងជិតឆ្ងាយក្តី សូមបានសុខសាន្ត៕**

**សូមអរគុណ**!!!